ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០២២-២០៣០

*“ទំនើបកម្មកសិកម្មកម្ពុជា មានលក្ខណៈប្រកួតប្រជែង បរិយាបន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព”*

បានទទួលការសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ថ្ងៃសុក្រ ១៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២

# មាតិកា


ទំព័រ

អារម្ភកថា ................................................................ i

សេចក្តីសង្ខេប ................................................................ ១

១. សេចក្តីផ្តើម ................................................................ ៣

១.១. ទិដ្ឋភាពរួម ................................................................ ៣

១.២. វឌ្ឍនភាព និងបញ្ហាប្រឈមនៃអនុវិស័យ ................................................................ ៥

១.៣. និន្នាការសាកល និងតំបន់ក្នុងវិស័យកសិកម្ម ................................................................ ១២

១.៤. និន្នាការក្នុងប្រទេសនៃវិស័យកសិកម្ម ................................................................ ១៣

១.៥. បញ្ហាប្រឈមក្នុងវិស័យកសិកម្ម ................................................................ ១៥

២. ចក្ខុវិស័យ ................................................................ ១៩

៣. គោលបំណង ................................................................ ១៩

៤. គោលដៅ ................................................................ ១៩

៥. យុទ្ធសាស្ត្រ ................................................................ ២១

៦. យន្តការសម្រាប់អនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម
ឆ្នាំ២០២២-២០៣០ ................................................................ ៣៤

៧. ធនធានហិរញ្ញវត្ថុ ................................................................ ៣៥

៨. ការពិនិត្យតាមដាន និងវាយតម្លៃ ................................................................ ៣៧

៩. ការគ្រប់គ្រងហានិភ័យ ................................................................ ៣៨

១០. សេចក្តីសន្និដ្ឋាន ................................................................ ៣៩

ឧបសម្ព័ន្ធ១ : សូចនាករគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម
ឆ្នាំ២០២២-២០៣០ ................................................................ ៤១

ឧបសម្ព័ន្ធ២ : ម៉ាទ្រិកស្តីពីវិធានការគោលនយោបាយ/ផែនការសកម្មភាពជាក់លាក់ ៤២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីឱ្យប្រទេសជាតិមានសន្តិភាព សន្តិសុខពេញលេញ មានឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង ក្រោមក្របខ័ណ្ឌគោលនយោបាយ ***ឈ្នះ ឈ្នះ*** ចាប់តាំងពីចុងឆ្នាំ១៩៩៨មក។ ចាប់តាំងពីពេលនោះមក ព្រះរាជាណាចក្រកម្ពុជាបានបោះជំហានទៅមុខយ៉ាងស្វាហាប់លើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ សហប្រតិបត្តិការ និងអភិវឌ្ឍន៍។ ផ្អែកលើមូលដ្ឋានគ្រឹះនេះ សេដ្ឋកិច្ចកម្ពុជាមានដំណើរការរីកលូតលាស់គួរជាទីមោទនៈ ដោយទទួលបានកំណើនប្រចាំឆ្នាំជាមធ្យមប្រមាណជាង៧% ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ដែលបានឆ្លុះបញ្ចាំងពីការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម សេវាកម្ម ទេសចរណ៍ និងអចលនទ្រព្យ។

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានមហិច្ឆតា ក្នុងការធ្វើទំនើបកម្មវិស័យកសិកម្មឱ្យកាន់តែមានភាពប្រកួតប្រជែង បរិយាបន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងមាននិរន្តរភាព ដែលនឹងនាំមកនូវការបង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពយូរអង្វែងសម្រាប់ប្រជាជនកម្ពុជា។

គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ត្រូវបានរៀបចំដើម្បីឱ្យសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងនេះ។ គោលបំណងចម្បងរបស់គោលនយោបាយនេះគឺបង្កើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មឱ្យកើនយ៉ាងតិច៣%ក្នុងមួយឆ្នាំ។ ដើម្បីសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍កសិកម្មក្នុងរយៈពេល១០ឆ្នាំខាងមុខ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅគោលនយោបាយជាយុទ្ធសាស្ត្រគឺ បន្តជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែងខ្ពស់ តាមរយៈការផ្តល់សេវាកម្មដែលមានគុណភាព ដែលនឹងផ្តល់មកវិញនូវការផ្គត់ផ្គង់ស្បៀងអាហារមានសុវត្ថិភាពនិងមានអាហារូបត្ថម្ភគ្រប់គ្រាន់ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដី ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ លើសពីនេះទៀត គោលនយោបាយនេះនឹងចូលរួមចំណែកសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ ពិសេសគោលដៅទី២ គឺបញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភនិងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព។

រាជរដ្ឋាភិបាលកម្ពុជា លើកទឹកចិត្តឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់អនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ឱ្យមានប្រសិទ្ធភាព ដោយត្រូវរៀបចំកសាងផែនការសកម្មភាពជាក់លាក់សម្រាប់អនុវត្ត បង្កើន និងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍនិងវិស័យឯកជននានា ចូលរួមអនុវត្តគោលនយោបាយនេះឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយបរិយាបន្ននិងមានប្រសិទ្ធភាពខ្ពស់។

រាជរដ្ឋាភិបាលកម្ពុជា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ពិតជានឹងរួមសហការគ្នាអនុវត្តសកម្មភាពការងារទៅតាមភារកិច្ច ពិសេសសហគមន៍អន្តរជាតិនឹងបន្តផ្តល់ជំនួយ ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តគោលនយោបាយនេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមានតាមផែនការនិងការរំពឹងទុក។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដែលបានចូលរួមយ៉ាងយកចិត្តទុកដាក់ ក្នុងដំណើរការកសាងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២២-២០៣០នេះនិងសូមលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្ត ដើម្បីសម្រេចបាននូវចក្ខុវិស័យប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃចន្ទ ១៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានមហិច្ឆតាក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ដើម្បីឱ្យវិស័យនេះកាន់តែមានភាពប្រកួតប្រជែង មានបរិយាបន្នធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព។

គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ផ្តល់នូវការតម្រង់ទិសយ៉ាងទូលំទូលាយនិងមុតស្រួចដើម្បីអភិវឌ្ឍន៍វិស័យនេះ សម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងវិស័យឯកជនរួមគ្នាអនុវត្ត។ គោលនយោបាយនេះបានដាក់ចេញនូវផ្នែកសំខាន់ៗចំនួន៤ គឺ (១) ការធ្វើទំនើបកម្មនិងពាណិជ្ជូបនីយកម្មក្នុងខ្សែច្រវាក់តម្លៃកសិកម្ម (២) ការវិនិយោគសាធារណៈនិងឯកជនក្នុងវិស័យកសិកម្ម (៣) កំណើនប្រកបដោយចីរភាពនិងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង (៤) ការកែទម្រង់ស្ថាប័ននិងបញ្ហាអន្តរវិស័យ។

គោលនយោបាយនេះមានគោលបំណងជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែង និងបរិយាបន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាហារូបត្ថម្ភ សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុកនិងការនាំចេញ ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គោលដៅជាយុទ្ធសាស្ត្រចំនួន៤ ត្រូវបានកំណត់និងដាក់ឱ្យអនុវត្តរួមមាន៖

(ទី១) លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង។

(ទី២) បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ឥណទាន និងការសម្រួលកសិពាណិជ្ជកម្ម។

(ទី៣) បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

(ទី៤) ពង្រឹងអភិបាលកិច្ចនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម។

ចំណុចសំខាន់នៃគោលនយោបាយនេះ គឺផ្តោតលើយុទ្ធសាស្ត្របង្កើនផលិតភាពនិងជំរុញកំណើនកសិកម្ម សំដៅពង្រីកការនាំចេញផលិតផលកសិកម្ម ព្រមទាំងការសម្របសម្រួល ការផ្លាស់ប្តូរទៅជាប្រព័ន្ធស្បៀងអាហារទំនើបនិងប្រកបដោយនិរន្តរភាព។ ក្របខ័ណ្ឌគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០នេះ ត្រូវបានរៀបចំឡើងស្របតាមនិងប្រទាក់ក្រឡាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាឆ្នាំ២០៣០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍ

ប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ដូចជាគោលនយោបាយជាតិដំឡូងមីឆ្នាំ២០២០-២០២៥ គោលនយោបាយស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយឆ្នាំ២០១៦-២០២៦ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥។

គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០នេះ ក៏ត្រូវបានរៀបចំដោយប្រកាន់យកនូវអភិក្រម២កម្រិតគឺ (១) កម្រិតសម្រាប់សន្តិសុខស្បៀង និង (២) កម្រិតសម្រាប់ការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម និងកិច្ចអន្តរាគមន៍ផ្នែកគោលនយោបាយ គឺប្រើប្រាស់អភិក្រមខ្សែច្រវាក់តម្លៃទាំងមូល។ ជាមួយគ្នានេះដែរ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ក៏នឹងត្រូវបានរៀបចំជាបន្តទៀត ដោយត្រូវបង្ហាញយ៉ាងលម្អិតនិងជាក់លាក់នូវសកម្មភាពគោលនយោបាយសម្រាប់អនុវត្ត។

យុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើគឺផ្តោតសំខាន់លើការរៀបចំនិងការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាក់លាក់មួយ ដោយផ្អែកលើយន្តការសហការជិតស្និទ្ធនិងសម្របសម្រួលដើម្បីធានាការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ ប្រកបដោយប្រសិទ្ធភាព។

ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០នេះ ត្រូវការថវិកាពីប្រភពសំខាន់បីគឺ ថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍ និងការវិនិយោគរបស់វិស័យឯកជន។ ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវបន្តដាក់ចេញនូវកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពអាទិភាពសំខាន់ៗ សំដៅធ្វើការវិភាជន៍ថវិកាជាតិនិងថវិកាដែលបានមកពីដៃគូអភិវឌ្ឍឱ្យបានសមស្រប ឆ្លើយតបទៅនឹងសូចនាករកំណត់ក្នុងគោលនយោបាយនេះ។ ជាមួយគ្នានេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធត្រូវបង្កើតគម្រោងលម្អិតដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ ផែនការរំកិលបីឆ្នាំ ដោយអនុលោមតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ប្រកបដោយជោគជ័យ ក៏នឹងអាស្រ័យលើស្ថានការណ៍ក្នុងតំបន់និងពិភពលោក ក៏ដូចជាសភាពការណ៍ក្នុងប្រទេស ដែលអាចជះឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលទៅលើដំណើរការនៃការធ្វើទំនើបកម្មកសិកម្ម ការប្រកួតប្រជែងកសិពាណិជ្ជកម្ម ផលិតភាពនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរីនិងកម្រិតនៃការវិនិយោគឯកជន។ ក្របខ័ណ្ឌនៃយន្តការពិនិត្យតាមដាននិងវាយតម្លៃនឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៅក្នុងកិច្ចការនេះ។

ការប្តេជ្ញាយ៉ាងមុតមាំក្នុងការសម្របសម្រួលនិងអនុវត្តគឺជាមូលដ្ឋាននៃជោគជ័យ ដោយត្រូវប្រែក្លាយផែនការសកម្មភាពជាលក្ខណៈគោលនយោបាយដែលមានក្នុងគោលនយោបាយនេះឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើននិងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍនិងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ចូលរួមអនុវត្តគោលនយោបាយនេះឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាពនិងមានប្រសិទ្ធភាពខ្ពស់។

## ១- សេចក្តីផ្តើម

### ១.១- ទិដ្ឋភាពរួម

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យកសិកម្ម គឺជាវិស័យនាំមុខមួយក្នុងចំណោមវិស័យដទៃទៀតដែលបានរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងការកាត់បន្ថយភាពក្រីក្រ។ វិស័យនេះក៏បានជួយផ្តល់ការងារនិងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ដែលមានជីវភាពរស់នៅពឹងអាស្រ័យលើការងារកសិកម្ម។ ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ដើម្បីពង្រឹងនូវបុរេលក្ខខណ្ឌចាំបាច់នានានិងបរិស្ថានគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់កម្ពុជា ក្នុងទិសដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ យុទ្ធសាស្ត្រចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាគឺផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើនផលិតភាពនិងភាពប្រកួតប្រជែង ដើម្បីធានាបាននូវសន្តិសុខស្បៀងនិងសុវត្ថិភាពស្បៀង និងជំរុញការនាំចេញផលិតផលកសិកម្ម ហើយផ្តល់នូវការផ្លាស់ប្តូររចនាសម្ព័ន្ធ ព្រមទាំងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។

នាពេលកន្លងមក កំណើននៃវិស័យកសិកម្មមានការប្រែប្រួលនិងមានពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ(របបទឹកភ្លៀង រាំងស្ងួត និងទឹកជំនន់)។ កំណើននៃវិស័យកសិកម្មមានប្រមាណ១,៧% នៅឆ្នាំ២០១៧ និង១,១% នៅឆ្នាំ២០១៨។ ចាប់ពីដើមឆ្នាំ២០២០ វិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក៏បានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ហើយក៏បានធ្វើឱ្យកំណើននៃវិស័យកសិកម្មមានក្នុងរង្វង់០,៥% (កំណើននេះត្រូវបានប៉ាន់ស្មានថានឹងកើនប្រហែល១,៤% នៅឆ្នាំ២០២១)។

អត្រាសមាសភាគចូលរួមចំណែកនៃវិស័យកសិកម្មបានថយចុះពី៣៣,៩% មកត្រឹម២០,៨% ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងនេះក្តី កំណើននៃតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្មក៏ជាទឡ្ហីករណ៍មួយបង្ហាញយ៉ាងច្បាស់លាស់ពីការរីកលូតលាស់នៃវិស័យកសិកម្មកម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សកន្លងទៅ។ ជាក់ស្តែង តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្មបានកើនឡើងពី១៥ ៩៣៨ពាន់លានរៀលនៅឆ្នាំ២០១០ ដល់២៣ ៦៣៩ពាន់លានរៀលនៅឆ្នាំ២០២០ ពោលគឺកើនឡើងប្រមាណជាង៤% ក្នុងមួយឆ្នាំ។ ការចូលរួមចំណែក(%)នៃអនុវិស័យកសិកម្មក្នុងវិស័យកសិកម្មរយៈពេល១០ឆ្នាំកន្លងទៅបាន

បង្ហាញថា ផលិតកម្មដំណាំបានចូលរួមចំណែកធំជាងគេគឺប្រមាណពី៥៨%ទៅ៥៩%នៃផលិតផលកសិកម្មសរុប។ ជាមួយគ្នានេះ ផលិតផលជលផលបានឈរនៅលំដាប់ទីពីរបន្ទាប់ពីដំណាំ គឺប្រមាណពី២២%ទៅ២៤% ផលិតផលសត្វមានក្នុងរង្វង់ជាង១១% និងព្រៃឈើមានក្នុងចន្លោះពី៦,៧%ទៅ៧%ប៉ុណ្ណោះ។

អត្រាពលកម្មកសិកម្មធៀបជាមួយនឹងកម្លាំងពលកម្មសរុបបានថយចុះពីរង្វង់៥៤% នៅឆ្នាំ២០១០ មកនៅត្រឹមតែប្រមាណ៣៥,៥%នៅឆ្នាំ២០២០នេះ និងប៉ាន់ស្មានធ្លាក់ចុះដល់ក្នុងរង្វង់ពី២៣%ទៅ២៥% នៅឆ្នាំ២០៣០ខាងមុខនេះ។ ពលកម្មកសិកម្មមាននិន្នាការថយចុះជាបន្តបន្ទាប់និងបានបង្កើនកាលានុវត្តភាពនៃការប្រើប្រាស់គ្រឿងយន្តកសិកម្មចូលមកជំនួសពលកម្មក្នុងផលិតកម្មកសិកម្ម ព្រមទាំងបានដោះស្រាយជាបណ្តើរៗនូវបញ្ហាកង្វះកម្លាំងពលកម្មកសិកម្មនេះ។ នាពេលបច្ចុប្បន្ននេះ ការប្រើប្រាស់គ្រឿងយន្តកសិកម្មក្នុងការរៀបចំដីស្រែមានប្រមាណជាង៩៨% និងការច្រូតកាត់ស្រូវដោយម៉ាស៊ីនច្រូតមានប្រមាណពី៧០%ទៅ៨០%។

ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩វិស័យដែលជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាសំខាន់ៗ ដូចជាសំណង់ វាយនភណ្ឌ និងទេសចរណ៍មានការធ្លាក់ចុះ កសិកម្មត្រូវបានវាយតម្លៃថាជាវិស័យមួយដែលមានភាពបន្ស៊ាំខ្ពស់ទៅនឹងវិបត្តិនេះ និងនៅមានសក្តានុពលធំធេងដែលកម្ពុជាអាចច្បាមយកផលប្រយោជន៍បន្ថែមទៀតសំដៅរួមចំណែកដល់ការស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩។

ទោះជាយ៉ាងនេះក្តី វិស័យនេះក៏នៅជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។ កំណើនផលិតភាពទាបនៅតែជាបញ្ហាសំខាន់ ដែលនឹងត្រូវផ្តោតលើការបង្កើននូវការផ្គត់ផ្គង់ពូជសុទ្ធ ការជំរុញឱ្យអនុវត្តបច្ចេកទេសសមស្រប និងពង្រីកប្រព័ន្ធស្រោចស្រពកសិកម្មឱ្យបានគ្រប់គ្រាន់។ បន្ថែមលើសពីនេះ កម្ពុជានៅមានតម្រូវការបង្កើនវិនិយោគលើការកែច្នៃ ដោយត្រូវបន្តដោះស្រាយបញ្ហាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនីនិងឡូជីស្ទិក ព្រមទាំងការធានាឱ្យបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមក្នុងខ្សែច្រវាក់ផលិតកម្មកែច្នៃ។ បច្ចុប្បន្ននេះ ផលិតផលកសិកម្មកម្ពុជាមានប្រមាណតែ១០%ប៉ុណ្ណោះ ដែលត្រូវបានកែច្នៃជាផលិតផលពាក់កណ្តាលសម្រេចនិងផលិតផលសម្រេច (ពោតក្រហមមានប្រមាណ៣៧% ស្រូវមាន១៧% ស្វាយមាន១៤% ដំឡូងមីមាន៨% និងគ្រាប់ស្វាយចន្ទីមានត្រឹមតែ៣%ប៉ុណ្ណោះ)។ ជាមួយគ្នានេះដែរ ផលិតផលកសិកម្មរបស់កម្ពុជាដែលនាំចេញភាគច្រើនទៅប្រទេសជិតខាង មានលក្ខណៈក្រៅផ្លូវការនិងមិនទាន់កែច្នៃ។ ម្យ៉ាងវិញទៀត សក្តានុពលនៃវិស័យកសិកម្មកម្ពុជាដែលនៅមាន ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរតាមរយៈកំណើនតម្រូវការក្នុងស្រុកនៃផលិតផលសំខាន់ៗ ដូចជាបន្លែ ត្រី សាច់ជាដើម ពិសេសសាច់ជ្រូកដែលកម្ពុជាមិនទាន់បានផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នៅឡើយ ដែលជាហេតុត្រូវនាំចូលពីប្រទេសជិតខាងដើម្បីបំពេញកង្វះខាតទាំងនេះ។

## ១.២- វឌ្ឍនភាពនិងបញ្ហាប្រឈមនៃអនុវិស័យ

### ១.២.១- អនុវិស័យដំណាំ

ផលិតផលស្រូវបានកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណ៣,១% ក្នុងរយៈពេល១០ឆ្នាំកន្លងមក (៨,២លានតោននៅឆ្នាំ២០១០ ដល់១០,៨លានតោននៅឆ្នាំ២០១៩ និង១២,២១លានតោននៅឆ្នាំ២០២១)។ អតិរេកស្រូវក៏បានកើនគួរឱ្យកត់សម្គាល់ផងដែរ គឺបានកើនពី៣,៩លានតោននាឆ្នាំ២០១០ ដល់៥,៧៥ លានតោននាឆ្នាំ២០១៩ និង៦,៩លានតោននាឆ្នាំ២០២១។ ទិន្នផលស្រូវបានកើនពី២ ៩៧០គ.ក្រ.ក្នុងមួយ ហ.ត.នៅឆ្នាំ២០១០ ដល់៣ ៤៩០គ.ក្រ.ក្នុងមួយហ.ត.នៅឆ្នាំ២០២១។ កំណើនជាមធ្យមប្រចាំឆ្នាំនៃផ្ទៃដី ដាំដុះដំណាំស្រូវមានប្រមាណ២,៤%(ដែលភាគច្រើនគឺកើនដោយសារការធ្វើប្រពលវប្បកម្ម) កំណើន ផ្ទៃដីប្រមូលផលមាន២,២% និងទិន្នផលមធ្យមប្រចាំឆ្នាំកើនប្រមាណជាង២%។

ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ផលិតកម្មដំណាំស្រូវបានប្រែប្រួលទៅតាមឆ្នាំនីមួយៗ។ ផលិតកម្ម ដំណាំស្រូវសម្រេចបានកំណើន៥,៧២%នៅឆ្នាំ២០០៩ កើនឡើងដល់៨,៧៥%នៅឆ្នាំ២០១០ និង៥,៨៣% នៅឆ្នាំ២០១២។ ស្ថានភាពអាក្រក់នៃគ្រោះរាំងស្ងួតបានធ្វើឱ្យផលិតកម្មដំណាំស្រូវធ្លាក់ចុះនៅចន្លោះឆ្នាំ ២០១៣និងឆ្នាំ២០១៥។ នៅឆ្នាំ២០១៦ ទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អទូទាំងប្រទេស បានធ្វើឱ្យផលិតកម្ម ដំណាំស្រូវសម្រេចបាន៦,៦%។ នៅឆ្នាំ២០១៧ កំណើននេះបានធ្លាក់ចុះបន្តិចវិញ ដោយសម្រេចបាន ៥,៦៩% និង៣,៣៥%នៅឆ្នាំ២០១៨។ នៅឆ្នាំ២០២១ កំណើនផលិតកម្មដំណាំស្រូវសម្រេចបាន១១,៦%។ ជាការសង្កេត កត្តាអាកាសធាតុពិតជាមានឥទ្ធិពលខ្លាំងទៅលើផលិតកម្មដំណាំស្រូវក៏ដូចជាដំណាំដទៃទៀត។ ការបង្កើនសមត្ថភាពស្រោចស្រពកសិកម្ម គឺជាទិសដៅគោលនយោបាយចម្បងមួយសម្រាប់រួមចំណែក ជំរុញកំណើនវិស័យកសិកម្ម។

បញ្ហាប្រឈមសំខាន់ៗក្នុងវិស័យស្រូវអង្ករកម្ពុជា រួមមាន(១) រោងម៉ាស៊ីនកិនស្រូវភាគច្រើនជួប នឹងកង្វះទុនសម្រាប់ប្រមូលទិញស្រូវក្នុងរដូវដែលប្រមូលផលច្រើន ដែលជាហេតុធ្វើឱ្យស្រូវមួយភាគធំ បានហូរចេញទៅប្រទេសជិតខាង (២) កង្វះការផ្គត់ផ្គង់ពូជសុទ្ធ ជាពិសេសពូជស្រូវក្រអូបដែលមានតម្លៃ ខ្ពស់ (៣) កង្វះទឹកសម្រាប់ស្រោចស្រពដំណាំស្រូវ ជាពិសេសនៅក្នុងរដូវប្រាំង ខណៈដែលកសិករភាគ ច្រើនពឹងផ្អែកលើទឹកភ្លៀងក្នុងរដូវវស្សា (៤) ភាពមានកម្រិតនៃការអនុវត្តបច្ចេកទេសដាំដុះប្រកបដោយ ភាតរបរិស្ថានរបស់កសិករ ដូចជាការរៀបចំដី ការប្រើប្រាស់ពូជ ជីគីមី និងថ្នាំសម្លាប់សត្វល្អិតជាដើម (៥) កាលវិភាគដាំដុះពុំទាន់ត្រូវបានកែប្រែឱ្យស្របតាមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ ដើម្បីបញ្ចៀស ហានិភ័យនៃគ្រោះរាំងស្ងួតនិងទឹកជំនន់ (៦) ផែនទីដាំដុះដំណាំពុំទាន់ត្រូវបានអភិវឌ្ឍឱ្យបានជាក់លាក់ ដើម្បីធានាបាននូវទិន្នផលនិងគុណភាព ដែលអាចប្រមូលផលបានតាមការរំពឹងទុកនិងក្នុងថ្លៃសមស្រប និង (៧) ការផ្សព្វផ្សាយកសិកម្មនៅមិនទាន់អនុវត្តបានទូលំទូលាយនៅឡើយ។

ជាមួយគ្នានេះដែរ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្មក៏មានការប្រែប្រួលទៅតាមឆ្នាំនីមួយៗ។ ផលិតផលដំណាំរួមផ្សំនិងឧស្សាហកម្មបានកើនពី៦,១៤លានតោនទៅឆ្នាំ២០១០ និងមានសន្ទុះកើនឡើងខ្លាំងចាប់ពីឆ្នាំ២០១៤ ពី១៤,៧២លានតោន ដល់១៦,៦៤លានតោននៅឆ្នាំ២០១៨ (កំណើនមធ្យមប្រចាំឆ្នាំប្រមាណជាង១៣% រយៈពេល១០ឆ្នាំកន្លងទៅ)។ ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្មសម្រេចបានកំណើន៥%នៅឆ្នាំ២០០៩ កើនឡើងដល់ជាង៩,៦%នៅឆ្នាំ២០១៥ និងបានធ្លាក់ចុះមកត្រឹម១,៤%នៅឆ្នាំ២០១៨ អាស្រ័យដោយបញ្ហាជំងឺម៉ូសាអ៊ិកបានវាយលុកខ្លាំងមកលើផលិតកម្មដំឡូងមី និងនៅឆ្នាំ២០២១ ផលិតកម្មដំណាំឧស្សាហកម្មបានកើនដល់ជាង១៩លានតោន។

ផលិតកម្មដំឡូងមីបានរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបប្រមាណពី៣% ទៅ៤% ក្នុងខ្សែច្រវាក់តម្លៃទាំងមូល។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ ផលិតកម្មដំឡូងមីសម្រេចបានប្រមាណ១៣លានតោនក្នុងមួយឆ្នាំនិងបានប្រើប្រាស់សម្រាប់ការកែច្នៃក្នុងស្រុកប្រហែល១៥% រីឯ៨៥%ទៀតត្រូវបាននាំចេញទៅបរទេស ពិសេសប្រទេសជិតខាង។ ក្នុងរយៈពេលមធ្យមនិងវែង តម្រូវការផលិតផលដែលធ្វើពីដំឡូងមីត្រូវបានព្យាករណ៍ថាមានការកើនឡើងខ្ពស់ ស្របពេលដែលប្រទេសមួយចំនួននឹងកាត់បន្ថយការដាំដុះ ដែលនេះជាសក្តានុពលសម្រាប់កម្ពុជាក្នុងការជំរុញការកែច្នៃដំឡូងមី សំដៅបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី សក្តានុពលនេះនឹងមិនអាចទាញយកប្រយោជន៍បានអស់នោះទេ ដោយសារបញ្ហាប្រឈមជាលក្ខណៈរចនាសម្ព័ន្ធនិងការសម្របសម្រួលស្ថាប័ន ដូចជា(១) អស្ថិរភាពនៃការផ្គត់ផ្គង់ដំឡូងមីឱ្យបានទៀងទាត់ ដែលជាហេតុធ្វើឱ្យខ្សែច្រវាក់ផលិតកម្មកែច្នៃរបស់រោងចក្រត្រូវនៅទំនេររហូតដល់៤ទៅ៦ខែក្នុងមួយឆ្នាំ (២) កង្វះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ មានឡសម្ងួត ឃ្លាំងស្តុកដំឡូងមីនៅតាមតំបន់និងសហគមន៍ ដែលជាហេតុធ្វើឱ្យកសិករនិងអាជីវករត្រូវលក់ចំណិតដំឡូងមីទៅប្រទេសជិតខាង (៣) ថ្លៃដើមផលិតកម្មសម្រាប់កែច្នៃនៅមានកម្រិតខ្ពស់ (៤) ភាពមានកម្រិតនៃកិច្ចសម្រួលកសិធុរកិច្ចនៃផលិតផលដំឡូងមី (៥) កង្វះខាតពូជដែលមានគុណភាព (៦) កង្វះខាតការណែនាំបច្ចេកទេសនិងការតម្រង់ទិសកសិករដើម្បីអាចចំណាយទុនតិច ទទួលទិន្នផល និងគុណភាពខ្ពស់ (៧) ការគិតគូរជំរុញការបង្កើតសហគមន៍ដាំដំឡូងមីដើម្បីងាយណែនាំលើការប្រើប្រាស់ពូជ បច្ចេកទេស ជី និងបំពាក់គ្រឿងម៉ាស៊ីនសមស្របជាដើម។

ផលិតកម្មស្វាយចន្ទីក៏ត្រូវបានចាត់ទុកថាជាដំណាំឧស្សាហកម្មដែលមានសក្តានុពលមួយសម្រាប់កម្ពុជា។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដោយសារតែទីផ្សារស្វាយចន្ទីមានភាពល្អប្រសើរ ការដាំដុះស្វាយចន្ទីមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងអត្រាកំណើនជាមធ្យមប្រមាណ២៤% ពោលគឺបានកើនពី៩៣ ៩៤៤តោនក្នុងឆ្នាំ២០១៥ ដល់២០៨ ៧៦៩តោននៅឆ្នាំ២០១៩។ ដោយសារតែលទ្ធភាពកែច្នៃក្នុងស្រុកនៅមានកម្រិត ផលិតផលស្វាយចន្ទីប្រមាណ៩៧% ត្រូវបាននាំចេញទៅប្រទេសជិតខាងដោយមិនទាន់កែច្នៃ។ បញ្ហាប្រឈមនៃការកែច្នៃគ្រាប់ស្វាយចន្ទីគឺបណ្តាលមកពីកត្តាមួយចំនួន រួមមាន(១) ក្រុមហ៊ុន

កែច្នៃជួបនូវកង្វះខាតទុនបង្វិលសម្រាប់ប្រមូលទិញគ្រាប់ស្វាយចន្ទីពីកសិករក្នុងរដូវប្រមូលផលច្រើន (២) ការចងក្រងកសិករដាំស្វាយចន្ទីជាក្រុមផលិតឬសហគមន៍កសិកម្មនៅមានចំនួនតិចតួចនៅឡើយ ដែលជាហេតុធ្វើឱ្យការផ្គត់ផ្គង់គ្រាប់ស្វាយចន្ទីមានលក្ខណៈរាយប៉ាយ ជាការលំបាកសម្រាប់ក្រុមហ៊ុនក្នុងការប្រមូលទិញ (៣) បច្ចេកទេសរបស់កសិករក្នុងការគ្រប់គ្រងជីជាតិ ការថែទាំដំណាំ និងការគ្រប់គ្រងកសិដ្ឋាននៅមានកម្រិត (៤) ថ្លៃដើមផលិតកម្មកែច្នៃខ្ពស់ (៥) ភាពមានកម្រិតនៃកិច្ចសម្រួលកសិធុរកិច្ច។

ផលិតកម្មដំណាំស្វាយមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១៩ ផ្ទៃដីដាំដុះស្វាយបានកើនឡើងដល់១២៤ ០០០ហ.ត. ធៀបនឹង២៤ ០០០ហ.ត. ក្នុងឆ្នាំ២០១០ និងមានផ្ទៃដីប្រមូលផលប្រមាណ៩១ ០០០ហ.ត. ដែលអាចប្រមូលផលបានចំនួន១,៤៤លានតោន។ ថ្វីត្បិតតែផលិតកម្មដំណាំស្វាយមានការកើនឡើងខ្លាំង ការកែច្នៃស្វាយនិងការនាំចេញផ្លែស្វាយស្រស់ផ្លូវការទៅកាន់ទីផ្សារអន្តរជាតិនៅមានចំនួនតិចតួចនៅឡើយ។ ក្នុងឆ្នាំ២០១៩ ការកែច្នៃនិងការនាំចេញផ្លែស្វាយស្រស់ផ្លូវការមានត្រឹមតែ៥%នៃផលិតផលស្វាយសរុប។ ករណីនេះបណ្តាលមកពីបញ្ហាប្រឈមមួយចំនួនក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ទាំងមូល ដូចជា(១) កង្វះបច្ចេកទេសក្នុងការជំរុញឱ្យដំណាំស្វាយផ្តល់ផលតាមពេលវេលាកំណត់ ការប្រើប្រាស់ធាតុចូលច្រើនខុសពីបច្ចេកទេសដែលធ្វើឱ្យថ្លៃដើមខ្ពស់ ប៉ុន្តែទទួលបានទិន្នផលទាប មិនអាចប្រកួតប្រជែងតម្លៃទីផ្សារបាន (២) អស្ថិរភាពនៃការផ្គត់ផ្គង់ស្វាយទៅក្រុមហ៊ុនកែច្នៃនិងនាំចេញ ដោយសារកង្វះការចងក្រងក្រុមផលិតឬសហគមន៍អ្នកដាំស្វាយនិងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម (៣) កង្វះអនុលោមភាពនៃលក្ខខណ្ឌស្តង់ដាអនាម័យនិងភូតគាមអនាម័យនិងលក្ខខណ្ឌផ្សេងៗទៀតដែលកំណត់ដោយប្រទេសបញ្ជាទិញ (៤) កង្វះម៉ាស៊ីនសម្លាប់សត្វល្អិតដែលមានក្នុងផ្លែស្វាយដែលជាហេតុធ្វើឱ្យស្វាយរបស់កម្ពុជាភាគច្រើនជួបការលំបាកក្នុងការនាំចេញទៅកាន់ទីផ្សារបរទេសបាន។

ផលិតកម្មដំណាំកៅស៊ូមានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ គឺបានកើនពី១៨១,៤៣ពាន់ហ.ត.នៅឆ្នាំ២០១០ ដល់៤០៥,៦៣ពាន់ហ.ត.នៅឆ្នាំ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ១៣,០៩%។ ផលិតផលកៅស៊ូសម្រេចបាន៤២,២៥ពាន់តោននៅឆ្នាំ២០១០ និងកើនដល់២៨៧,៦៣ពាន់តោននៅឆ្នាំ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ២២,៣៦%។ នៅឆ្នាំ២០២១ ផលិតផលកៅស៊ូសម្រេចបាន៣៦៨ពាន់តោន កើនឡើង៥,៤% ធៀបនឹងឆ្នាំ២០២០។ ការនាំចេញផលិតផលកៅស៊ូក៏មានការកើនឡើង ដោយទំហំនៃការនាំចេញបានកើនពី៤២ពាន់តោននៅឆ្នាំ២០១០ ដល់២៨២ពាន់តោននៅឆ្នាំ២០១៩ (កើនឡើង៧ដងក្នុងរយៈពេល១០ឆ្នាំកន្លងទៅ)។ នៅឆ្នាំ២០២១ ការនាំចេញផលិតផលកៅស៊ូសម្រេចបាន៣៦៦,៣ពាន់តោន កើនឡើង៨,៣% ធៀបនឹងឆ្នាំ២០២០។ ក្នុងឆ្នាំ២០១៩ តម្រូវការប្រើប្រាស់កៅស៊ូនៅលើពិភពលោកមាន១៣,៧០លានតោន (ការផ្គត់ផ្គង់មានចំនួន ១៣,៧៦លានតោន) និងនៅឆ្នាំ២០២៥ សង្ឃឹមថានឹងមានតម្រូវការកើនឡើងដល់ ១៧,៧លានតោន ហើយការផ្គត់ផ្គង់មានចំនួនប្រមាណ១៦,៩លានតោន។ បញ្ហាប្រឈមសំខាន់នៃផលិតកម្ម

កៅស៊ូនៅកម្ពុជា រួមមាន(១) ទិន្នផលកៅស៊ូមានកម្រិតទាប ដោយសារការប្រើប្រាស់រុក្ខសម្ភារៈមិនមានគុណភាព ការទទួលយកបច្ចេកទេសកៅស៊ូរបស់អ្នកដាំកៅស៊ូនៅមានកម្រិតទាប ការផ្សព្វផ្សាយមិនបានទូលំទូលាយ ព្រមទាំងការសិក្សាស្រាវជ្រាវផ្នែកកៅស៊ូមិនទាន់បានល្អប្រសើរ (២) ថ្លៃកៅស៊ូទាបដោយសារមិនមានទីផ្សារកៅស៊ូរបស់សហគមន៍ឬសមាគមអ្នកដាំកៅស៊ូ រោងចក្រកែច្នៃផលិផលសម្រេចធ្វើពីកៅស៊ូមានចំនួនតិចតួច ការនាំចេញកៅស៊ូភាគច្រើនមិនមានវិញ្ញាបនបត្របញ្ជាក់គុណភាព និងកៅស៊ូមិនទាន់កែច្នៃមួយចំនួនធំត្រូវបាននាំចេញក្រៅផ្លូវការទៅប្រទេសជិតខាង និង (៣) កង្វះពលកម្មក្នុងផលិតកម្មកៅស៊ូដែលបណ្តាលមកពីលក្ខខណ្ឌការងារមិនប្រសើរដូចវិស័យកម្មន្តសាលឬសេវាកម្មផ្សេងៗ និងប្រាក់ពលកម្មនៅមានកម្រិត។

ទោះជាយ៉ាងនេះក្តី ការនាំចេញសរុបនៃផលិតផលកសិកម្ម (ទិន្នន័យផ្លូវការដែលឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យភូតគាមអនាម័យ) បានកើនឡើងចាប់តាំងពីឆ្នាំ២០១៣ ដែលទំហំនៃការនាំចេញសម្រេចបានចំនួន៣,៦លានតោន ឬស្មើនឹងជាង១ពាន់លានដុល្លារអាមេរិក (ឆ្នាំ២០១២មានត្រឹមតែ៦៨០ពាន់តោន) និងនៅឆ្នាំ២០១៩ សម្រេចបានចំនួន៤,៨លានតោន ឬស្មើនឹងជិត១ ៥០០លានដុល្លារអាមេរិក (កើនឡើងប្រមាណ៣៣%)។ នៅឆ្នាំ២០២១ ការនាំចេញសរុបនៃផលិតផលកសិកម្មបានកើនដល់៧,៩៨លានតោន។

ការនាំចេញអង្ករជាផ្លូវការ(ទិន្នន័យអង្ករឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យភូតគាមអនាម័យ) បានកើនឡើងពី១០៥ពាន់តោន (ឬស្មើនឹង៦៣ពាន់ដុល្លារអាមេរិក) នៅឆ្នាំ២០១០ ដល់ប្រមាណជាង៦២០ពាន់តោន (ឬស្មើនឹង៤៤០លានដុល្លារអាមេរិក) នៅឆ្នាំ២០១៩ (កើនឡើង៦ដងក្នុងរយៈពេល១០ឆ្នាំកន្លងទៅ) និងនៅឆ្នាំ២០២១ ការនាំចេញអង្ករជាផ្លូវការសម្រេចបាន៦១៧ពាន់តោន។ ការនាំចេញស្រូវក្រៅផ្លូវការទៅប្រទេសជិតខាងត្រូវបានប៉ាន់ស្មានថាមានចំនួនជាង២លានតោនក្នុងមួយឆ្នាំៗ។

### ១.២.២- អនុវិស័យផលិតកម្មសត្វ

ផលិតកម្មសត្វក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីនៅមានបញ្ហាមួយចំនួនត្រូវដោះស្រាយក៏ដោយ។ ជាទូទៅ ការចិញ្ចឹមសត្វរបស់ប្រជាកសិករជាលក្ខណៈគ្រួសារ និងការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានកំណើនប្រមាណ៥,៩៣% ជាមធ្យមប្រចាំឆ្នាំ ក្នុងនោះការចិញ្ចឹមគោមានការថយចុះ២,៤៣% ការចិញ្ចឹមក្របីថយចុះ៤,៨% ការចិញ្ចឹមជ្រូកកើន០,៧៩% និងការចិញ្ចឹមបក្សី (មាន់និងទា) កើនឡើង៧,១៤% ជាមធ្យមក្នុងមួយឆ្នាំ។ ការចិញ្ចឹមសត្វរបស់ប្រជាកសិករជាលក្ខណៈគ្រួសារ និងការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មបានកើនពីជាង២៧លានក្បាលនៅឆ្នាំ២០១០ ដល់ជាង៤៥,៨៥លានក្បាលនៅឆ្នាំ២០១៩ (បើគិតជាទំហំទឹកប្រាក់គឺបានកើនពី១ ៤៥៨លានដុល្លារ ដល់១ ៨២៧លានដុល្លារ)។ នៅឆ្នាំ២០២១ ផលិតកម្មសត្វទូទាំងប្រទេសបានកើនដល់៥៩,៩៦លានក្បាល។

ជាការកត់សម្គាល់ ការចិញ្ចឹមគោរបស់ប្រជាកសិករជាលក្ខណៈគ្រួសារបានធ្លាក់ចុះជាមធ្យមប្រមាណ ២,៤៧% ក្នុងមួយឆ្នាំ(ឆ្នាំ២០១០ មានចំនួនជាង៣,៤៨លានក្បាល និងនៅឆ្នាំ២០១៩ មានត្រឹមតែចំនួន ២,៧៧លានក្បាល) ដោយសារកង្វះកម្លាំងពលកម្មថៃទាំនៅជនបទ ជាមួយនឹងការផ្លាស់ប្តូរវិធីយាបថកសិករ ក្នុងការបន្ថយការចិញ្ចឹមគោក្របីសម្រាប់ជាកម្លាំងអូសទាញ និងម៉្យាងទៀតសេវាកម្មភ្ជួររាស់ដោយគ្រឿង យន្តកសិកម្មបានរីកចម្រើនជួយជំនួសឱ្យកម្លាំងពលកម្មដែលខ្វះខាត។

ចំពោះការចិញ្ចឹមសត្វជ្រូករបស់កសិករគ្រួសារនិងកសិដ្ឋានជាលក្ខណៈពាណិជ្ជកម្ម នៅមិនទាន់ មានការរីកចម្រើនខ្លាំងនៅឡើយ(ឆ្នាំ២០១០ ចិញ្ចឹមបានចំនួន២,២លានក្បាល កើនដល់៣លានក្បាលនៅ ឆ្នាំ២០១៧ និងបានថយមកត្រឹម២,១៨លានក្បាលនៅឆ្នាំ២០១៩)។ កំណើនយឺតនៃផលិតកម្មជ្រូកនេះគឺ អាស្រ័យដោយថ្លៃដើមផលិតកម្មមានតម្លៃខ្ពស់ ពិបាកប្រកួតប្រជែងជាមួយនឹងជ្រូកដែលនាំចូលពីប្រទេស ជិតខាង និងម៉្យាងទៀតកត្តាជំងឺសត្វ (ប៉េស្តជ្រូកអាហ្វ្រិកនិងជំងឺផ្សេងៗទៀត) បានកើតមានឡើងនាពេល កន្លងមក ដែលជាកត្តារាំងស្ទះដល់ការចិញ្ចឹមសត្វជ្រូកនៅកម្ពុជា។ ការចិញ្ចឹមបក្សី (ពិសេសមាន់ ទា) មាន សន្ទុះរីកចម្រើនខ្លាំងគួរជាទីមោទនៈ ទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារនិងជាកសិដ្ឋានចិញ្ចឹមជាលក្ខណៈ ពាណិជ្ជកម្មគឺបានកើនពី២០,៨លានក្បាលនៅឆ្នាំ២០១០ ដល់៤០,៣លានក្បាលនៅឆ្នាំ២០១៩ (ឬកើនពី ១០៩លានដុល្លារ ដល់៤០៤លានដុល្លារ)។

ជាការកត់សម្គាល់រួម សមាមាត្រ(%)នៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារបាននិងកំពុងបន្តធ្លាក់ ចុះក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គឺបានថយចុះពី៨០% នៅឆ្នាំ២០១៥ មកត្រឹម៦៥% នៅឆ្នាំ២០២០។ ផ្ទុយមកវិញ សមាមាត្រនៃការចិញ្ចឹមសត្វដោយកសិដ្ឋានជាលក្ខណៈពាណិជ្ជកម្មបានកើនដល់៣៥% នៅ ឆ្នាំ២០២០នេះ។ ជាក់ស្តែង ចំនួនកសិដ្ឋានចិញ្ចឹមសត្វគ្រប់ប្រភេទបានកើនពី១ ០៩០កន្លែងនៅឆ្នាំ២០១៧ ដល់១ ២៩៣កន្លែងនាឆ្នាំ២០២០។

ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមសំខាន់នៃផលិតកម្មសត្វនៅកម្ពុជាគឺ (១) ថ្លៃដើមផលិតកម្មនៅ ខ្ពស់នៅឡើយ ពិសេសថ្លៃចំណាយលើចំណីសត្វ (ប្រមាណ៧០%នៃចំណាយសរុប) ថ្នាំបង្ការនិងព្យាបាលសត្វ ដែលជាហេតុនាំឱ្យមានការលំបាកក្នុងការប្រកួតប្រជែង (២) កង្វះពូជមាន់ ជ្រូក គោ ដែលមានគុណភាព បច្ចេកទេសផលិតនៅមានកម្រិត (៣) កង្វះដើមទុនសម្រាប់ពង្រីកការចិញ្ចឹមសត្វ និង (៤) ជំងឺឆ្លងសត្វនិង ជំងឺស៊ូណូស (៥) កង្វះការផ្សព្វផ្សាយជំរុញការលើកទឹកចិត្តឱ្យកសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បី បង្កើនចំណូលគ្រួសារ (៦) កង្វះខាតការផ្គត់ផ្គង់ចំណីសត្វ ដែលមានគុណភាពខ្ពស់ និងថ្លៃសមរម្យពីរោង ចក្រក្នុងស្រុកឬដោយជំរុញឱ្យកសិករចេះផលិតចំណីដោយខ្លួនឯង។

### ១.២.៣- អនុវិស័យជលផល

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលត្រូវបានបន្តអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះបានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ ទិសស្លោក **"សហគមន៍នេសាទគ្មានបទល្មើស"** បាននិងកំពុងខិតខំអនុវត្តក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។ ក្នុងការចូលរួមចំណែកអនុវត្តការកែទម្រង់ ច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផលត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។ វិសោធនកម្មនៃច្បាប់នេះ គឺជារបត់ថ្មីមួយនៃការកែទម្រង់វិស័យជលផលឱ្យស្របតាមតួនាទីភារកិច្ចនិងតម្រូវការជាក់ស្តែងនៃសង្គមកម្ពុជាបច្ចុប្បន្ន។ បន្ថែមលើសពីនេះ ច្បាប់ស្តីពីជលផលថ្មីកំពុងត្រូវបានរៀបចំតាក់តែងសម្រាប់បម្រើឱ្យការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផលនេះឱ្យមានលក្ខណៈបរិយាបន្ននិងនិរន្តរភាព។

ក្នុងរយៈពេល១០ឆ្នាំកន្លងទៅ បរិមាណផលនេសាទសរុប (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) បានកើនឡើងគួរឱ្យកត់សម្គាល់ គឺបានកើនប្រមាណជាង៥%ជាមធ្យមក្នុងមួយឆ្នាំៗ ពោលកើនពី៥៥០ពាន់តោននៅឆ្នាំ២០១០ ដល់៨៥៦,៤ពាន់តោននៅឆ្នាំ២០២១។ ផលនេសាទទឹកសាបកើនពី៤០៥ពាន់តោននៅឆ្នាំ២០១០ ដល់៤៧៩ពាន់តោននៅឆ្នាំ២០១៩ (+១,៩% ជាមធ្យមប្រចាំឆ្នាំ)។ បរិមាណផលនេសាទសមុទ្របានកើនឡើងដូចគ្នាពី៨៥ពាន់តោន ដល់ជាង១២២ពាន់តោន ពីឆ្នាំ២០១០ និងឆ្នាំ២០១៩ (កើនប្រមាណ៤,១%ជាមធ្យមប្រចាំឆ្នាំ)។ ផលវារីវប្បកម្មបានកើនឡើងពី៦០ពាន់តោន ដល់ជាង៣០៧ពាន់តោន ក្នុងចន្លោះឆ្នាំ២០១០ និង២០១៩ (+១៩,៩%ជាមធ្យមប្រចាំឆ្នាំ)។

ជាមួយនឹងវឌ្ឍនភាពនេះ វិស័យនេះនៅជួបបញ្ហាប្រឈមមួយចំនួន រួមមាន(១) បទល្មើសនេសាទនៅបន្តកើតមាន ទោះបីវិធានការបង្ក្រាបត្រូវបានអនុវត្តក៏ដោយ (២) សមត្ថភាពសហគមន៍នេសាទនៅមានកម្រិត ហើយជីវភាពរស់នៅពឹងអាស្រ័យតែលើរបរនេសាទ និងកំណើនតម្រូវការផល ផលិតផលជលផល (៣) ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រជលផលនិងវារីវប្បកម្មនៅមានកម្រិត (៤) ដីព្រៃលិចទឹកដែលជាជម្រកត្រីពងកូនមួយចំនួនត្រូវបានបាត់បង់ (៥) កង្វះបច្ចេកទេសក្នុងការចិញ្ចឹមត្រី កង្វះពូជត្រីដែលមានគុណភាពខ្ពស់ (៦) កង្វះទីផ្សារដែលមានស្ថិរភាពសម្រាប់ឱ្យកសិករយកត្រីទៅលក់ដោយផ្ទាល់ ពោលគឺកសិករភាគច្រើនពឹងផ្អែកស្ទើរទាំងស្រុងលើអាជីវករប្រមូលទិញត្រី ដែលជាទូទៅរងនូវហានិភ័យនៃការប្រែប្រួលថ្លៃ (៧) កង្វះដើមទុនក្នុងការពង្រីកកសិដ្ឋានចិញ្ចឹមត្រី (៨) កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រោយពេលប្រមូលផល ដូចជាកង្វះផែត្រីនៅតាមសហគមន៍ មជ្ឈមណ្ឌលប្រមូលផ្តុំនិងចែកចាយត្រី ផ្លូវតភ្ជាប់ទៅកាន់កសិដ្ឋានវារីវប្បកម្ម បណ្តាញអគ្គិសនី សិប្បកម្មកែច្នៃត្រី ទឹកស្អាតជាដើម (៩) កង្វះតំបន់

ពិសេសសម្រាប់វារីវប្បកម្មក្នុងទន្លេទ្រាយធំ ដែលកៀកនឹងប្រភពទឹកនិងទីផ្សារ និង (១០) ការអភិរក្សនិងការជំរុញផ្តល់ពូជត្រីធម្មជាតិដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅពុំទាន់ត្រូវបានអនុវត្តគ្រប់គ្រាន់នៅឡើយ។

### ១.២.៤- អនុវិស័យព្រៃឈើ

កម្មវិធីកែទម្រង់វិស័យព្រៃឈើ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្ត ដោយបានខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹងដើម្បីបង្ក្រាបបទល្មើសព្រៃឈើនិងសត្វព្រៃ ព្រមទាំងសម្រេចបាននូវលទ្ធផលធំៗជាច្រើន។ វិស័យព្រៃឈើបានរួមចំណែកយ៉ាងសំខាន់នៅក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍដោយចីរភាព ពិសេសវិស័យនេះបានជួយលើកកម្ពស់ជីវភាព ផ្តល់មុខរបរ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុវត្ត ដោយបានបង្កើនការត្រួតពិនិត្យការអនុវត្តនិងបានដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានអនុវត្តកិច្ចសន្យាវិនិយោគ។

ជាការកែទម្រង់មួយថ្មីទៀត រាជរដ្ឋាភិបាលបានសម្រេចផ្ទេរព្រៃការពារនិងអភិរក្សព្រៃឈើ១៣កន្លែង តំបន់ព្រៃផ្តល់ផល៥កន្លែងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនទៅក្រសួងបរិស្ថានគ្រប់គ្រងនិងផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ច៧៣កន្លែងពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់គ្រងបន្ត។

ការដាំឈើឡើងវិញត្រូវបានយកចិត្តទុកដាក់អនុវត្តខ្ពស់ ដោយសហការក្នុងភាពជាដៃគូជាមួយវិស័យឯកជន។ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ដាំឈើលើដីព្រៃរេចរឹល ដោយសហការដៃគូជាមួយវិស័យឯកជន។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីវិធានព្រៃឯកជន ដែលប្រកាសនេះមានគោលបំណងកំណត់នូវវិធានព្រៃឯកជន សម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើតនិងអភិវឌ្ឍន៍ព្រៃឯកជន។ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ការដាំឈើឡើងវិញ ទាំងរដ្ឋនិងវិស័យឯកជន សម្រេចបានសរុបចំនួន៤០៨ពាន់ហ.ត.។

ការបង្កើតសហគមន៍ព្រៃឈើមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។ គិតត្រឹមឆ្នាំ២០២១ សហគមន៍ព្រៃឈើសរុបចំនួន៦៤៣សហគមន៍ត្រូវបានបង្កើត ដែលគ្របដណ្តប់លើផ្ទៃដី៥២២ ២៧៣ហ.ត. និងមានសហគមន៍ព្រៃឈើចំនួន៥៣៦សហគមន៍ត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការ។ ជាមួយគ្នានេះ កិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៤៩ ត្រូវបានរៀបចំនិងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៦ ក៏ត្រូវបានអនុម័ត។

ជាការកត់សម្គាល់ កំណើនប្រជាជននាំឱ្យមានតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើ។ ការប្រែក្លាយដីព្រៃឈើជាដីកសិកម្មនិងដីលំនៅឋានមានការកើនឡើង និងមានសម្ពាធលើព្រៃធម្មជាតិនិងប្រព័ន្ធ

មជ្ឈដ្ឋានជីវៈចម្រុះ។ ការរំលោភកាន់កាប់ដីព្រៃឈើដោយខុសច្បាប់នៅតែជាបញ្ហាចោទ។ ទោះបីជាមានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានដាក់ចេញឱ្យអនុវត្តជាបន្តបន្ទាប់ ក៏ការរំលោភកាន់កាប់ដីព្រៃឈើនៅកើតមានមិនឈប់ឈរច្រើនរូបភាព។ ម៉្យាងវិញទៀត សហគមន៍ព្រៃឈើដែលបានបង្កើតរួចហើយក៏នៅមានកង្វះការគាំទ្រ ទាំងផ្នែកបច្ចេកទេសនិងធនធានថវិកា ដើម្បីឱ្យដំណើរការគ្រប់គ្រងរបស់សហគមន៍មានប្រសិទ្ធភាពខ្ពស់។

## ១.៣. និន្នាការសាកលនិងតំបន់ក្នុងវិស័យកសិកម្ម

ចំនួនប្រជាជនក្នុងពិភពលោកនឹងកើនឡើងពីប្រមាណជិត៨ពាន់លាននាក់នាពេលបច្ចុប្បន្ន ដល់ ៨,៥ពាន់លាននាក់នៅឆ្នាំ២០៣០។ ចំនួនប្រជាជននេះត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ជិត១០ពាន់លាននាក់នៅឆ្នាំ២០៥០ ដែលនឹងធ្វើឱ្យមានកំណើននៃតម្រូវការស្បៀងអាហារជាចាំបាច់ (FAO, ២០១៧)។ ប្រជាជនក្នុងពិភពលោកនឹងត្រូវបានផ្គត់ផ្គង់ចំណីអាហារកាន់តែប្រសើរជាងមុននៅឆ្នាំ២០៣០។

ជារួម នៅឆ្នាំ២០៣០ តម្រូវការទីផ្សារ ការផ្គត់ផ្គង់ក្នុងតំបន់ និងពិភពលោកនឹងកើនឡើង ហើយនឹងផ្តល់កាលានុវត្តភាពមួយសម្រាប់កម្ពុជាក្នុងការផលិតនូវផលិតផលកសិកម្ម ដើម្បីបំពេញសេចក្តីត្រូវការទាំងនោះ។ ទីផ្សារនៃបណ្តាប្រទេសអឺរ៉ុប ឥណ្ឌា អាស៊ាន ចិន កូរ៉េ និងជប៉ុន គឺជាគោលដៅយុទ្ធសាស្ត្រនៃការនាំចេញផលិតផលកសិកម្មកម្ពុជា ពិសេសអង្ករ កៅស៊ូ ដំឡូងមី ពោត ស្វាយចន្ទី ម្រេច ស្វាយ ចេក និងផលិតផលកសិឧស្សាហកម្មមួយចំនួនទៀត។ ក្នុងន័យនេះ កម្ពុជាត្រូវតែចាប់ច្បាមយកនូវឱកាសនេះ ដើម្បីផលិតនិងផ្គត់ផ្គង់ផលិតផលកសិកម្មមានគុណភាពខ្ពស់ សុវត្ថិភាព ស្របតាមស្តង់ដាតំបន់និងអន្តរជាតិ។

ទម្រង់នៃការប្រើប្រាស់ម្ហូបអាហារបានផ្លាស់ប្តូរទៅជាអាហារដែលមានគុណភាពខ្ពស់និងថ្លៃជាងមុនដូចជាសាច់ ផលិតផលទឹកដោះគោជាដើម។ ប្រទេសកំពុងអភិវឌ្ឍនឹងពឹងផ្អែកកាន់តែខ្លាំងឡើងលើការនាំចូលធញ្ញជាតិ ផ្លែឈើ បន្លែ សាច់ និងទឹកដោះគោ។ ការផលិតនូវផលិតផលទាំងនេះនឹងមិនដើរទាន់តម្រូវការទេ។ នៅត្រឹមឆ្នាំ២០៣០ ប្រទេសទាំងនេះអាចផលិតបានតែ៨៦%នៃតម្រូវការធញ្ញជាតិក្នុងប្រទេសរបស់ខ្លួនប៉ុណ្ណោះ។ ជាមួយគ្នានេះ ក៏មានការកើនឡើងនូវចំណូលចិត្តចំពោះអាហារដែលមានគុណភាពល្អសម្រាប់សុខភាពនិងអាហារដែលមានមុខងារបន្ថែម ដែលអាហារទាំងនេះកំពុងជំរុញឱ្យមានតម្រូវការវត្ថុធាតុដើមចំណីអាហារដែលមានគុណភាពខ្ពស់។ ការអនុលោមពាក់ព័ន្ធនឹងស្តង់ដាអនាម័យនិងភូតគាមអនាម័យនឹងត្រូវរឹតបន្តឹងក្នុងគោលដៅសុខុមាលភាពប្រជាជន។

ការពង្រីកផ្ទៃដីកសិកម្មសម្រាប់ផលិតកម្មស្បៀងអាហារនឹងមានសភាពយឺតជាងកាលពីអតីតកាល។ ក្នុងរយៈពេល៣០ឆ្នាំខាងមុខ ប្រទេសកំពុងអភិវឌ្ឍនឹងត្រូវការ១២០លានហ.ត.បន្ថែមទៀតសម្រាប់ដាំដំណាំ។ ប្រការនេះនឹងត្រូវការការពង្រីកផ្ទៃដីស្រោចស្រពពី២០២លានហ.ត.នាពេលបច្ចុប្បន្នដល់២៤២លានហ.ត.

នៅត្រឹមឆ្នាំ២០៣០ ដែលបង្កើនសម្ពាធលើធនធានទឹកដែលកំពុងខ្វះខាតនៅតាមតំបន់ជាច្រើននៃពិភពលោក (FAO)។

បច្ចេកវិទ្យាទំនើបនិងសមស្របថ្មីៗនឹងត្រូវបានបង្កើតឡើង ដែលនាំមកនូវកំណើនផលិតកម្មប្រកបដោយនិរន្តរភាព ព្រមទាំងជួយការពារបរិស្ថានកាន់តែប្រសើរឡើង។ ការបង្កើនផលិតភាពកសិកម្មនឹងមិនត្រូវពឹងផ្អែកតែលើការប្រើប្រាស់ធាតុចូលកាន់តែច្រើនទៀតនោះទេ ពោលគឺកំណើននេះអាចដើរទន្ទឹមគ្នានឹងប្រព័ន្ធផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាពនិងភាតរបរិស្ថាន។ ម៉្យាងវិញទៀត ពាណិជ្ជកម្មអេឡិចត្រូនិកសម្រាប់ផលិតផលកសិកម្មនិងផលិតផលម្ហូបអាហារដែលមានលក្ខណៈស្តង់ដារអនាម័យខ្ពស់កាន់តែមានសារៈសំខាន់ខ្លាំងឡើងនិងត្រូវផលិតឱ្យស្របទៅតាមតម្រូវការប្រើប្រាស់នាពេលខាងមុខ។

ដោយឡែក ការរាំងស្ទះដល់ដំណើរការក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ បានធ្វើឱ្យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភស្ថិតក្នុងសភាពគួរឱ្យបារម្ភ។ តាមរបាយការណ៍របស់កម្មវិធីស្បៀងអាហារពិភពលោក(WFP) មនុស្សប្រមាណ១៣០លាននាក់និងជីវភាពរស់នៅរបស់ពួកគេនៅក្នុងប្រទេស៥៥កំពុងមានហានិភ័យរួចទៅហើយនៅឆ្នាំ២០២០ (Anthem, ២០២០)។ ការវាយតម្លៃដោយអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ក្នុងឆ្នាំ២០២០ បង្ហាញថា វិបត្តិជំងឺកូវីដ-១៩ អាចធ្វើឱ្យប្រជាជនចំនួនពី៨៣ទៅ១៣២លាននាក់បន្ថែមទៀតធ្លាក់ចូលក្នុងក្រុមមនុស្សដែលខ្វះអាហារូបត្ថម្ភក្នុងឆ្នាំ២០២០ ដោយសារការបាត់បង់កំណើនផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក។

ជាមួយគ្នានេះដែរ បណ្តាប្រទេសអាស៊ានបានបង្កើតផែនទីបង្ហាញផ្លូវមួយ ហើយបានដាក់ចេញនូវចក្ខុវិស័យឆ្នាំ២០២៥ របស់ខ្លួនសម្រាប់បណ្តារដ្ឋជាសមាជិកអាស៊ានអនុវត្តឱ្យមានលក្ខណៈសមាហរណកម្មភាពប្រកួតប្រជែងនិងនវានុវត្តន៍។ នៅក្នុងន័យនេះ បណ្តាប្រទេសអាស៊ានបានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងកម្លាំងដល់អ្នកផលិតនិងជាពិសេសសហគមន៍កសិកម្ម ដើម្បីដោះស្រាយបញ្ហាប្រឈមនានា និងបង្កើនតួនាទីផលិតនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្មជាសាកល (លេខាធិការដ្ឋានអាស៊ានឆ្នាំ២០១៨)។

## ១.៤- និន្នាការក្នុងប្រទេសនៃវិស័យកសិកម្ម

ប្រជាជននិងវិស័យកសិកម្ម : យោងតាមជំរឿនឆ្នាំ២០១៩ ប្រទេសកម្ពុជាមានប្រជាជនចំនួន១៦ ៥២៤ ៤៨២នាក់ ក្នុងនោះមានជនចំណាកស្រុកចំនួន១ ២៣៥ ៩៩៣នាក់ដែលកំពុងធ្វើការនៅបរទេស។ ប្រជាជនកម្ពុជាប្រមាណ៧៦,២%រស់នៅតាមទីជនបទនិងពឹងផ្អែកលើសកម្មភាពចិញ្ចឹមជីវិតក្នុងវិស័យកសិកម្ម។ នៅឆ្នាំ២០២០ ពលកម្មកសិកម្មមានចំនួនជាង៣៥,៥% ធៀបនឹងពលកម្មសរុប។ ជាការកត់សម្គាល់ គឺមានការថយចុះលើការពឹងផ្អែកប្រាក់ចំណូលកសិកម្មក្នុងតំបន់ជនបទនិងបន្តការធ្វើចំណាកស្រុកទៅរកការងារដែលមានប្រាក់កម្រៃល្អប្រសើរ។ ប្រជាជនកម្ពុជារំពឹងថានឹងកើនដល់ជាង២០លាននាក់នៅត្រឹមឆ្នាំ២០៣០ និង២៥លាននាក់នៅត្រឹមឆ្នាំ២០៥០។ ប្រឈមនឹងស្ថានភាពនេះ ការអភិវឌ្ឍវិស័យ

អប់រំកសិកម្ម ការបង្កើនចំណេះដឹង និងជំនាញបច្ចេកទេស នឹងរួមចំណែកដល់ការអភិវឌ្ឍវិស័យកសិកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ ខណៈដែលកម្រិតជីវភាពកាន់តែប្រសើរឡើង ប្រជាជនកម្ពុជាភាគច្រើននឹងកាន់តែយកចិត្តទុកដាក់ខ្លាំងឡើងលើគុណភាពនិងសុវត្ថិភាពក្នុងការប្រើប្រាស់ចំណីអាហារ ជាពិសេសបន្លែ ផ្លែឈើ និងត្រីសាច់។

ការប្រែប្រួលអាកាសធាតុ : ការប្រែប្រួលអាកាសធាតុនិងលក្ខណៈជាវដ្តនៃព្រឹត្តិការណ៍ចរន្តអែលនីញ្ញូនិងឡានីញ៉ា កំពុងបង្កផលប៉ះពាល់(រយៈពេលខ្លីនិងវែង) លើវិស័យកសិកម្ម ដែលនាំមកនូវផលវិបាកគួរឱ្យកត់សម្គាល់ ជាពិសេសសម្រាប់អ្នកផលិតក្រីក្រមិនសូវមានធនធាននិងមិនមានជម្រើសផ្សេងទៀតក្នុងការប្រកបរបរចិញ្ចឹមជីវិត។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះនៅលើពិភពលោក ដោយការប្រែប្រួលអាកាសធាតុ(ភាគច្រើនដោយសារតែកសិករជាច្រើនប្រកបរបរកសិកម្មពឹងផ្អែកលើទឹកភ្លៀង)។ តាមការព្យាករការប្រែប្រួលអាកាសធាតុអាចកាត់បន្ថយផ.ស.ស.ប្រមាណ២,៥% នៅឆ្នាំ២០៣០ និង៩,៨%នៅឆ្នាំ២០៥០។ និន្នាការនេះនឹងអាចពន្យារពេលដល់ការសម្រេចគោលដៅរបស់កម្ពុជាដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ (UNDP, ២០១៨)។

ផលិតភាពកសិកម្មនិងនវានុវត្តន៍ : ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំពុងមានការផ្លាស់ប្តូររបស់ប្រជាជនដែលមានចំនួនកាន់តែកើនឡើង វិស័យកសិកម្មនឹងត្រូវការផលិតកម្មទ្វេដងនៅឆ្នាំ២០៥០ (FAO, ២០១៧)។ យុទ្ធសាស្ត្រប្រកបដោយនវានុវត្តន៍ថ្មីៗសម្រាប់វិស័យនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន ការបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងកំណើនសេដ្ឋកិច្ច។ កិច្ចខិតខំប្រឹងប្រែងដើម្បីទាក់ទាញអ្នកវិនិយោគនិងអ្នកច្នៃប្រឌិតថ្មីៗត្រូវតែខិតខំជាបន្តទៀត ដើម្បីបង្កើតគំនិតថ្មីៗជាប្រយោជន៍ដល់វិស័យនេះនិងសម្រាប់កសិករនៅជនបទក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍គួរត្រូវបានពង្រឹងបន្ថែម ដើម្បីស្វែងរកដំណោះស្រាយឱ្យបានសមស្របនឹងប្រព័ន្ធផលិតកម្មបែបប្រពលវប្បកម្មនិងមាននិរន្តរភាព។

ការប្រើប្រាស់ធនធានធម្មជាតិ : ប្រជាជនក្រីក្រនៅជនបទក្នុងប្រទេសកម្ពុជាមួយភាគធំបានពឹងផ្អែកលើធនធានធម្មជាតិ ដូចជាដីធ្លី ត្រី ព្រៃឈើ ទន្លេជាដើម សម្រាប់ជីវភាពរស់នៅរបស់ពួកគាត់។ លទ្ធភាពប្រើប្រាស់ធនធានទាំងនេះនៅមានកម្រិត ហើយកាន់តែមានការរឹតត្បិតបន្ថែមទៀត ដោយសារការបង្កើនការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ដីធ្លីនិងការការពារបរិស្ថាន។ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថាក្នុងចំណោមសហគ្រាសកសិកម្មសរុបចំនួន១,៧លានគ្រួសារនៅកម្ពុជាមាន ១១% ចូលរួមសកម្មភាពប្រមូលឈើសម្រាប់ថាមពល។ ទន្ទឹមនឹងនេះ កំណើនប្រជាជននិងនគរូបនីយកម្មកំពុងជះឥទ្ធិពលទៅលើប្រព័ន្ធអេកូឡូស៊ីរបស់ប្រទេសកម្ពុជា ដែលបណ្តាលឱ្យមានការរិចរិលបរិស្ថាននិងការបាត់បង់សេវាកម្មអេកូឡូស៊ីនិងជីវៈចម្រុះ។ ការប្រើប្រាស់ដី ទឹក ព្រៃឈើ និងអនុផលផ្សេងៗប្រកប

ដោយនិរន្តរភាព គឺតម្រូវឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ដើម្បីការរីកលូតលាស់សេដ្ឋកិច្ច និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។

ការផ្លាស់ប្តូរប្រព័ន្ធស្បៀងអាហារ ៖ ប្រព័ន្ធស្បៀងអាហារគ្របដណ្តប់គ្រប់តួអង្គ កិច្ចដំណើរការផលិតកម្ម ធនធាននៃខ្សែច្រវាក់តម្លៃស្បៀងអាហារ និងការប្រើប្រាស់ស្បៀងអាហារ ហើយស្ថិតនៅក្នុងលំនឹងប្រកបដោយជីវជាតិជាមួយនឹងប្រព័ន្ធដទៃទៀត។ នាពេលខាងមុខគឺចាំបាច់ត្រូវស្វែងយល់អំពីបញ្ហាប្រឈមនិងគម្លាតនៅក្នុងប្រព័ន្ធស្បៀងអាហារបច្ចុប្បន្ន ដើម្បីប្រែក្លាយប្រព័ន្ធនេះឆ្ពោះទៅរកប្រព័ន្ធមួយដែលមាននិរន្តរភាពនិងបរិយាបន្ន ដែលផលិតអាហារមានគុណភាពសម្រាប់សុខភាពនិងមានជីវជាតិ ព្រមទាំងមានប្រាក់ចំណេញផងដែរ។ កិច្ចពិភាក្សាថ្នាក់ជាតិស្តីពីប្រព័ន្ធស្បៀងអាហារឆ្នាំ២០២១ បានរៀបចំឱ្យមានផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ ដែលមានចក្ខុវិស័យច្បាស់លាស់ ដើម្បីធ្វើឱ្យប្រព័ន្ធស្បៀងកាន់តែមានភាពរឹងមាំ ផ្តល់នូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់មនុស្សគ្រប់រូប ដោយគិតគូរពីចីរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

តម្រូវការនិងការប្រើប្រាស់ស្បៀងអាហារ ៖ លទ្ធភាពទទួលបានអង្ករដែលជាអាហារចម្បងសម្រាប់ប្រជាជនកម្ពុជាគឺគ្រប់គ្រាន់នៅថ្នាក់ជាតិ។ តម្រូវការក្នុងស្រុកនឹងមានការផ្លាស់ប្តូរទាំងប្រភេទនិងគុណភាពនៃអាហារ ជាមួយនឹងការវិវឌ្ឍរបស់កម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យម។ ជាការសង្កេត គឺមានការកើនឡើងនូវការទទួលទានសាច់ច្រើននៅតាមតំបន់ប្រជុំជន។ ទន្ទឹមនឹងកំណើនប្រាក់ចំណូល ប្រជាជនមានឱកាសដើម្បីបង្កើនគុណភាពអាហារនិងមានការយល់ដឹងអំពីសុវត្ថិភាពចំណីអាហារ សម្រាប់ទាំងអ្នកប្រើប្រាស់និងអ្នកផលិត និងមានតម្រូវការរបបអាហារដែលល្អសម្រាប់សុខភាព។

វិសមភាពយេនឌ័រក្នុងវិស័យកសិកម្ម ៖ ជាទូទៅស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់និងចែកចាយស្បៀងអាហារសម្រាប់គ្រួសារ។ ទោះយ៉ាងនេះក៏ដោយ ស្ត្រីបានរួមចំណែកចំនួន៤៨%នៃកម្លាំងពលកម្មសរុបនៅកម្ពុជា ហើយប្រមាណ៣០%នៃស្ត្រីទាំងនេះបម្រើការងារក្នុងវិស័យកសិកម្ម(ADB, ២០២០)។ ស្ត្រីកម្ពុជាប្រឈមនឹងបញ្ហាធំៗជាច្រើនទាក់ទងនឹងការបង្កើនឱកាសសេដ្ឋកិច្ចរបស់ពួកគាត់( លទ្ធភាពប្រើប្រាស់ដីធ្លី បច្ចេកវិទ្យាព័ត៌មាន និងសេវាបច្ចេកទេសកសិកម្ម)។ ការដោះស្រាយវិសមភាពយេនឌ័រតាមរយៈការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនិងការទទួលបានអត្ថប្រយោជន៍ពីអន្តរាគមន៍កសិកម្ម ក៏ដូចជាការធ្វើសេចក្តីសម្រេចចិត្តនានា គឺជាគន្លឹះក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។ ម៉្យាងវិញទៀត ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបច្ចេកទេស គឺជាគន្លឹះក្នុងការបង្កើនឱកាសសម្រាប់ស្ត្រីទាំងក្នុងនិងក្រៅវិស័យកសិកម្ម។

## ១.៥- បញ្ហាប្រឈមក្នុងវិស័យកសិកម្ម

ផលិតភាពកសិកម្ម : ផលិតភាពកសិកម្មនៅកម្ពុជាមានកម្រិតទាប បើធៀបជាមួយប្រទេសដទៃទៀតក្នុងតំបន់ ក្នុងនោះការធ្វើទំនើបកម្មប្រព័ន្ធផលិតកម្មទើបតែចាប់ផ្ដើមនិងក្នុងល្បឿនយឺត។ យន្តកម្មកសិកម្មនិងការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប តម្រូវឱ្យមានការលើកកម្ពស់ការយល់ដឹង ការបង្កើនសមត្ថភាពបច្ចេកទេសនិងការទទួលបានឥណទាននៅក្នុងវិស័យនេះទាំងមូល។ សមត្ថភាពក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្មទំនើបនិងសមស្របមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ ជាពិសេសការប្រើប្រាស់ធាតុចូលកសិកម្ម(គ្រាប់ពូជ ជី និងថ្នាំកសិកម្ម) គ្រឿងយន្តកសិកម្មនិងបច្ចេកវិទ្យាក្រោយប្រមូលផលជាដើម។ កត្តាទាំងនេះរួមចំណែកដល់ថ្លៃដើមផលិតកម្មខ្ពស់និងផលិតភាពទាប ដែលបណ្ដាលឱ្យមានការលំបាកក្នុងការប្រកួតប្រជែង។ ទន្ទឹមនឹងនេះដែរ ប្រព័ន្ធផលិតកម្មកសិកម្មចាំបាច់ត្រូវសម្របតាមនិន្នាការកើនឡើងនៃការធ្វើចំណាកស្រុកពីជនបទមកទីប្រជុំជន។ កសិករដែលមានដីកសិកម្មតិចតួច មិនអាចទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ចវិមាត្រនិងអាចប្រកួតប្រជែងបានទេ ដោយសារតែការចំណាយលើផលិតកម្មខ្ពស់ ដែលនាំឱ្យមានប្រាក់ចំណេញទាប។

ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងនិរន្តរភាព : វិស័យកសិកម្មនៅប្រទេសកម្ពុជាងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុនិងវដ្ដនៃព្រឹត្តិការណ៍ចរន្តអែលនីណូនិងឡានីញ៉ា។ ប្រព័ន្ធធារាសាស្ត្រនៅមានកំណត់និងប្រព័ន្ធផលិតកម្មមានភាពធន់ទៅនឹងអាកាសធាតុនៅមានកម្រិតទាប។ បច្ចេកវិទ្យានិងនវានុវត្តន៍ដែលធន់នឹងអាកាសធាតុ គឺជាមធ្យោបាយចាំបាច់ដើម្បីធានានិរន្តរភាពយូរអង្វែងសម្រាប់វិស័យនេះ។ លើសពីនេះទៀត វិស័យនេះត្រូវការនូវការគាំទ្រនិងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីឆ្ពោះទៅរកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការចាប់យកឧស្ម័នកាបូនិច ព្រមទាំងការសម្រេចបាននូវគោលដៅនៃរបាយការណ៍បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ។ ដើម្បីសម្រេចបានគោលដៅនេះគឺចាំបាច់ ត្រូវដោះស្រាយបញ្ហានៃការថយចុះគម្របព្រៃឈើក្នុងប្រទេស រួមទាំងព្រៃកោងកាងនិងព្រៃលិចទឹក ដែលភាគច្រើនបង្កឡើងដោយការពង្រីកដីកសិកម្ម នគរូបនីយកម្ម និងការកាប់ឈើខុសច្បាប់។ អាងទន្លេសាបងាយរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ ដោយសារការផ្លាស់ប្ដូររបបទឹកភ្លៀង ដែលអាចជះឥទ្ធិពលដល់ប្រព័ន្ធចរន្តទឹកជំនន់របស់បឹងនិងធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល។

រចនាសម្ព័ន្ធនៃផលិតកម្មកសិកម្ម : វិស័យកសិកម្មនៅតែមានកសិករខ្នាតតូចភាគច្រើន។ ការធ្វើកសិកម្មជាលក្ខណៈគ្រួសារខ្នាតតូចមួយភាគធំគឺធ្វើផលិតកម្មកសិកម្មដោយពឹងផ្អែកលើទឹកភ្លៀងនិងនៅប្រើប្រាស់ធាតុចូល ឧបករណ៍កសិកម្មទំនើបតិចតួច។ ប្រមាណជាងមួយភាគបីនៃកសិករខ្នាតតូចនៅតែជាអ្នកផលិតដើម្បីចិញ្ចឹមជីវិត(មិនមែនផលិតដើម្បីពាណិជ្ជកម្ម)។ ការចងក្រងកសិករឱ្យនៅក្នុងបណ្ដុំអាជីវកម្ម

ផលិតកម្មឬសហគមន៍កសិកម្មគឺជាគន្លឹះសម្រាប់ជួយដោះស្រាយ ដើម្បីបង្កើនបាននូវបច្ចេកទេសផលិត ទទួលបានឥណទានសមរម្យនិងពិសេសការអនុវត្តនូវផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ការរំខាននៃទីផ្សារការងារ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ : ការណ៍នេះកំពុងបន្តកើតមានដែលចាំបាច់ត្រូវចាត់វិធានការអន្តរាគមន៍នានា ដើម្បីរក្សាការងារនៅក្នុងវិស័យកសិកម្មឱ្យមាននិរន្តរភាព និងកាត់បន្ថយជាបណ្តើរៗនូវការធ្វើចំណាកស្រុក។ ក្នុងរយៈពេលមធ្យម បញ្ហានេះនឹងតម្រូវឱ្យមានដំណោះស្រាយជាក់លាក់សម្រាប់ប្រព័ន្ធកសិកម្មខ្នាតតូច ក្នុងការគាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាកសិករដែលផ្អែកលើកសិកម្ម។ ទោះយ៉ាងណាក៏ដោយ អាស្រ័យលើល្បឿននៃការងើបឡើងវិញនៃសេដ្ឋកិច្ចក្នុងស្រុក តំបន់ និងអន្តរជាតិ ស្ថានភាពនេះអាចផ្លាស់ប្តូរបានល្អប្រសើរឡើងវិញ ដែលទាមទារឱ្យមានការឆ្លើយតបប្រកបដោយភាពបត់បែននិងឆាប់រហ័សទាក់ទងនឹងវិធានការគាំទ្រវិស័យកសិកម្ម។

ការកែលម្អការគ្រប់គ្រងទឹក : បញ្ហានេះនៅតែជាកត្តាគន្លឹះក្នុងការបង្កើនផលិតភាពកសិកម្ម។ ការផ្គត់ផ្គង់ទឹកកសិកម្មនៅតែមិនទាន់គ្រប់តាមតម្រូវការរបស់កសិករ ជាពិសេសនៅក្នុងអំឡុងពេលរាំងស្ងួត ទោះបីជាប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធបង្ហូរដោះទឹកត្រូវបានកសាងនិងមានលទ្ធភាពអាចផ្គត់ផ្គង់ទឹកដល់តំបន់សក្តានុពលកសិកម្មមួយចំនួនធំហើយក៏ដោយ។ ការបង្កើតក្របខ័ណ្ឌនៃការគ្រប់គ្រងទឹកកសិកម្មប្រកបដោយនិរន្តរភាព ដែលជំរុញការកសាងប្រព័ន្ធធារាសាស្ត្រទំនើបនឹងធ្វើឱ្យផលិតកម្មប្រសើរឡើងនិងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ការវិនិយោគលើការពង្រីកប្រព័ន្ធធារាសាស្ត្រ ការកសាងសមត្ថភាពរបស់ប្រតិបត្តិករគ្រប់គ្រងនិងប្រើប្រាស់ប្រព័ន្ធនេះ ទាមទារនូវការយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀត។

ការបង្កើនតម្លៃបន្ថែមដល់វិស័យកសិកម្ម : ផលិតផលកសិកម្មមានប្រមាណ១០%នៃផលិតផលសរុបរបស់កម្ពុជាត្រូវបានកែច្នៃនៅក្នុងប្រទេស ហើយការនាំចេញផលិតផលកសិកម្មកែច្នៃមានតែប្រមាណ៥% ប៉ុណ្ណោះនៃការនាំចេញផលិតផលសរុបក្នុងឆ្នាំ២០២០ ដែលកត្តានេះគឺបានបង្ហាញពីសក្តានុពលដ៏សំខាន់សម្រាប់ការវិនិយោគលើការបង្កើនតម្លៃបន្ថែម ការកែច្នៃ ការបង្កើតការងារ និងកំណើនក្នុងវិស័យកសិកម្ម។

ការអភិវឌ្ឍផ្នែកកសិឧស្សាហកម្ម : ផ្នែកនេះគឺជាគន្លឹះក្នុងការបង្កើនតម្លៃបន្ថែមលើមុខទំនិញកសិកម្មតាមរយៈការធានាគុណភាពនិងសុវត្ថិភាពនៃផលិតផលម្ហូបអាហារនិងការកែច្នៃសម្រាប់នាំចេញ។ ក្នុងន័យនេះ ការបង្កើតបណ្តុំកសិឧស្សាហកម្មឬការបង្កើតតំបន់សេដ្ឋកិច្ចពិសេសសម្រាប់កែច្នៃនិងនាំចេញផលិតផលកសិកម្មនិងការសម្របសម្រួលភាពជាដៃគូរវាងវិស័យសាធារណៈ វិស័យឯកជន និងអ្នកផលិត នឹងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍផ្នែកនេះនាពេលខាងមុខ។

លទ្ធភាពទទួលបានធាតុចូលដែលមានគុណភាពក្នុងតម្លៃសមរម្យ : កង្វះគ្រាប់ពូជដែលមានស្តង់ដាគុណភាពគឺជាឧបសគ្គដ៏ធ្ងន់ធ្ងរ ហើយធាតុចូលកសិកម្មភាគច្រើនត្រូវបាននាំចូលពីបរទេសនិងមានតម្លៃខ្ពស់។

ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតកាន់តែច្រើនសម្រាប់ការដាំបន្លែនិងស្រូវប្រាំងកំពុងធ្វើឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងសម្រាប់អ្នកទទួលទាន។

ការដឹកជញ្ជូននិងឡូហ្ស៊ីស្ទិក: ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់ទី៩៤ ក្នុងចំណោមប្រទេសចំនួន ១៣៧ លើភាពប្រកួតប្រជែងផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៧-២០១៨ នៅក្នុងសន្ទស្សន៍នៃភាពប្រកួតប្រជែងរបស់វេទិកាសេដ្ឋកិច្ចពិភពលោក។ ទោះយ៉ាងណាក៏ដោយ ការចំណាយលើការដឹកជញ្ជូន ការស្តុកទុកនៅកម្ពុជាគឺខ្ពស់ជាងការចំណាយនៅក្នុងប្រទេសជិតខាង។ ការណ៍នេះគឺបានធ្វើឱ្យថ្លៃដើមនាំចេញខ្ពស់និងពិបាកប្រជែងទីផ្សារ។

ការទទួលបានហិរញ្ញវត្ថុនិងឥណទានរបស់កសិករខ្នាតតូច: ការផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ក្រុមងាយរងគ្រោះនិងអ្នកក្រីក្រនៅជនបទដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអ្នកផ្តល់ប្រាក់កម្ចីឯកជន គឺជាកិច្ចការដែលត្រូវយកចិត្តទុកដាក់។ ការផ្តល់ប្រាក់កម្ចីដល់វិស័យកសិកម្មនិងជាពិសេសដល់កសិករខ្នាតតូចត្រូវបានគេចាត់ទុកថាមានហានិភ័យនិងមានអត្រាការប្រាក់ខ្ពស់ដែលដាក់បន្ទុកធ្ងន់ធ្ងរដល់អ្នកខ្ចី។ ក្នុងស្ថានភាពបច្ចុប្បន្ននៃជំងឺកូវីដ-១៩ បានធ្វើឱ្យការខ្ចីប្រាក់កាន់តែជួបការលំបាក។

សមត្ថភាពសហគមន៍កសិកម្មនៅមានកម្រិត : សហគមន៍កសិកម្មដែលបានបង្កើតឡើងដើម្បីផ្តល់អំណាចនិងបង្កើនជំនាញ ពង្រឹងការចូលទីផ្សារ បង្កើនអំណាចចរចា និងលទ្ធភាពទទួលសេវាកម្មបច្ចេកទេសនិងឥណទានគឺនៅមានចំនួនតិចនៅឡើយ។

ការអភិវឌ្ឍសមត្ថភាពនិងកំណែទម្រង់ស្ថាប័ន : ការអភិវឌ្ឍធនធានមនុស្សនិងការបង្កើនសមត្ថភាពបច្ចេកទេសកសិកម្មនៅថ្នាក់មូលដ្ឋាននៅមានកម្រិត និងត្រូវតែពន្លឿនកិច្ចការនេះជាចាំបាច់ ដើម្បីពង្រឹងលទ្ធភាពក្នុងការផ្តល់សេវាបច្ចេកទេសកសិកម្មដែលមានគុណភាពខ្ពស់ ដល់កសិករនៅតាមជនបទប្រកបដោយប្រសិទ្ធភាព។ ការកែទម្រង់ស្ថាប័នមានសារៈសំខាន់សម្រាប់នាំមកនូវការគ្រប់គ្រងវិស័យកសិកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីពង្រឹងប្រសិទ្ធភាពនៃសេវាបច្ចេកទេសនិងអភិបាលកិច្ច។ ជាមួយគ្នានេះ ការស្រាវជ្រាវនិងអភិវឌ្ឍន៍គឺចាំបាច់ត្រូវបន្តពង្រឹងនិងពង្រីកបន្ថែមទៀត។ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងបច្ចេកវិទ្យាឌីជីថលកសិកម្មនៅមានកម្រិត ដែលនឹងត្រូវយកចិត្តទុកដាក់ជំរុញឱ្យអនុវត្តនាពេលខាងមុខជាចាំបាច់។

ផ្អែកលើនិន្នាការនិងបញ្ហាប្រឈមសាកល ក៏ដូចជាក្នុងតំបន់ វិធានការគោលនយោបាយសម្រាប់អន្តរាគមន៍ ដូចដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនេះ និងជាឧបករណ៍ដើម្បីដោះស្រាយបញ្ហាដែលបានកើតមាននៅក្នុងវិស័យកសិកម្មទាំងមូល។ ការដាក់ចេញនូវគោលនយោបាយរយៈពេល១០ឆ្នាំនេះ គឺដើម្បីបង្កើនកំណើនវិស័យកសិកម្មដែលមានភាពប្រកួតប្រជែងខ្ពស់ មានបរិយាបន្ន និងនិរន្តរភាព។ គោលនយោបាយនេះ គឺដើម្បីគាំទ្រដល់បេសកកម្មក្នុងការបង្កើនការផ្តល់នូវផលិតផលស្បៀង

អាហារដែលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាហារូបត្ថម្ភ រួមជាមួយនឹងការពារធនធានដី ទឹក ព្រៃឈើ និងជលផលប្រកបដោយចីរភាព។

## ២- ចក្ខុវិស័យ

គោលនយោបាយនេះ មានចក្ខុវិស័យកសាង*កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាបន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនឹងធ្វើឱ្យកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា*។

## ៣- គោលបំណង

គោលនយោបាយនេះមានគោលបំណង*ជំរុញកំណើនកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្ម ពិពិធកម្មកសិកម្ម និងជំរុញនីជីថល្លូបនីយកម្ម ប្រកបដោយភាពប្រកួតប្រជែង បរិយាបន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល*។

## ៤- គោលដៅ

**(ទី១) ការធ្វើទំនើបកម្មនិងពាណិជ្ជូបនីយកម្មខ្សែច្រវាក់តម្លៃកសិកម្ម**

**(ទី២) ការវិនិយោគសាធារណៈនិងឯកជនក្នុងវិស័យកសិកម្ម**

**(ទី៣) កំណើនប្រកបដោយចីរភាពនិងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង**

**(ទី៤) ការកែទម្រង់ស្ថាប័ននិងបញ្ហាអន្តរវិស័យ។**

ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយនេះ គោលដៅជាយុទ្ធសាស្ត្រចំនួន៤ ត្រូវបានកំណត់និងដាក់ឱ្យអនុវត្តរួមមាន៖

### គោលដៅយុទ្ធសាស្ត្រទី១ : "លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង"

គោលដៅយុទ្ធសាស្ត្រនេះគឺផ្តោតលើការយកចិត្តទុកដាក់ជាសំខាន់ ដល់ការបង្កើនផលិតភាពពិពិធកម្ម និងការបង្កើនប្រាក់ចំណេញនៅក្នុងខ្សែច្រវាក់តម្លៃដំណាំស្រូវ ដំណាំរដូវ កៅស៊ូ និងដំណាំកសិឧស្សាហកម្មផ្សេងទៀត ក៏ដូចជាផលិតកម្មសត្វនិងកសិផលដទៃទៀតដែលមានសក្តានុពលសេដ្ឋកិច្ចបម្រើឱ្យការនាំចេញ ព្រមទាំងជំរុញការអភិវឌ្ឍកសិឧស្សាហកម្មដែលអាចធ្វើទៅបាននិងមានផលចំណេញខ្ពស់ ជាពិសេសការ

អនុវត្តអភិក្រមភាពជាដៃគូរវាង "វិស័យសាធារណៈ ផ្នែកឯកជន អ្នកផលិត/ សហគមន៍កសិកម្ម(៤Ps)" សម្រាប់ការអភិវឌ្ឍផ្នែកកសិពាណិជ្ជកម្មឱ្យមានការប្រកួតប្រជែងខ្ពស់។ ជាមួយគ្នានេះ ត្រូវប្រើប្រាស់សក្ដានុពលនៃបច្ចេកវិទ្យាវៃឆ្លាតនិងឌីជីថលក្នុងផលិតកម្មប្រកបដោយនិរន្តរភាពនិងបង្កើនការអនុវត្តនូវវិធានការការពារដំណាំ អនាម័យនិងភូតគាមអនាម័យ និងការបើកទីផ្សារនាំចេញផលិតផលដែលមានគុណភាពខ្ពស់ប្រកបដោយប្រសិទ្ធភាព។

**គោលដៅយុទ្ធសាស្ត្រទី២ : "បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មនិងការសម្រួលកសិពាណិជ្ជកម្ម"**

គោលដៅយុទ្ធសាស្ត្រនេះគឺផ្ដោតការយកចិត្តទុកដាក់ជាសំខាន់លើការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រពកសិកម្ម ស្ថានីយបូមទឹកកសិកម្ម ការពង្រីកការតភ្ជាប់ផ្លូវទៅកសិដ្ឋាន ការផ្ដល់អគ្គិសនីដែលមានតម្លៃអនុគ្រោះដល់សហគមន៍កសិកម្ម ជំរុញការវិនិយោគវិស័យឯកជនក្នុងការផលិតនិងកែច្នៃផលិតផលកសិកម្ម លទ្ធភាពទទួលបានឥណទានជនបទ និងការសម្រួលកសិពាណិជ្ជកម្មឱ្យបានល្អប្រសើរ។

**គោលដៅយុទ្ធសាស្ត្រទី៣ : "បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព"**

គោលដៅយុទ្ធសាស្ត្រនេះគឺយកចិត្តទុកដាក់ខ្ពស់ចំពោះការគ្រប់គ្រងដីកសិកម្ម ទឹក ព្រៃឈើ អនុផលព្រៃឈើនិងសត្វព្រៃ ក៏ដូចជាធនធានជលផលប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។ បង្កើនភាពធន់នឹងអាកាសធាតុក្នុងប្រព័ន្ធផលិតកម្ម និងសម្រួលដល់ការផ្លាស់ប្ដូរប្រព័ន្ធស្បៀង ឆ្ពោះទៅរកការផ្គត់ផ្គង់ចំណីអាហារដែលមានតម្លៃសមរម្យ មានសុវត្ថិភាព និងមានជីវជាតិ។

**គោលដៅយុទ្ធសាស្ត្រទី៤ : "ពង្រឹងអភិបាលកិច្ចនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"**

គោលដៅយុទ្ធសាស្ត្រនេះគឺផ្ដោតលើការពង្រឹងការគ្រប់គ្រងស្ថាប័ន ការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនិងការអប់រំកសិកម្ម រួមទាំងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យទាំងមូល។ ការដឹកនាំលើការស្ដារស្ថានភាពឡើងវិញពីជំងឺកូវីដ-១៩ ហើយដកស្រង់យកមេរៀននិងបទពិសោធដែលទទួលបាននាពេលនេះយកទៅអនុវត្តគឺជាកិច្ចការចម្បង ដើម្បីឆ្លើយតបនឹងវិបត្តិដែលអាចកើតមាននាពេលអនាគត។

គោលដៅជាយុទ្ធសាស្ត្រនិងលទ្ធផលដែលត្រូវសម្រេចក្នុងវិស័យកសិកម្ម នឹងត្រូវបានបញ្ចូលទៅក្នុងសកម្មភាពគោលនយោបាយលម្អិតតាមអនុវិស័យនីមួយៗ នៅក្នុងកម្មវិធី/គម្រោងប្រតិបត្តិការជាក់លាក់ដែលនឹងត្រូវរៀបចំនៅក្នុងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០។

## ៥. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយ ក៏ដូចជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា វិធានការគោលនយោបាយជាយុទ្ធសាស្ត្រគន្លឹះសំខាន់ៗនឹងត្រូវដាក់ចេញសម្រាប់អនុវត្តពីឆ្នាំ២០២២ ដល់ឆ្នាំ២០៣០រួមមាន៖

### ផ្នែកទី១ : ការធ្វើទំនើបកម្មនិងពាណិជ្ជូបនីយកម្មខ្សែច្រវាក់តម្លៃកសិកម្ម

**គោលដៅយុទ្ធសាស្ត្រទី១ : "លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង"**

**ក.១. បង្កើនផលិតភាពនិងតម្លៃបន្ថែមនៃខ្សែច្រវាក់តម្លៃដំណាំ**

១.១. បង្កើនផលិតភាពដំណាំអាទិភាព (ស្រូវ ដំឡូងមី ពោត ស្វាយចន្ទី ចេក ស្វាយ រុក្ខជាតិលម្អ បន្លែ មៀន/គាងែន ម្រេច អំពៅ ទុរេន ដូង ម្នាស់ ស្រកានាគ ប៉ិរ លូ ដំឡូងជ្វា និងម្ទេស) តាមរយៈការគាំទ្របច្ចេកទេសកសិកម្មទំនើបដល់កសិករ/អ្នកផលិត និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម។

១.២. បង្កើនពិពិធកម្មក្នុងផលិតកម្មនិងកាត់បន្ថយហានិភ័យពីការដាំដំណាំតែមួយមុខនិងរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំនីមួយៗ ដោយប្រើអភិក្រមខ្សែច្រវាក់ផលិតកម្មកសិកម្ម។

១.៣. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រការផលិតនិងបង្កើនការធ្វើយន្តកម្មផលិតកម្មដំណាំ។

១.៤. លើកកម្ពស់ឧស្សាហកម្មគ្រាប់ពូជដំណាំនិងបង្កើនការគ្រប់គ្រងធាតុចូលកសិកម្ម។

១.៥. កែលម្អគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្មនិងកសិពាណិជ្ជកម្ម ព្រមទាំងរៀបចំស្តង់ដាផលិតផលកសិកម្មឱ្យបានសមស្រប។

១.៦. កំណត់តំបន់ដាំដុះនិងកសាងផែនទីដាំដុះដំណាំកសិកម្ម។

១.៧. ពង្រឹងការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម និងបង្កើនសមត្ថភាពពិសោធន៍កសិកម្ម។

១.៨. ពង្រឹងសេវាកម្មគាំទ្រនិងការអភិវឌ្ឍធនធានមនុស្សក្នុងផលិតកម្មដំណាំ។

**ក.២. បង្កើនផលិតភាពនិងតម្លៃបន្ថែមនៃខ្សែច្រវាក់តម្លៃកៅស៊ូ**

២.១. ពង្រឹងនិងកែលម្អខ្សែច្រវាក់តម្លៃផលិតកម្មកៅស៊ូ តាមរយៈការពង្រីកបច្ចេកទេសផលិតកម្មកៅស៊ូប្រកបដោយនិរន្តរភាព ពង្រឹងសហគមន៍កៅស៊ូគ្រួសារ និងអភិវឌ្ឍទីផ្សារកៅស៊ូ។

២.២- ពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដោយត្រូវបង្កើនបណ្តាញផ្ទេរបច្ចេកវិទ្យាដល់អ្នកផលិតកៅស៊ូ ដើម្បីបង្កើនគុណភាពនិងផលិតភាពកៅស៊ូ។

២.៣- លើកកម្ពស់ការវិនិយោគផ្ទាល់ពីបរទេសលើការអភិវឌ្ឍកៅស៊ូនិងធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍដើម្បីគាំទ្រផលិតកម្មនិងការអភិវឌ្ឍកៅស៊ូប្រកបដោយចីរភាព។

## ក.៣- បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មសត្វ

៣.១- ជំរុញការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ និងរៀបចំធ្វើបច្ចុប្បន្នភាពផែនការនេះសម្រាប់អនុវត្តរយៈពេល១០ឆ្នាំទៅមុខទៀត។

៣.២- លើកកម្ពស់ផលិតកម្មសត្វដែលមានភាពប្រកួតប្រជែងនិងបរិយាបន្ន(អនុវត្តការចិញ្ចឹមសត្វល្អ កែលម្អពូជសត្វ បច្ចេកទេស គុណភាព សុវត្ថិភាពចំណី ការបង្កាត់ពូជសត្វ ...)។

៣.៣- លើកកម្ពស់សុខភាពសត្វ សុខុមាលភាពសត្វ និងសុខភាពសាធារណៈ (ជីវសុវត្ថិភាព កាត់បន្ថយអត្រាឈឺស្លាប់សត្វ ផលិតវ៉ាក់សាំង បសុឱសថ ព្យាបាល អនាម័យសត្វ សាច់ និងផលិតផលសត្វ ពិឃាតសត្វដោយសមានធម៌ មន្ទីរពិសោធន៍វិនិច្ឆ័យជំងឺសត្វ ....)។

៣.៤- លើកកម្ពស់ការផ្សព្វផ្សាយលើការអនុវត្តបច្ចេកទេសនិងការបណ្តុះបណ្តាល ព្រមទាំងពង្រឹងការអនុវត្តច្បាប់ និងជំរុញការងារស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ។

៣.៥- លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន សមាគម/សហគមន៍ចិញ្ចឹមសត្វ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ។

៣.៦- សម្របសម្រួលការវិនិយោគឯកជនលើការចិញ្ចឹមសត្វ ការបង្កើតរោងចក្រផលិតចំណីសត្វ ផលិតវ៉ាក់សាំងនិងផលិតបសុឱសថ ព្រមទាំងការកែច្នៃសម្រាប់ការនាំចេញ។

៣.៧- បន្តជំរុញលើកទឹកចិត្តការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារតាមទីជនបទ ដែលជាប្រភពចំណូលបន្ថែមរបស់កសិករខ្នាតតូច រួមទាំងផ្តល់ធាតុចូលផលិតកម្មដែលមានផលវិជ្ជមានដល់ការចិញ្ចឹមសត្វ។

## ក.៤- លើកកម្ពស់ការអភិវឌ្ឍកសិឧស្សាហកម្មនិងកសិទេសចរណ៍

៤.១- ធ្វើឱ្យប្រសើរឡើងនិងទំនើបកម្មផ្នែកកសិឧស្សាហកម្ម ដោយត្រូវពង្រឹងសមត្ថភាពផលិតដល់សហគ្រាសធុនតូចនិងមធ្យម ឆ្លើយតបតាមស្តង់ដាគុណភាពនិងសុវត្ថិភាពចំណីអាហារ។

៤.២- សិក្សានិងបង្កើតសួនកសិឧស្សាហកម្មនៅកម្ពុជាសម្រាប់ប្រមូលផ្តុំសហគ្រាសកែច្នៃផលិតផលកសិកម្មដើម្បីផលិតបម្រើឱ្យការនាំចេញ។

៤.៣- លើកកម្ពស់កសិទេសចរណ៍ក្នុងខ្សែច្រវាក់ផលិតកម្មនៃវិស័យកសិកម្មនិងជំរុញការអភិវឌ្ឍខ្សែក្រវាត់បៃតង ដើម្បីផ្គត់ផ្គង់ផលិតផលកសិកម្មដល់សេវាកម្មនិងអាជីវកម្មទេសចរណ៍។

៤.៤- ពង្រឹងនិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលើគុណភាព សុវត្ថិភាពសម្រាប់ផល ផលិតផលកសិកម្មដោយអនុលោមតាមស្តង់ដាជាតិនិងអន្តរជាតិ។

៤.៥- ពង្រឹងនិងអភិវឌ្ឍប្រព័ន្ធទីផ្សារប្រកបដោយនិរន្តរភាព និងបរិយាបន្នសម្រាប់ផល ផលិតផលកសិកម្មតាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា។

## ក.៥- បង្កើនផលិតភាពតាមការអនុវត្តបច្ចេកវិទ្យាវៃឆ្លាតក្នុងខ្សែច្រវាក់តម្លៃកសិកម្ម

៥.១- ជំរុញការអនុវត្តបច្ចេកទេសកសិកម្មទំនើប(ប្រព័ន្ធដំណក់ទឹក ការគ្រប់គ្រងសត្វល្អិតចង្រៃ កសិដ្ឋានមានដំបូល/ សំណាញ់)។

៥.២- លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ សូឡាបូមទឹក ជំរុញសហគ្រាសកសិកម្ម ឱ្យប្រើបច្ចេកវិទ្យាកសិកម្មវៃឆ្លាត និងការកសាងនិងប្រើប្រាស់ឡជីវឧស្ម័ន។

៥.៣- លើកកម្ពស់និងអនុវត្តផលិតកម្មកសិកម្មសរីរាង្គ (CamOrganic) អនុវត្តកសិកម្មល្អ (CamGAP) និងកសិកម្មដែលវៃឆ្លាតនឹងអាកាសធាតុ ជាមួយនឹងការអនុវត្តនូវបច្ចេកវិទ្យាវៃឆ្លាតនិងទំនើប។

៥.៤- ពង្រឹងការផ្សព្វផ្សាយកសិកម្មដោយប្រើបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ទំនើបដើម្បី ផ្សព្វផ្សាយដល់កសិករទាំងអស់ ដោយប្រើប្រព័ន្ធដែលផ្អែកលើតម្រូវការនិងការគាំទ្រចំគោលដៅប្រកបដោយគុណភាពខ្ពស់។

៥.៥- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតនៅគ្រប់ដំណាក់កាលនៃផលិតកម្ម កសិកម្ម ពិសេសក្រោយពេលប្រមូលផល ដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និង ប្រសិទ្ធភាពខ្ពស់។

## ក.៦- បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃវារីវប្បកម្ម

៦.១- ពង្រឹងការងារស្រាវជ្រាវពូជ ពង្រីកផលិតកម្មពូជ ជំរុញបច្ចេកទេសចិញ្ចឹមទំនើប រួមទាំង ស្រាវជ្រាវកែលម្អពូជត្រីធម្មជាតិនិងអភិរក្សពូជត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដើម្បីបង្កាត់ពូជឱ្យបានកាន់តែច្រើន សម្រាប់ចែកចាយលែងក្នុងទន្លេ បឹង ស្រះធម្មជាតិ និងចែកជូនប្រជាពលរដ្ឋ ដើម្បីចិញ្ចឹមតាមបែបធម្មជាតិតាមវាលស្រែ។

៦.២- សិក្សាអំពីសក្តានុពលនៃទីតាំង ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវគាំទ្រ និងបរិស្ថានដែលអំណោយផលដើម្បីបង្កើតតំបន់វារីវប្បកម្ម។

៦.៣- ចងក្រងបណ្តុំវារីវប្បករទៅតាមតំបន់នីមួយៗ ដើម្បីបង្កើនសមត្ថភាពផលិតកម្ម ងាយស្រួលក្នុងការផ្តល់បច្ចេកទេស ឥណទាន និងទីផ្សារ។

៦.៤- រៀបចំផែនការផលិតកម្មនិងសកម្មភាពវារីវប្បកម្មជាក់លាក់ទៅតាមប្រភេទវារីសត្វ ព្រមទាំងរៀបចំបង្កើតបណ្តុំអាជីវករ/អ្នកប្រមូលទិញ និងភ្ជាប់ទៅកាន់ទីផ្សារតាមរយៈការអនុវត្តនូវយន្តការ "ផលិតកម្មវារីវប្បកម្មតាមកិច្ចសន្យា" រវាងបណ្តុំវារីវប្បករនិងបណ្តុំអាជីវករ។

៦.៥- សម្របសម្រួលដល់វារីវប្បករក្នុងការទទួលបាននូវតម្លៃអគ្គិសនីសមស្រប ដើម្បីជំរុញការធ្វើវារីវប្បកម្មនិងការបង្កើតរោងចក្រកែច្នៃផលវារីវប្បកម្មសម្រាប់នាំចេញ។

៦.៦- សម្របសម្រួលដល់វារីវប្បករក្នុងការទទួលបាននូវឥណទាន ដែលមានអត្រាការប្រាក់ទាបសមរម្យ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម។

៦.៧- ពិនិត្យលទ្ធភាពលើការលើកលែងឬព្យួរអាករលើតម្លៃបន្ថែមនិងពន្ធនាំចូលគ្រឿងម៉ាស៊ីនសម្ភារៈបរិក្ខារ និងឧបករណ៍ដែលបម្រើដល់ការជំរុញនិងអភិវឌ្ឍន៍វារីវប្បកម្ម។

៦.៨- សិក្សាលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់ការធ្វើវារីវប្បកម្មទឹកសាបនៅតាមតំបន់ដីសណ្តទន្លេមេគង្គកម្ពុជានិងសិក្សាលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់ការធ្វើវារីវប្បកម្មសមុទ្រសម្រាប់ការនាំចេញ។

៦.៩- រៀបចំផែនការនៃការបង្កើតទីផ្សារផលវារីវប្បកម្មនិងមានការគាំទ្រនូវមធ្យោបាយដឹកជញ្ជូនផលវារីវប្បកម្មទៅដល់កន្លែងចែកចាយនៅតាមរាជធានី/ខេត្តដល់បណ្តុំវារីវប្បករ។

**ក.៧- បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មព្រៃឈើនិងសត្វព្រៃ**

៧.១- ពង្រឹងនិងកែលម្អខ្សែច្រវាក់តម្លៃផលិតកម្មព្រៃឈើនិងសត្វព្រៃ តាមរយៈការពង្រឹងបច្ចេកវិទ្យាផលិតកម្មនិងកែច្នៃប្រកបដោយនិរន្តរភាព និងពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើ។

៧.២- ពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃដោយបង្កើនបណ្តាញផ្ទេរបច្ចេកវិទ្យាដល់អ្នកពាក់ព័ន្ធដើម្បីបង្កើនគុណភាពនិងផលិតភាពព្រៃឈើនិងសត្វព្រៃ ពិសេសបង្កើនសមត្ថភាពបច្ចេកទេសក្នុងការសិក្សា ពិសោធន៍ស្រាវជ្រាវប្រភេទពូជឈើឆាប់ផ្តល់ផលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

៧.៣- លើកកម្ពស់ការវិនិយោគផ្ទាល់ពីបរទេសលើការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ និងធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ ដើម្បីគាំទ្រផលិតកម្មនិងការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាព។

៧.៤- បង្កើនផលិតកម្មព្រៃឈើដែលមានភាពប្រកួតប្រជែងនិងបរិយាបន្ន តាមរយៈការជំរុញការអនុវត្តគម្រោងសហការដាំព្រៃឈើឡើងវិញ ពិសេសដាំប្រភេទពូជឈើដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់។

៧.៥- លើកកម្ពស់ការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាព ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយការអនុវត្តបច្ចេកទេស ព្រមទាំងពង្រឹងការអនុវត្តច្បាប់និងគោលនយោបាយ។

៧.៦- លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុង អនុវិស័យព្រៃឈើនិងសត្វព្រៃ។

៧.៧- ពង្រឹងការគ្រប់គ្រងនិងបច្ចេកទេសកែច្នៃឈើដាំឱ្យស្របតាមស្តង់ដា សម្រាប់បម្រើដល់ ការនាំចេញនូវផលិតផលឈើដាំ។

**ក.៨- ពង្រឹងប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព**

៨.១- អនុវត្តវិធានការបច្ចេកទេសសំដៅធ្វើឱ្យមាននូវអាហារដែលមានសុវត្ថិភាពនិងមាន អាហារូបត្ថម្ភគ្រប់គ្រាន់ដើម្បីកាត់បន្ថយបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ ដោយរួមបញ្ចូល ការលើកកម្ពស់យេនឌ័រ។

៨.២- ជំរុញឱ្យមានប្រពន្ធ័ស្បៀងអាហារកាន់តែមានប្រសិទ្ធភាព បរិយាបន្ន និងធន់ជាងមុន ដែលអាចបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ដោយត្រូវជំរុញការធ្វើទំនើបកម្មនៃ ផលិតកម្មស្បៀងអាហារ។

៨.៣- អនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ឆ្នាំ២០៣០។

៨.៤- អនុវត្តនូវវិធានការកាត់បន្ថយការបាត់បង់ស្បៀងតាមបណ្តោយខ្សែច្រវាក់តម្លៃកសិកម្ម។

**ក.៩- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្ម**

៩.១- រៀបចំយុទ្ធសាស្ត្រកសិកម្មអេឡិចត្រូនិកនិងបង្កើតប្រព័ន្ធគាំទ្រកសិកម្មតាមបែបឌីជីថល ដើម្បីជំរុញផលិតកម្មកសិកម្ម រួមទាំងការចែករំលែកព័ត៌មានបច្ចេកទេសកសិកម្មទាន់ ពេលវេលា។

៩.២- បង្កើតនិងអនុវត្តឧបករណ៍សម្រាប់ឌីជីថលនីយកម្មក្នុងការអប់រំ ការបណ្តុះបណ្តាល និង ការងារផ្សព្វផ្សាយកសិកម្ម ព្រមទាំងលើកទឹកចិត្តដល់ការប្រើប្រាស់ឧបករណ៍ឌីជីថល និង ឧបករណ៍ឆ្លាតវៃដោយកសិករទាំងបុរសនិងស្ត្រី។

៩.៣- បង្កើតនិងសម្របសម្រួលដល់ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់កសិពាណិជ្ជកម្ម។

៩.៤- ផ្តល់សេវាកម្មដោយប្រើបច្ចេកវិទ្យាឌីជីថល ជាពិសេសគាំទ្រដល់ប្រព័ន្ធផ្តល់វិញ្ញាបនបត្រ ការចេញលិខិតអនុញ្ញាតនានា ការផ្លាស់ប្តូរព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ សមស្របតាមតម្រូវការជាតិនិងអន្តរជាតិ។

៩.៥- គាំទ្រដល់ការអភិវឌ្ឍនិងការគ្របដណ្តប់ទូលំទូលាយនៃបណ្តាញឌីជីថលនៅទូទាំងប្រទេស កម្ពុជា រួមទាំងតំបន់ជនបទនិងតំបន់កសិកម្ម ដើម្បីសម្រួលដល់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាននិងទូរគមនាគមន៍។

៩.៦- អនុវត្តសាកល្បងសេវាផ្សព្វផ្សាយកសិកម្មដែលប្រើបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងទំនើបលើបច្ចេកវិទ្យាកសិកម្មជាក់លាក់និងវិស័យអាទិភាព(ផលិតកម្មស្រូវ កៅស៊ូ សត្វនិងវារីវប្បកម្មជាដើម)។

៩.៧- អនុវត្តសាកល្បងគំនិតនៃការដាក់បញ្ចូលកសិករវ័យក្មេងជាអ្នកសម្របសម្រួលបន្ថែមលើភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលទទួលការបណ្តុះបណ្តាលលើបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ដែលគាំទ្រដោយអ្នកអភិវឌ្ឍបច្ចេកវិទ្យាវ៉ៃឆ្លាត។

៩.៨- ពង្រឹងការអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ (National Single Window)។

៩.៩- សម្របសម្រួលការស្រាវជ្រាវនិងអនុវត្តសាកល្បងវេទិកាឌីជីថលសម្រាប់កៀរគរការវិនិយោគសាធារណៈលើការដាំឈើវិបុលកម្មនិងចិញ្ចឹមសត្វព្រៃ។

## ក.១០- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារសម្រាប់កសិករខ្នាតតូចនិងមធ្យម

១០.១- បង្កើតនិងពង្រឹងសហគមន៍កសិកម្មដើម្បីកែលម្អលទ្ធភាពចូលទៅកាន់ទីផ្សារ តាមរយៈកិច្ចព្រមព្រៀងអាជីវកម្មឬយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា។

១០.២- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារសម្រាប់កសិករខ្នាតតូចនិងមធ្យមតាមរយៈការរៀបចំផ្សព្វផ្សាយតាំងលក់ផលិតផលកសិកម្មនៅតាមបណ្តារាជធានីខេត្ត។

១០.៣- ជំរុញការអនុវត្តបច្ចេកទេសសមស្របនិងធាតុចូល ដើម្បីធានាការចំណាយទាបនៃផលិតកម្មសំដៅបង្កើនការប្រកួតប្រជែងរបស់កសិករខ្នាតតូចនិងមធ្យម។

១០.៤- បង្កើតលទ្ធភាពចូលទៅកាន់ទីផ្សារ ជាមួយនឹងតម្លៃថេរក្នុងរដូវប្រមូលផល (ចងក្រងបណ្តុំអាជីវកម្ម ដោយភ្ជាប់ទីផ្សារតាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា)។

១០.៥- ធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់ខ្សែច្រវាក់តម្លៃក្នុងចំណោមតួអង្គនានា ដោយត្រូវផ្សព្វផ្សាយដល់កសិករក្នុងការរៀបចំការផលិតនូវផលិតផលកសិកម្ម ស្របគ្នាជាមួយតម្រូវការផ្គត់ផ្គង់លើទីផ្សារ។

១០.៦- ពង្រីកសេវាកម្មព័ត៌មានទីផ្សារកសិកម្មបែបឌីជីថលដល់កសិករខ្នាតតូចនិងមធ្យម សំដៅភ្ជាប់ទីផ្សារកសិកម្មនិងកសាងទំនុកចិត្តក្នុងចំណោមតួអង្គនៃខ្សែច្រវាក់តម្លៃកសិកម្ម។

១០.៧- បង្កើតបណ្តុំអាជីវកម្មរបស់កសិករនិងអ្នកកែច្នៃកសិផលសម្រាប់បង្កភាពងាយស្រួលក្នុងការចែកចាយនិងគ្រប់គ្រងតម្លៃទីផ្សារ។

១០.៨- ជំរុញការបញ្ចូលសកម្មភាពទេសចរណ៍និងអេកូទេសចរណ៍ទៅក្នុងសហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍ដែលមានសក្តានុពលផ្សេងទៀត។

## ផ្នែកទី២ : ការវិនិយោគសាធារណៈនិងឯកជនក្នុងវិស័យកសិកម្ម

### គោលដៅយុទ្ធសាស្ត្រទី២ : "បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មនិងការសម្រួលកសិពាណិជ្ជកម្ម"

### ខ.១- បង្កើនប្រសិទ្ធភាពនៃការស្រោចស្រពកសិកម្ម

១.១- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកធារាសាស្ត្រកសិកម្ម។

១.២- គ្រប់គ្រងនិងអភិវឌ្ឍធនធានទឹកនិងការអនុវត្តការពង្រីកប្រព័ន្ធធារាសាស្ត្រ។

១.៣- គ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត។

១.៤- គ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម។

១.៥- បង្កើនការការពារនិងអភិរក្សធនធានទឹក។

១.៦- ធ្វើផែនទីនិងកំណត់តំបន់ស្រោចស្រពកសិកម្មដើម្បីធ្វើផែនការផលិតកម្មកសិកម្មសមស្រប។

១.៧- ការកំណត់និងធ្វើអាទិភាពដល់តំបន់សក្តានុពលសម្រាប់ប្រព័ន្ធធារាសាស្ត្រ។

១.៨- សាងសង់និងស្តារស្ថានីយបូមទឹកសម្រាប់បម្រើឱ្យការងារកសិកម្ម។

១.៩- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកក្នុងតំបន់កសិកម្មដែលទទួលបានការស្រោចស្រព។

១.១០- ជំរុញលើកទឹកចិត្តស្តារព្រែក បឹង អូរ ស្រះ ត្រពាំងធម្មជាតិ សម្រាប់ស្តុកទឹកអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតជាអន្តរកាល និងជួយពន្លឿនការរំដោះទឹកជំនន់ផងដែរ។

### ខ.២- ពង្រីកការភ្ជាប់ផ្លូវចូលទៅកសិដ្ឋានបណ្តាញអគ្គិសនីនិងការដឹកជញ្ជូនផលិតផលកសិកម្ម

២.១- បង្កើនថវិកាវិនិយោគដើម្បីកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រកសិកម្ម និងត្រូវពង្រីកការតភ្ជាប់ផ្លូវចូលទៅកសិដ្ឋាន ទីផ្សារ និងសហគ្រាសកសិកម្មឱ្យបានល្អប្រសើរ។

២.២- ពង្រីកការគ្របដណ្តប់និងបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ ដោយសាងសង់ស្ថានីយបន្ថែមនៅតំបន់សក្តានុពលកសិកម្ម ពិសេសពង្រីកបណ្តាញអគ្គិសនីសម្រាប់ផលិតកម្មកសិកម្មក្នុងសហគមន៍កសិកម្ម និងសហគ្រាសកែច្នៃផលិតផលកសិកម្ម។

២.៣- ពិនិត្យលទ្ធភាពបង្កើនថវិកានិងគ្រប់គ្រងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការងារផលិតកម្មកសិកម្ម។

២.៤- ពង្រីកប្រព័ន្ធឡូហ្ស៊ីស្ទិកសម្រាប់ផលិតផលកសិកម្ម ដើម្បីផ្តល់នូវការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការដឹកជញ្ជូនកសិផល រួមទាំងការរៀបចំបង្កើតផ្សារបោះដុំកសិផល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រោយពេលប្រមូលផលចាំបាច់ផ្សេងទៀត។

### ខ.៣- លើកកម្ពស់ការវិនិយោគកសិកម្មនិងកិច្ចសម្រួលកសិពាណិជ្ជកម្ម

៣.១- ជំរុញវិស័យឯកជនឱ្យបង្កើនការវិនិយោគក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម ពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍកសិកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ។

## ផ្នែកទី២ : ការវិនិយោគសាធារណៈនិងឯកជនក្នុងវិស័យកសិកម្ម

### គោលដៅយុទ្ធសាស្ត្រទី២ : "បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មនិងការសម្រួលកសិពាណិជ្ជកម្ម"

### ខ.១. បង្កើនប្រសិទ្ធភាពនៃការស្រោចស្រពកសិកម្ម

១.១. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកធារាសាស្ត្រកសិកម្ម។

១.២. គ្រប់គ្រងនិងអភិវឌ្ឍធនធានទឹកនិងការអនុវត្តការពង្រីកប្រព័ន្ធធារាសាស្ត្រ។

១.៣. គ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត។

១.៤. គ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម។

១.៥. បង្កើនការការពារនិងអភិរក្សធនធានទឹក។

១.៦. ធ្វើផែនទីនិងកំណត់តំបន់ស្រោចស្រពកសិកម្មដើម្បីធ្វើផែនការផលិតកម្មកសិកម្មសមស្រប។

១.៧. ការកំណត់និងធ្វើអាទិភាពដល់តំបន់សក្តានុពលសម្រាប់ប្រព័ន្ធធារាសាស្ត្រ។

១.៨. សាងសង់និងស្តារស្ថានីយបូមទឹកសម្រាប់បម្រើឱ្យការងារកសិកម្ម។

១.៩. បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកក្នុងតំបន់កសិកម្មដែលទទួលបានការស្រោចស្រព។

១.១០. ជំរុញលើកទឹកចិត្តស្តារព្រែក បឹង អូរ ស្រះ ត្រពាំងធម្មជាតិ សម្រាប់ស្តុកទឹកអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតជាអន្តរកាល និងជួយពន្លឿនការរំដោះទឹកជំនន់ផងដែរ។

### ខ.២. ពង្រីកការភ្ជាប់ផ្លូវចូលទៅកសិដ្ឋានបណ្តាញអគ្គិសនីនិងការដឹកជញ្ជូនផលិតផលកសិកម្ម

២.១. បង្កើនថវិកាវិនិយោគដើម្បីកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រកសិកម្ម និងត្រូវពង្រីកការតភ្ជាប់ផ្លូវចូលទៅកសិដ្ឋាន ទីផ្សារ និងសហគ្រាសកសិកម្មឱ្យបានល្អប្រសើរ។

២.២. ពង្រីកការគ្របដណ្តប់និងបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ ដោយសាងសង់ស្ថានីយបន្ថែមនៅតំបន់សក្តានុពលកសិកម្ម ពិសេសពង្រីកបណ្តាញអគ្គិសនីសម្រាប់ផលិតកម្មកសិកម្មក្នុងសហគមន៍កសិកម្ម និងសហគ្រាសកែច្នៃផលិតផលកសិកម្ម។

២.៣. ពិនិត្យលទ្ធភាពបង្កើនថវិកានិងគ្រប់គ្រងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការងារផលិតកម្មកសិកម្ម។

២.៤. ពង្រីកប្រព័ន្ធឡូហ្ស៊ីស្ទិកសម្រាប់ផលិតផលកសិកម្ម ដើម្បីផ្តល់នូវការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការដឹកជញ្ជូនកសិផល រួមទាំងការរៀបចំបង្កើតផ្សារបោះដុំកសិផល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រោយពេលប្រមូលផលចាំបាច់ផ្សេងទៀត។

### ខ.៣. លើកកម្ពស់ការវិនិយោគកសិកម្មនិងកិច្ចសម្រួលកសិពាណិជ្ជកម្ម

៣.១. ជំរុញវិស័យឯកជនឱ្យបង្កើនការវិនិយោគក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម ពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍកសិកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ។

៣.២. លើកទឹកចិត្តនិងផ្តល់ការថែទាំការវិនិយោគក្នុងស្រុកនិងបរទេសក្នុងវិស័យកសិកម្មតាមរយៈការបង្កើតគោលនយោបាយ បទប្បញ្ញត្តិពាក់ព័ន្ធ និងជំរុញការអនុវត្តច្បាប់ស្តីពីវិនិយោគ។

៣.៣. សម្របសម្រួលវិនិយោគលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេសសម្រាប់កែច្នៃផលិតផលកសិកម្មនាំចេញ។

៣.៤. ពង្រីកភាពជាដៃគូរវាងវិស័យសាធារណៈនិងផ្នែកឯកជន ពិសេសការបង្កើតសហព័ន្ធកសិឧស្សាហកម្មកម្ពុជា។

៣.៥. បន្តកែទម្រង់និងការពង្រឹងសមត្ថភាពស្ថាប័នក្នុងការផ្តល់សេវា កាត់បន្ថយចំណាយលើការធ្វើធុរកិច្ច ដោយពិនិត្យជាចាំបាច់លើបញ្ហាបទប្បញ្ញត្តិ នីតិវិធីនៃការអនុវត្ត សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៣.៦. លើកទឹកចិត្តបង្កើតនិងពង្រីកភាពជាដៃគូរវាងរដ្ឋនិងឯកជន លើការបង្កើតរោងចក្រផលិតជីកសិកម្មនិងចំណីសត្វក្នុងស្រុកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាការផ្គត់ផ្គង់ជីនិងចំណីសត្វមានគុណភាពខ្ពស់ ថ្លៃសមស្របដែលធានាបាននូវផលិតផលកសិកម្មមានទិន្នផល និងសុវត្ថិភាពខ្ពស់ សម្រាប់ប្រជែងបានទាំងក្នុងស្រុក តំបន់ និងទីផ្សារអន្តរជាតិ។

៣.៧. លើកកម្ពស់ការវិនិយោគទៅលើវិបុលកម្មសត្វព្រៃដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ដោយបង្កលក្ខណៈអំណោយផលដែលផ្តល់ការលើកទឹកចិត្តវិស័យឯកជន នៅក្នុងការធ្វើវិបុលកម្មសត្វព្រៃ។

៣.៨. ជំរុញការវិនិយោគលើគម្រោងបង្កើតមូលដ្ឋានឧស្សាហកម្មកែច្នៃឈើដាំ។

## ២.៤. បង្កើនធនធានហិរញ្ញវត្ថុនិងឥណទានក្នុងវិស័យកសិកម្ម

៤.១. បង្កើនការប្រើប្រាស់ថវិកាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ក្នុងការអភិវឌ្ឍវិស័យកសិកម្មដែលឆ្លើយតបនឹងភាពចាំបាច់និងតម្រូវការរបស់អ្នកផលិត អ្នកកែច្នៃ និងអ្នកនាំចេញ។

៤.២. សម្របសម្រួលនិងអភិវឌ្ឍសេវាកម្មហិរញ្ញវត្ថុនិងផលិតផលហិរញ្ញវត្ថុ ស្របតាមតម្រូវការសម្រាប់កសិដ្ឋានខ្នាតតូចនិងមធ្យម និងកសិធុរកិច្ច។

៤.៣. បង្កើនឥណទានសម្រាប់វិស័យកសិឧស្សាហកម្ម ដោយត្រូវបង្កើនទំហំទឹកប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារសហគ្រាសខ្នាតតូចនិងមធ្យម ដើម្បីបម្រើសេចក្តីត្រូវការហិរញ្ញវត្ថុរបស់អ្នកពាក់ព័ន្ធកសិឧស្សាហកម្ម។

៤.៤. ជំរុញឱ្យមានការចូលរួមនិងបង្កើនលទ្ធភាពប្រើប្រាស់សេវាធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មឱ្យកាន់តែច្រើនបន្ថែមទៀត ដើម្បីបម្រើសេចក្តីត្រូវការហិរញ្ញវត្ថុរបស់តួអង្គនានានៅក្នុងខ្សែច្រវាក់តម្លៃ ពិសេសពង្រីកបន្ថែមនូវឥណទានក្រៅពីស្រូវអង្ករ ដោយបង្កើនឥណទានដល់ការចិញ្ចឹមសត្វ ការបង្កើតសត្តឃាតដ្ឋាន ការកែច្នៃផលិតផលសត្វ វារីវប្បកម្ម ការកែច្នៃផល ផលិតផលជលផល ការគាំទ្រសហគមន៍ ការដាំឈើ ការធ្វើវិបុលកម្ម និងចិញ្ចឹមសត្វព្រៃ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រកសិកម្មផ្សេងទៀត។

## ផ្នែកទី៣ : កំណើនប្រកបដោយចីរភាពនិងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

## គោលដៅយុទ្ធសាស្ត្រទី៣ : "បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផល ប្រកបដោយនិរន្តរភាព"

### គ.១- លើកកម្ពស់ការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃ

១.១- ជំរុញការគ្រប់គ្រងនិងអភិវឌ្ឍព្រៃឈើ មានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដោយត្រូវរៀបចំផែនការអភិវឌ្ឍន៍វិស័យព្រៃឈើសម្រាប់អនុវត្តរយៈពេល១០ឆ្នាំទៅមុខ និងរៀបចំយន្តការអនុវត្តផែនការនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

១.២- បង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍព្រៃឈើសហគមន៍ ជំរុញការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ រៀបចំគោលការណ៍ណែនាំស្តីពីការចងក្រងផែនការគ្រប់គ្រងព្រៃសហគមន៍និងលើកកម្ពស់ជីវភាពសហគមន៍តាមរយៈការអនុវត្តប្រព័ន្ធកសិរុក្ខកម្ម។

១.៣- ជំរុញការគ្រប់គ្រងនិងអភិវឌ្ឍសត្វព្រៃនិងជីវៈចម្រុះ ពិសេសជំរុញការថែរក្សា ចិញ្ចឹម និងការធ្វើវិបុលកម្មសត្វព្រៃជាលក្ខណៈគ្រួសារនិងកសិដ្ឋាន។

១.៤- ជំរុញការចុះបញ្ជីដីព្រៃឈើ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងព្រៃឈើនិងសត្វព្រៃឱ្យមានប្រសិទ្ធភាពខ្ពស់។

១.៥- ពង្រឹងការស្រាវជ្រាវដើម្បីគាំទ្រដល់ការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ។

១.៦- ពង្រឹងក្របខ័ណ្ឌស្ថាប័នសម្រាប់ការអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាពទាក់ទងនឹងធនធានព្រៃឈើនិងសត្វព្រៃ។

### គ.២- លើកកម្ពស់ការគ្រប់គ្រងធនធានជលផល

២.១- ជំរុញការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលឆ្នាំ២០១៥-២០២៤ និងរៀបចំធ្វើបច្ចុប្បន្នភាពផែនការនេះសម្រាប់អនុវត្តរយៈពេល១០ឆ្នាំទៅមុខទៀត។

២.២- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ ពិសេសពង្រឹងសមត្ថភាពសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានជលផល និងលើកកម្ពស់ជីវភាពរស់នៅប្រជានេសាទនៅតាមសហគមន៍ ព្រមទាំងពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍ស្រះជម្រកត្រី។

២.៣- លើកទឹកចិត្តបង្កើនការការពារ អភិរក្សធនធានជលផល នៅតាមបឹង អូរ ព្រែក ទន្លេ សមុទ្រ និងពង្រឹងការគ្រប់គ្រងដែននេសាទ។

២.៤ ពង្រីកការផ្សព្វផ្សាយជំរុញការចិញ្ចឹមត្រីតាមបែបធម្មជាតិនៅតាមវាលស្រែ តាមទីតាំងណាដែលអាចធ្វើបាន ដើម្បីស្ដារត្រីធម្មជាតិឡើងវិញ កែលម្អប្រភពផ្គត់ផ្គង់ត្រីតាមបែបធម្មជាតិ កាត់បន្ថយការប្រើប្រាស់ជីនិងថ្នាំគីមីកសិកម្មដែលបំផ្លាញត្រីនិងជីវៈចម្រុះ។

២.៥ ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍ធនធានជលផលដោយផ្ដោតលើការវិភាគខ្សែច្រវាក់តម្លៃ រួមទាំងការគ្រប់គ្រងក្រោយប្រមូលផល។

២.៦ ជំរុញការអភិវឌ្ឍសមត្ថភាពនិងបច្ចេកវិទ្យាដើម្បីកែលម្អគុណភាពនៃផលរបស់អ្នកនេសាទខ្នាតតូចសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

២.៧ បង្កើនការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផលនិងលើកកម្ពស់ការនាំចេញផល ផលិតផលជលផល។

២.៨ ជំរុញការអនុវត្តគោលនយោបាយគ្រប់គ្រងជលផលសមុទ្រ។

២.៩ ពង្រឹងការអនុវត្តច្បាប់ស្ដីពីជលផលនិងបទប្បញ្ញត្តិដែលមានស្រាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់។

២.១០ ពង្រឹងសមភាពយេនឌ័រនិងលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល។

## គ.៣ លើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម

៣.១ អនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី សំដៅរក្សានិងបង្កើនផលិតភាពដីឆ្លើយតបនឹងតម្រូវការក្នុងការអភិវឌ្ឍវិស័យកសិកម្ម ការកែលម្អស្ថានភាពនៃជីវិតរស់នៅរបស់ប្រជាជន ព្រមទាំងក្នុងការរួមចំណែកកាត់បន្ថយនិងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។

៣.២ ទប់ស្កាត់ការរេចរឹលដីនិងបង្កើនផលិតភាពដីតាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងពង្រីកការអនុវត្តបច្ចេកទេសគ្រប់គ្រងដីកសិកម្ម។

៣.៣ រៀបចំផែនការសកម្មភាពជាក់លាក់និងអនុវត្តឱ្យបានសកម្ម ដើម្បីទប់ស្កាត់ការខ្សោះជីវជាតិដី គុណភាពទឹក និងការពារធនធានធម្មជាតិ។

៣.៤ ធ្វើឱ្យប្រសើរឡើងនូវការអភិរក្សដីកសិកម្មរបស់ប្រទេសកម្ពុជា ដោយត្រូវស្ដារទីជម្រាលនិងសេវាកម្មអេកូឡូស៊ី រួមទាំងការជំរុញអនុវត្តបង្ហាញអំពីការអនុវត្តល្អក្នុងការគ្រប់គ្រងដីកសិកម្មនិងការរៀបចំបង្ហាញអំពីប្រសិទ្ធភាពនៃការបញ្ចូលក្បាលដីរួមគ្នាក្នុងការធ្វើផលិតកម្មកសិកម្មបែបយន្តូបនីយកម្ម។

៣.៥ ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងដីនិងទីជម្រាលដោយចីរភាព។

៣.៦ លើកកម្ពស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងអេកូឡូស៊ី។

៣.៧ បង្កើនការអនុវត្តនូវយុទ្ធសាស្ត្រឬវិធីសាស្ត្រគាំទ្រវិស័យកសិកម្ម ដោយផ្ដោតលើការមិនមានការប្រើប្រាស់ជីគីមីដែលមិនស្របតាមស្តង់ដា ព្រមទាំងជំរុញការងារកសិកម្មដែលប្រើប្រាស់ជីធម្មជាតិឱ្យមាននិរន្តរភាព។

### គ.៤- ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

៤.១- ជំរុញការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព តាមរយៈការបង្កើតនិងអនុវត្តនូវយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឆ្នាំ២០៣០។

៤.២- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញប្រកបដោយប្រសិទ្ធភាពនិងចីរភាព តាមរយៈការបង្កើតនិងអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០។

៤.៣- លើកកម្ពស់ផលិតកម្មកសិកម្មដែលមានមេត្រីភាពបរិស្ថាននិងជំរុញផលិតកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន តាមរយៈការអនុវត្តបច្ចេកទេសកសិកម្មអភិរក្ស។

៤.៤- សម្របសម្រួលការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាឆ្ពោះទៅរកអព្យាក្រឹតកាបូន(Carbon Neutral)។

៤.៥- អនុវត្តយុទ្ធសាស្ត្រពាក់ព័ន្ធដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ធនធានជលផល រួមទាំងវារីវប្បកម្ម។

៤.៦- សម្រួលសម្រួលគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី១២ ដែលជាការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាពឱ្យស្របនឹងគោលនយោបាយនៃការប្រើប្រាស់ជីគីមី។

## ផ្នែកទី៤ : ការកែទម្រង់ស្ថាប័ននិងបញ្ហាអន្តរវិស័យ

## គោលដៅយុទ្ធសាស្ត្រទី៤ : "ពង្រឹងអភិបាលកិច្ចនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"

### ឃ.១- ពង្រឹងការគ្រប់គ្រងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស

១.១- ធ្វើការកែទម្រង់ការគ្រប់គ្រងស្ថាប័នទៅជារចនាសម្ព័ន្ធដែលមានប្រសិទ្ធភាពជាងមុន រួមទាំងការគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយការគាំទ្រនិងមានប្រសិទ្ធភាពខ្ពស់។

១.២- ពង្រឹងការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងវិស័យកសិកម្ម តម្រង់ឆ្ពោះទៅរកការពង្រឹងសមត្ថភាពមនុស្សនិងស្ថាប័នក្នុងវិស័យកសិកម្ម ព្រមទាំងធានាសមភាពយេនឌ័រក្នុងការអភិវឌ្ឍធនធានមនុស្ស។

១.៣- ពង្រឹងគុណភាពនៃការអប់រំកសិកម្មតាមរយៈការអនុវត្តផែនការមេឆ្នាំ២០៣០ របស់គ្រឹះស្ថានអប់រំកសិកម្មនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យកសិកម្ម សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីផ្តល់នូវលទ្ធភាពបង្កើតមុខរបរវិជ្ជាជីវៈដែលទាក់ទាញ ផ្អែកលើគុណផល និងមានចំណូលខ្ពស់។

១.៤- បង្កើនសមត្ថភាពស្រាវជ្រាវសម្រាប់ការអភិវឌ្ឍកសិកម្ម ធ្វើការស្រាវជ្រាវមូលដ្ឋាន និងការស្រាវជ្រាវបែបអនុវត្តដែលផ្សារភ្ជាប់ទៅនឹងតម្រូវការទីផ្សារ ព្រមទាំងត្រូវរៀបចំនិងអនុវត្តគោលនយោបាយស្រាវជ្រាវកសិកម្មកម្ពុជា។

១.៥- ពង្រឹងសមត្ថភាពសេវាផ្សព្វផ្សាយបច្ចេកទេសលើជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាក់ទាញ ប្រមូលផ្តុំ និងបណ្តុះបណ្តាលបច្ចេកវិទ្យាកសិកម្មថ្មីៗនិងឌីជីថលដល់កសិករវ័យក្មេង ព្រមទាំងពង្រឹងការតភ្ជាប់រវាងការស្រាវជ្រាវនិងការផ្សព្វផ្សាយកសិកម្ម។

១.៦- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងចុះបញ្ជីកសិកម្ម (ដំណាំ ការចិញ្ចឹមសត្វ ព្រៃឈើ ជលផលជាដើម) ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងព្យាករណ៍ការផ្គត់ផ្គង់ និងតម្រូវការសម្រាប់ដាក់ចេញនូវវិធានការនានាក្នុងការអភិវឌ្ឍវិស័យកសិកម្មទាំងមូល។

### ឃ.២- ការរៀបចំតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យកសិកម្ម

២.១- រៀបចំកសាងច្បាប់ថ្មីៗបន្ថែមទៀតនិងធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធនឹងវិស័យកសិកម្មឱ្យស្របតាមសភាពការណ៍ជាក់ស្តែង (ធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើនិងច្បាប់ស្តីពីជលផល)។

២.២- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញឱ្យអនុវត្តដើម្បីពង្រឹងវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

២.៣- រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ (អនុក្រឹត្យ ប្រកាសនានា) និងពិនិត្យលើតម្រូវការកែសម្រួលបទប្បញ្ញត្តិ ដែលគ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍កសិកម្ម ដើម្បីផ្តល់បរិយាកាសគាំទ្រដល់អ្នកផលិតផលិតផលកសិកម្ម អ្នកកែច្នៃ និងអ្នកនាំចេញ។

២.៤- ពង្រីកការផ្សព្វផ្សាយនិងការយល់ដឹងជាសាធារណៈលើច្បាប់និងបទប្បញ្ញត្តិដែលទាក់ទងនឹងវិស័យកសិកម្ម។

### ឃ.៣- បង្កើនភាពជាអ្នកដឹកនាំក្នុងវិស័យកសិកម្ម

៣.១- ជំរុញការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងសមត្ថភាពការងារនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីគ្រប់គ្រង ដឹកនាំ និងគាំទ្រដល់កិច្ចអភិវឌ្ឍវិស័យកសិកម្ម និងអ្នកពាក់ព័ន្ធក្នុងវិស័យនេះ។

៣.២- ពង្រឹងសមត្ថភាពដើម្បីទាក់ទាញការគាំទ្រនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

៣.៣- លើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅគ្រប់ដំណាក់កាលនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនិងអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត ដែលគិតគូរពីយេនឌ័រ។

៣.៤- ផ្តល់ចំណេះដឹងបច្ចេកទេសកសិកម្មនិងចំណេះធ្វើជាក់លាក់ ការងារប្រតិបត្តិការ ព្រមទាំងព័ត៌មានចាំបាច់សម្រាប់ការអនុវត្តនិងវាយតម្លៃគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនៅថ្នាក់ក្រោមជាតិ។

៣.៥- ពង្រឹងយន្តការនៃការអនុវត្តរបស់អង្គភាពគ្រប់គ្រងគម្រោងអភិវឌ្ឍន៍កសិកម្ម ដើម្បីបង្កើនការសម្របសម្រួល ការធ្វើសុខដុមនីយកម្មនៃគម្រោងទាំងអស់ឱ្យមានសង្គតិភាព និងជំរុញការអនុវត្តឆ្លើយតបទៅនឹងវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម។

## ៦- យន្តការសម្រាប់អនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០

យុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើគឺផ្តោតសំខាន់ទៅលើការរៀបចំនិងការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាក់លាក់មួយ ដោយផ្អែកលើយន្តការសហការជិតស្និទ្ធនិងសម្របសម្រួលដើម្បីធានាការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ ប្រកបដោយប្រសិទ្ធភាព។ សសរស្តម្ភគោលនយោបាយតាមផ្នែកទាំងបួនផ្តល់នូវក្របខ័ណ្ឌរួមមួយសម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះ។ សសរស្តម្ភទាំងបួននេះមិនមែនជាសមាសធាតុដោយឡែកតែឯងនោះទេ ប៉ុន្តែជាការពង្រឹងគ្នាទៅវិញទៅមក ដោយផ្អែកលើសកម្មភាពសម្របសម្រួលនិងការបំពេញបន្ថែមជាមួយនឹងគោលនយោបាយតាមវិស័យផ្សេងៗទៀត។

តួអង្គសំខាន់ៗដែលត្រូវអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ រួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នទទួលខុសត្រូវដឹកនាំការអនុវត្តផ្ទាល់ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍ និងវិស័យឯកជនដែរ។ ជំហានទាំងបួនដែលពាក់ព័ន្ធនឹងការបង្កើត ការអនុវត្ត និងការវាយតម្លៃគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះរួមមាន៖

១- **ការប្រឹក្សាពិគ្រោះយោបល់:** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងាររៀបចំគោលនយោបាយបានធ្វើការសិក្សាលើឯកសារនិងរបាយការណ៍គោលនយោបាយដែលពាក់ព័ន្ធដើម្បីជាមូលដ្ឋានក្នុងការតាក់តែងគោលនយោបាយនេះ។ ការពិគ្រោះយោបល់គោលនយោបាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានធ្វើឡើង។ មន្ត្រីនិងអ្នកជំនាញសំខាន់ៗរបស់រាជរដ្ឋាភិបាលបានចូលរួមផ្តល់យោបល់ ដើម្បីធានាថាគំនិតនិងយោបល់ទាំងនោះត្រូវបានដាក់ចូលទៅក្នុងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះ។

២- **ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន :** វិធានការគោលនយោបាយដូចដែលមានចែងក្នុងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ផ្តល់ឱកាសឱ្យអ្នកគាំទ្រផ្នែកបច្ចេកទេសនិងធនធានហិរញ្ញវត្ថុ រួមទាំងវិស័យឯកជននិងដៃគូអភិវឌ្ឍ បង្កើនកិច្ចសហការគ្នាក្នុងការអនុវត្តគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់ តាមរយៈកិច្ចសម្របសម្រួលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយ

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងារបច្ចេកទេស (TWGs) ពាក់ព័ន្ធទាំងអស់។

៣. **ការអនុវត្តនិងការសម្របសម្រួល :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារបច្ចេកទេសនឹងដឹកនាំតាមវិធីសាស្ត្រសម្របសម្រួល សហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម និងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ឱ្យមានប្រសិទ្ធភាពខ្ពស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តតាមអភិក្រមគោលនយោបាយ "ភាពជាដៃគូរដ្ឋ/ដៃគូអភិវឌ្ឍ វិស័យឯកជន និងអ្នកផលិត/សហគមន៍កសិកម្ម" ដែលនឹងគាំទ្រដល់ដំណើរការនៃការអនុវត្តនេះបានល្អប្រសើរ។

៤. **យន្តការសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីវឌ្ឍនភាពនិងនិន្នាការសំខាន់ៗធៀបនឹងសូចនាកររបស់គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតួអង្គសំខាន់ៗទាំងអស់ត្រូវទទួលខុសត្រូវ ដោយត្រួតពិនិត្យនូវភាពសមស្របនៃវិធានការនិងសម្រួលការអនុវត្តរបស់ខ្លួន។ កិច្ចដំណើរការត្រួតពិនិត្យគឺនឹងត្រូវផ្អែកលើយន្តការពិនិត្យតាមដាននិងវាយតម្លៃ ដែលនឹងត្រូវបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានានិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធស្ថិតិកសិកម្ម ដែលជាឧបករណ៍តាមដាននិងវាយតម្លៃ ត្រូវតែពង្រឹងឱ្យមានប្រសិទ្ធភាពខ្ពស់។

## ៧. ធនធានហិរញ្ញវត្ថុ

ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ត្រូវការថវិកាពីប្រភពសំខាន់ចំនួនបីគឺ ថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍ និងការវិនិយោគរបស់វិស័យឯកជន។ ថវិកាជាតិដែលទទួលបានពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបែងចែកឱ្យបានសមស្របទៅតាមក្រសួងស្ថាប័ននិងអង្គភាពបច្ចេកទេសពាក់ព័ន្ធសម្រាប់អនុវត្តសកម្មភាពក្នុងគោលនយោបាយនេះ។ បណ្តាដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងបង្កើតយុទ្ធសាស្ត្រភាពជាដៃគូក្នុងប្រទេសរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងគោលបំណងនិងគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិនេះ។ ទន្ទឹមនឹងនេះ ស្នើឱ្យវិស័យឯកជនបង្កើនការបណ្តាក់ទុនវិនិយោគដើម្បីធ្វើទំនើបកម្មវិស័យកសិកម្មផងដែរ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាវិធានការគោលនយោបាយដ៏សំខាន់និងបានកំណត់ទិសដៅច្បាស់លាស់ ក្នុងការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ ទៅជាប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ។ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលឬសមិទ្ធកម្មនេះគឺជាប្រព័ន្ធផ្សារភ្ជាប់ការវិភាជន៍ថវិកាទៅនឹងសកម្មភាពដែលជាគម្រោងការ

ជាក់ស្តែងនិងក្នុងក្របខ័ណ្ឌកម្មវិធីច្បាស់លាស់ ឆ្លើយតបនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័ន ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាថាថវិកាពិតជាដើរតួនាទីសំខាន់និងជាឧបករណ៍បម្រើឱ្យគោលនយោបាយប្រកបដោយភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាព។

ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវបន្តដាក់ចេញនូវកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពអាទិភាពជាក់លាក់ សំដៅធ្វើការវិភាជន៍ថវិកាជាតិនិងថវិកាដែលបានមកពីដៃគូអភិវឌ្ឍឱ្យបានសមស្រប ឆ្លើយតបទៅនឹងសូចនាករកំណត់ក្នុងគោលនយោបាយនេះ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងមធ្យោបាយដើម្បីសម្រេចបានរបស់កម្មវិធីទាំងអស់នោះ អាចត្រូវបានកែសម្រួលដោយយោងទៅលើលទ្ធផលការងារ និងធនធានដែលមាន។

ជាមួយគ្នានេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធត្រូវបង្កើតគម្រោងលម្អិតដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (PIP) ដោយអនុលោមតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងសម្របសម្រួលដោយក្រសួងផែនការ។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍត្រូវពិនិត្យឡើងវិញនូវបញ្ជីគម្រោងនៃកម្មវិធីវិនិយោគសាធារណៈ ដើម្បីប្រើប្រាស់ក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍ ស្របតាមទិសដៅនិងសក្តានុពល។

ក្រសួងនិងស្ថាប័នពាក់ព័ន្ធចាំបាច់ត្រូវបន្តខិតខំទាក់ទាញជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍនានា ដើម្បីចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយជោគជ័យ។ ជាមួយគ្នានេះដែរ ក្រសួងនិងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនឹងបន្តប្រើប្រាស់ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក(TWG-AW) ព្រមទាំងក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ (TWG-F) ក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ព្រៃឈើ(TWG-FR) ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ(TWG-FSN) ជាមូលដ្ឋានសម្រាប់កៀរគរជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនេះ។ ក្រសួងនិងស្ថាប័នពាក់ព័ន្ធនឹងបន្តប្រើប្រាស់វេទិការាជរដ្ឋាភិបាលវិស័យឯកជន ដើម្បីទាក់ទាញការវិនិយោគកាន់តែច្រើន ដោះស្រាយបញ្ហាប្រឈមដែលវិស័យឯកជនប្រឈមនិងលើកកម្ពស់សហគ្រិនភាព រួមទាំងសហគ្រាសកសិកម្មខ្នាតតូចនិងមធ្យម ជាពិសេសសហគ្រាសកសិពាណិជ្ជកម្ម និងវិនិយោគិនផ្នែកកែច្នៃផលិតផលកសិកម្ម ដែលជាការរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ៨- ការពិនិត្យតាមដាននិងវាយតម្លៃ

ការអនុវត្តផែនការការងារក្រោមគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះតម្រូវឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនិងមានការចូលរួមយ៉ាងសកម្មពីក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអង្គភាពបច្ចេកទេស។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័ននាំមុខក្នុងការអនុវត្តគោល

នយោបាយជាតិនេះ។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួល ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។ គ្រប់ក្រសួងស្ថាប័ននិងអង្គភាពបច្ចេកទេសដែលទទួលខុសត្រូវក្នុងការអនុវត្ត ក្រោមក្របខ័ណ្ឌគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបង្កើតយន្តការនៃការអនុវត្តនិងរាយការណ៍អំពីលទ្ធផលការងារប្រចាំឆ្នាំមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានមូលដ្ឋានបូកសរុបជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំការប្រជុំពិភាក្សាកម្រិតបច្ចេកទេស ដើម្បីឱ្យក្រសួងស្ថាប័ននិងអង្គភាពអនុវត្តពាក់ព័ន្ធរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងពេលអនុវត្ត។

ការពិនិត្យតាមដាននិងវាយតម្លៃអំពីវឌ្ឍនភាពនៅដើមអាណត្តិនឹងត្រូវរៀបចំនៅក្នុងឆ្នាំ២០២៤ ដោយត្រូវចុះសិក្សាលម្អិតនិងប្រមូលព័ត៌មានដើម្បីផ្ទៀងផ្ទាត់សូចនាករដែលបានកំណត់នៅក្នុងកម្រិតនៃវិធានការគោលនយោបាយ។ ការពិនិត្យតាមដាននិងវាយតម្លៃវឌ្ឍនភាពពាក់កណ្ដាលអាណត្តិនឹងត្រូវធ្វើឡើងនៅឆ្នាំ២០២៧ ហើយការពិនិត្យតាមដាននិងវាយតម្លៃចុងក្រោយនឹងធ្វើនៅឆ្នាំ២០៣០ ដើម្បីវាយតម្លៃលទ្ធផល ធៀបនឹងសូចនាករដែលបានកំណត់ និងវាស់វែងលទ្ធផលដូចដែលបានបញ្ជាក់នៅក្នុងគោលនយោបាយជាតិនេះ។

ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយជោគជ័យ ក៏នឹងអាស្រ័យលើស្ថានការណ៍ក្នុងតំបន់និងពិភពលោក ក៏ដូចជាសភាពការណ៍ក្នុងប្រទេស ដែលអាចជះឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលទៅលើដំណើរការនៃការធ្វើទំនើបកម្មកសិកម្ម ការប្រកួតប្រជែងកសិពាណិជ្ជកម្ម ផលិតភាពនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី និងកម្រិតនៃការវិនិយោគឯកជន។ ក្របខ័ណ្ឌនៃយន្តការពិនិត្យតាមដាននិងវាយតម្លៃនឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៅក្នុងកិច្ចការនេះ។ ដើម្បីធានាថាដំណើរការពិនិត្យតាមដាននិងវាយតម្លៃមានភាពរលូន ក្រសួងស្ថាប័នពាក់ព័ន្ធនឹងចាត់តាំងបុគ្គលទទួលខុសត្រូវ (មន្ត្រីជាន់ខ្ពស់) ដើម្បីសម្របសម្រួលនិងរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០។

## ៩- ការគ្រប់គ្រងហានិភ័យ

ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទទួលបាននូវភាពជោគជ័យទៅបាន គឺអាស្រ័យទៅលើកត្តាហានិភ័យខាងក្នុងនិងខាងក្រៅ ដែលត្រូវកំណត់ឱ្យឃើញយ៉ាងច្បាស់នូវអត្តសញ្ញាណដែលនាំឱ្យហានិភ័យទាំងនោះត្រូវបានកាត់បន្ថយ។

**១- ហានិភ័យខាងក្នុង :** ការចូលរួមពីអ្នកពាក់ព័ន្ធនៅគ្រប់កម្រិតដែលជាយន្តការនាំផលការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទទួលបាននូវភាពជោគជ័យ។ កត្តានេះទាមទារឱ្យ

មានការឯកភាពគ្នា មានឆន្ទៈរួមគ្នា សម្របសម្រួលនូវការអនុវត្តសកម្មភាពនិងការសហការក្នុងភាពជាដៃគូ នៃភាគីពាក់ព័ន្ធពីក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យឯកជន ព្រមទាំងរួមគ្នារកដំណោះស្រាយនូវបញ្ហាប្រឈមដែលកើតមានក្នុងវិស័យកសិកម្ម ដើម្បីឱ្យការអនុវត្តគោលនយោបាយនេះមានប្រសិទ្ធភាព។

**២- ហានិភ័យខាងក្រៅ** : វិស័យកសិកម្មនៅតែជួបបញ្ហាប្រឈមនិងភាពងាយរងគ្រោះ ទៅនឹងការប្រែប្រួលអាកាសធាតុ។ គ្រោះរាំងស្ងួត ទឹកជំនន់ និងជំងឺផ្សេងៗ បានជះឥទ្ធិពលនិងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់កសិករប៉ុណ្ណោះទេ ប៉ុន្តែក៏អាចបង្កើតភាពមិនច្បាស់លាស់នៃការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ផងដែរ។ ជាងនេះទៅទៀត ការកើតឡើងនៃហានិភ័យផ្សេងទៀត ដូចជាជំងឺកូវីដ-១៩ ជំងឺរាតត្បាតជាសកល សង្គ្រាមជាដើម ដែលបានជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ បានរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងតម្រូវការ ធ្វើឱ្យប៉ះពាល់ដល់លំហូរពាណិជ្ជកម្មក្នុងតំបន់និងពិភពលោក និងការសម្របសម្រួលកសិពាណិជ្ជកម្ម។

ផែនការគ្រប់គ្រងហានិភ័យនឹងត្រូវបង្កើតឡើងដើម្បីបញ្ចៀសបានឬកាត់បន្ថយជាមុននូវផលប៉ះពាល់ទាំងឡាយដែលអាចកើតមានឡើង។ ជាមួយគ្នានេះដែរ ក្នុងការអនុវត្តគោលនយោបាយនេះ គឺមានជាប់ពាក់ព័ន្ធដល់ការជួយអន្តរាគមន៍ ក៏ដូចជាការលើកទឹកចិត្តពីរដ្ឋ ទាំងផ្នែកពង្រឹងអភិបាលកិច្ច ការគ្រប់គ្រងសមត្ថភាពបច្ចេកទេស ការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយខ្ពស់ សំដៅជួយដោះស្រាយបញ្ហាប្រឈមនានាដែលនឹងជួបប្រទះ ពិសេសការលំបាករបស់វិស័យឯកជនក្នុងការអនុវត្តផែនការវិនិយោគធំៗក្នុងផ្នែកកសិកម្មនិងកសិឧស្សាហកម្ម។

ដើម្បីកាត់បន្ថយហានិភ័យទាំងកត្តាខាងក្នុងនិងខាងក្រៅ ព្រមទាំងបញ្ហាប្រឈម ដែលបានសន្មតនឹងកើតមានក្នុងការអនុវត្តគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធពីក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យឯកជន ត្រូវរួមគ្នាវិភាគនិងរកវិធីសាស្ត្រកាត់បន្ថយ និងគ្រប់គ្រងនូវហានិភ័យ ដែលកើតឡើងជាយថាហេតុ តាមរយៈយន្តការសម្របសម្រួលរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការដោះស្រាយ ដែលជាយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ១០- សេចក្តីសន្និដ្ឋាន

ជារួម គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ដែលផ្តល់ជាផែនទីបង្ហាញផ្លូវទូលំទូលាយមួយ ដើម្បីដឹកនាំវិស័យកសិកម្មកម្ពុជាឆ្ពោះទៅរកកំណើនប្រកបដោយចីរភាពនៅឆ្នាំ២០៣០ ស្របតាមស្ថានភាពសេដ្ឋកិច្ចសង្គមសាកលនិងរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ឆន្ទៈមោះមុត និងសមត្ថភាពវិជ្ជាជីវៈរបស់ក្រសួងស្ថាប័ន ដែលទទួលបន្ទុកអនុវត្តគោលនយោបាយនេះ និងជាកម្លាំងរួមគ្នា

មួយដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយ ដូចដែលបានកំណត់និងដើម្បីលើកកម្ពស់កំណើននៃវិស័យកសិកម្មឱ្យមានភាពប្រកួតប្រជែង មានចីរភាព និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ការរួបរួមក្នុងគោលបំណងតែមួយក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ពិតជាកម្លាំងមួយសម្រាប់ភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មជាក់ជាមិនខាន។

ដោយឡែក ក្រសួងស្ថាប័នពាក់ព័ន្ធក៏មានកិច្ចការជាច្រើនទៀត ដែលនឹងត្រូវអនុវត្តក្នុងគោលនយោបាយនេះនិងត្រូវសម្រេចឱ្យបានលទ្ធផលជាក់ស្តែងនាពេលខាងមុខ។ ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័នត្រូវតែខិតខំធ្វើយ៉ាងណាអនុវត្តការងារឱ្យបានសកម្មនិងខ្លាំងក្លានូវបណ្តាសកម្មភាពទាំងឡាយដូចដែលបានដាក់ចេញក្នុងគោលនយោបាយនេះ។ ជាមួយគ្នានេះ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏នឹងត្រូវបង្កើនការសម្របសម្រួលជាមួយក្រសួងស្ថាប័នដទៃទៀតដែលមានភារកិច្ចអនុវត្តនូវសកម្មភាពគោលនយោបាយគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

ការប្តេជ្ញាយ៉ាងមុតមាំក្នុងការសម្របសម្រួលនិងអនុវត្តគឺជាមូលដ្ឋាននៃជោគជ័យ ដោយត្រូវប្រែក្លាយផែនការសកម្មភាពដែលមានក្នុងគោលនយោបាយជាតិនេះឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើននិងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍនិងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មគ្រប់ជ្រុងជ្រោយឱ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ចូលរួមអនុវត្តគោលនយោបាយនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាពនិងមានប្រសិទ្ធភាពខ្ពស់។

គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ពិតជានឹងចូលរួមសហការអនុវត្តសកម្មភាពការងារ ជាពិសេសសហគមន៍អន្តរជាតិនានានឹងបន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ និងលើកទឹកចិត្តកសិករចូលរួមសកម្ម ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០នេះ ឱ្យទទួលបាននូវលទ្ធផលផ្លែផ្កាជាវិជ្ជមាននិងប្រកបដោយប្រសិទ្ធភាពតាមផែនការនិងការរំពឹងទុក ជាមួយនឹងការប្តេជ្ញាចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យរីកចម្រើនរុងរឿងនាពេលអនាគត។

# ឧបសម្ព័ន្ធ១ : សូចនាករគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០

## គោលដៅយុទ្ធសាស្ត្រទី១ : លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង

| វិធានការគោលនយោបាយ | សូចនាករ | សូចនាករវឌ្ឍនភាព/ សូចនាករសមិទ្ធកម្មបង្ហាញ | មធ្យោបាយផ្ទៀងផ្ទាត់/ ប្រភពទិន្នន័យ |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី១ | កំណើនតម្លៃបន្ថែមសរុបនៃផលិតកម្មដំណាំកើនឡើង ៣,១ % ក្នុងមួយឆ្នាំ | តម្លៃបន្ថែមសរុបនៃផលិតកម្មដំណាំកើនឡើងពី១៣ ១៣០ពាន់លានរៀលក្នុងឆ្នាំ២០១៩ ដល់ ១៨ ៣៧២ ពាន់លានរៀលនៅឆ្នាំ២០៣០ | ប្រភពទិន្នន័យពីក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) |
| | កំណើនតម្លៃបន្ថែមសរុបនៃផលិតកម្មសត្វនឹងកើនឡើង ២,៧% ក្នុងមួយឆ្នាំ | តម្លៃបន្ថែមសរុបនៃផលិតកម្មសត្វកើនឡើងពី ២ ៥០២ពាន់លានរៀលក្នុងឆ្នាំ២០១៩ ដល់ ៣ ៣៥៥ពាន់លានរៀលនៅឆ្នាំ២០៣០ | ប្រភពទិន្នន័យពីក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) |
| | អត្រា (%) នៃការនាំចេញផលិតផលកសិកម្មកែច្នៃធៀបនឹងការនាំចេញផលិតផលសរុប | អត្រា (%) នៃការនាំចេញផលិតផលកសិកម្មកែច្នៃធៀបនឹងការនាំចេញផលិតផលសរុបកើនពី៥% ក្នុងឆ្នាំ២០១៩ ដល់១៥% នៅឆ្នាំ២០៣០ | ប្រភពទិន្នន័យពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

## គោលដៅយុទ្ធសាស្ត្រទី២ : បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មនិងការសម្រួលកសិពាណិជ្ជកម្ម

| វិធានការគោលនយោបាយ | សូចនាករ | សូចនាករវឌ្ឍនភាព/ សូចនាករសមិទ្ធកម្មបង្ហាញ | មធ្យោបាយផ្ទៀងផ្ទាត់/ ប្រភពទិន្នន័យ |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី២ | អត្រា (%) លទ្ធភាពស្រោចស្រពដំណាំស្រូវ (រដូវវស្សា និងរដូវប្រាំង) កើនឡើង | អត្រា (%) លទ្ធភាពស្រោចស្រពដំណាំស្រូវ (រដូវវស្សា និងរដូវប្រាំង) កើនឡើងពី៦១,១៨% ក្នុងឆ្នាំ២០១៩ ដល់៧០% នៅឆ្នាំ២០៣០ | ក្រសួងធនធានទឹកនិងឧតុនិយម |
| | អត្រា% (%) នៃសហគមន៍កសិកម្មត្រូវបានជំរុញឱ្យដាក់ពាក្យស្នើសុំការអនុគ្រោះថ្លៃអគ្គិសនីក្នុងវិស័យកសិកម្ម ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអគ្គិសនី | យ៉ាងតិច៣០% នៃចំនួនសហគមន៍កសិកម្មទទួលបានការតភ្ជាប់អគ្គិសនីដែលមានតម្លៃអនុគ្រោះនៅឆ្នាំ២០៣០ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងរ៉ែនិងថាមពល (អាជ្ញាធរអគ្គិសនីកម្ពុជា) |
| | ប្រវែងផ្លូវជនបទតភ្ជាប់ទៅកសិដ្ឋានកើនឡើង | ប្រវែង(គីឡូម៉ែត្រ) ផ្លូវជនបទតភ្ជាប់ទៅកសិដ្ឋានត្រូវបានសាងសង់ | ក្រសួងអភិវឌ្ឍន៍ជនបទ |

## គោលដៅយុទ្ធសាស្ត្រទី៣ : បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព

| វិធានការគោលនយោបាយ | សូចនាករ | សូចនាករវឌ្ឍនភាព/សូចនាករសមិទ្ធកម្មបង្ហាញ | មធ្យោបាយផ្ទៀងផ្ទាត់/ប្រភពទិន្នន័យ |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី៣ | តម្លៃបន្ថែមសរុបនៃផលិតផលព្រៃឈើកើនឡើងប្រមាណ ១,២% ក្នុងមួយឆ្នាំ | តម្លៃបន្ថែមសរុបនៃផលិតផលព្រៃឈើកើនឡើងពី១ ៤៩០ ពាន់លានរៀល ក្នុងឆ្នាំ២០១៩ ដល់១ ៦៩៩ពាន់លានរៀល នៅឆ្នាំ២០៣០ | ប្រភពទិន្នន័យពីក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) |
| | តម្លៃបន្ថែមសរុបនៃផលិតផលនេសាទកើនឡើងយ៉ាងហោចណាស់៤,៣% ក្នុងមួយឆ្នាំ | តម្លៃបន្ថែមសរុបនៃផលិតផលនេសាទកើនឡើងពី៥ ៤៩៣ ពាន់លានរៀល ក្នុងឆ្នាំ២០១៩ ដល់៨ ៧២៩ពាន់លានរៀល នៅឆ្នាំ២០៣០ | ប្រភពទិន្នន័យពីក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) |

## គោលដៅយុទ្ធសាស្ត្រទី៤ : "ពង្រឹងអភិបាលកិច្ចនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"

| វិធានការគោលនយោបាយ | សូចនាករ | សូចនាករវឌ្ឍនភាព/សូចនាករសមិទ្ធកម្មបង្ហាញ | មធ្យោបាយផ្ទៀងផ្ទាត់/ប្រភពទិន្នន័យ |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី៤ | កែទម្រង់រចនាសម្ព័ន្ធអង្គភាពនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | រចនាសម្ព័ន្ធអង្គភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានកែសម្រួល | ប្រភពទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ត្រូវបានបង្កើត | - ចំនួនច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ត្រូវបានបង្កើត<br>- ចំនួនច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័ត និងជំរុញឱ្យអនុវត្ត | ប្រភពទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | អត្រានិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ/ | - អត្រា (%) នៃនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ | ប្រភពទិន្នន័យពីក្រសួងកសិកម្ម |

| | | | |
|---|---|---|---|
| | វិទ្យាស្ថានដែលសិក្សាផ្នែកកសិកម្ម ឬមុខជំនាញពាក់ព័ន្ធទទួលបានការងារធ្វើ | - អត្រា (%) នៃនិស្សិតបញ្ចប់ការសិក្សាដែលមានជំនាញវិជ្ជាជីវៈ ទាំងស្ត្រី និងបុរស មានឱកាសបង្កើតការងារ | រុក្ខាប្រមាញ់ និងនេសាទ |

## ឧបសម្ព័ន្ធ២ : ម៉ាទ្រិកស្តីពីវិធានការគោលនយោបាយ/ផែនការសកម្មភាពជាក់លាក់

| ល.រ. | វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | | | ស្ថាប័ន/អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|
| | | ២០២២-២០២៣ | ២០២៤-២០២៦ | ២០២៧-២០៣០ | |
| **ក- ការធ្វើទំនើបកម្មនិងពាណិជ្ជូបនីយកម្មខ្សែច្រវាក់តម្លៃកសិកម្ម** | | | | | |
| ១ | **បង្កើនផលិតភាពនិងតម្លៃបន្ថែមនៃខ្សែច្រវាក់តម្លៃដំណាំ**<br><br><u>សូចនាករ</u><br>- តម្លៃនៃផលិតផលដំណាំក្រៅពីស្រូវកើនឡើងពី១៦ ០០០ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់២០ ៨០០ពាន់លានរៀលនៅឆ្នាំ២០៣០<br>- តម្លៃនៃផលិតផលស្រូវកើនឡើងពី៧ ៤០០ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់៩ ៧៥៦ពាន់លានរៀលនៅឆ្នាំ២០៣០<br>- កំណើន(%) បរិមាណនាំចេញផលិតផលកសិកម្មកើន៧% ក្នុងអំឡុងឆ្នាំ២០២០-២០២៥ និង៦% ក្នុងអំឡុងឆ្នាំ២០២៦-២០៣០។ | | | | |
| ១.១ | បង្កើនផលិតភាពដំណាំអាទិភាព តាមរយៈការគាំទ្របច្ចេកទេសកសិកម្មទំនើប | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងធនធានទឹក និងឧតុនិយម |
| ១.២ | បង្កើនពិពិធកម្មក្នុងផលិតកម្មនិងកាត់បន្ថយហានិភ័យពីការដាំដំណាំតែមួយមុខ និងរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំនីមួយៗ | √ | √ | √ | |
| ១.៣ | អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនការធ្វើយន្តកម្មផលិតកម្មដំណាំ | √ | √ | √ | |
| ១.៤ | ការលើកកម្ពស់ឧស្សាហកម្មគ្រាប់ពូជដំណាំ និងធាតុចូលសម្រាប់ដំណាំកសិកម្ម | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ១.៥ | កែលម្អគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម និងកសិពាណិជ្ជកម្ម ព្រមទាំងរៀបចំស្តង់ដាផលិតផលកសិកម្ម | √ | √ | √ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- វិស័យឯកជនពាក់ព័ន្ធ |
| ១.៦ | កំណត់តំបន់ដាំដុះនិងកសាងផែនទីដាំដុះដំណាំកសិកម្ម | √ | √ | | |
| ១.៧ | ពង្រឹងការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម និងបង្កើនសមត្ថភាពពិសោធន៍កសិកម្ម | √ | √ | √ | |
| ១.៨ | ពង្រឹងសេវាកម្មគាំទ្រនិងការអភិវឌ្ឍធនធានមនុស្សក្នុងផលិតកម្មដំណាំ | √ | √ | √ | |
| ២ | **បង្កើនផលិតភាពនិងតម្លៃបន្ថែមនៃខ្សែច្រវាក់តម្លៃកៅស៊ូ**<br>**សូចនាករ**<br>- បង្កើនផ្ទៃដីកៅស៊ូចៀរជ័រពី២៥០ ៥០០ហ.ត.នៅឆ្នាំ២០១៩ ដល់៣៣១ ០០០ហ.ត.នៅឆ្នាំ២០៣០<br>- បង្កើនផលិតកម្មកៅស៊ូពី២៨៧ ៦០០តោនក្នុងឆ្នាំ២០១៩ ដល់៤៦៣ ០០០តោននៅឆ្នាំ២០៣០<br>- បង្កើនចំណូលសរុបពី៣៧៧លានដុល្លារក្នុងឆ្នាំ២០១៩ ដល់៩៦១លានដុល្លារអាមេរិកនៅឆ្នាំ២០៣០។ | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា<br>- ធនាគារសហគ្រាសធុនតូច និងមធ្យម<br>- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ២.១ | ពង្រឹងនិងកែលម្អខ្សែច្រវាក់តម្លៃផលិតកម្មកៅស៊ូ តាមរយៈការពង្រីកបច្ចេកទេសផលិតកម្មកៅស៊ូប្រកបដោយនិរន្តរភាព ពង្រឹងសហគមន៍កៅស៊ូគ្រួសារ និងអភិវឌ្ឍទីផ្សារកៅស៊ូ | √ | √ | √ | |
| ២.២ | ពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដោយបង្កើនបណ្តាញផ្ទេរបច្ចេកវិទ្យាដល់អ្នកផលិតកៅស៊ូ ដើម្បីបង្កើនគុណភាពនិងផលិតភាពកៅស៊ូ ពង្រឹងស្តង់ដាកៅស៊ូស្របតាមតម្រូវការទីផ្សារ | √ | √ | √ | |
| ២.៣ | លើកកម្ពស់ការវិនិយោគផ្ទាល់ពីបរទេសលើការអភិវឌ្ឍកៅស៊ូនិងធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ ដើម្បីគាំទ្រផលិតកម្មនិងការអភិវឌ្ឍកៅស៊ូប្រកបដោយចីរភាព | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ៣ | **បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មសត្វ**<br>**សូចនាករ**<br>- តម្លៃទឹកប្រាក់ផលិតផលសត្វសរុបត្រូវបង្កើនពី៧ ៣០៨ពាន់លានរៀលក្នុងឆ្នាំ២០១៩ ដល់៩ ៦០០ពាន់លានរៀលនៅឆ្នាំ២០៣០<br>- អត្រា(%) នៃការផ្គត់ផ្គង់សាច់ក្នុងស្រុកកើនឡើងពី៨០%ក្នុងឆ្នាំ២០១៩ ដល់៩០%នៅឆ្នាំ២០៣០<br>- ការចិញ្ចឹមសត្វសម្រាប់គោលបំណងពាណិជ្ជកម្មកើនឡើងពី៣០%ក្នុងឆ្នាំ២០១៩ ដល់៦៣%នៅឆ្នាំ២០៣០។ | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងរ៉ែ និងថាមពល (អគ្គិសនីកម្ពុជា)<br>- ធនាគារសហគ្រាសធុនតូច និងមធ្យម<br>- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ៣.១ | ជំរុញការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ និងរៀបចំធ្វើបច្ចុប្បន្នភាពផែនការនេះសម្រាប់អនុវត្តរយៈពេល១០ឆ្នាំទៅមុខទៀត | √ | √ | √ | |
| ៣.២ | លើកកម្ពស់ផលិតកម្មសត្វដែលមានភាពប្រកួតប្រជែងនិងបរិយាបន្ន(អនុវត្តការចិញ្ចឹមសត្វល្អ កែលម្អពូជសត្វ បច្ចេកទេស គុណភាព សុវត្ថិភាពចំណី ការបង្កាត់ពូជសត្វ ...)។ | √ | √ | √ | |
| ៣.៣ | លើកកម្ពស់សុខភាពសត្វ សុខុមាលភាពសត្វ និងសុខភាពសាធារណៈ(ជីវសុវត្ថិភាព កាត់បន្ថយអត្រាឈឺស្លាប់ ផលិតវ៉ាក់សាំង បសុឱសថ ព្យាបាល អនាម័យសត្វ សាច់ និងផលិតផលសត្វ ពិឃាតសត្វដោយសមានធម៌ មន្ទីរពិសោធន៍វិនិច្ឆ័យជំងឺសត្វ) | √ | √ | √ | |
| ៣.៤ | លើកកម្ពស់ការផ្សព្វផ្សាយលើការអនុវត្តបច្ចេកទេសនិងការបណ្តុះបណ្តាល ព្រមទាំងពង្រឹងការអនុវត្តច្បាប់ ជំរុញការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ | √ | √ | √ | |
| ៣.៥ | លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងអនុវិស័យសុខភាពនិងផលិតកម្មសត្វ | √ | √ | √ | |
| ៣.៦ | សម្របសម្រួលការវិនិយោគឯកជនលើការចិញ្ចឹមសត្វ ការបង្កើតរោងចក្រផលិតចំណីសត្វ ផលិតវ៉ាក់សាំង និងផលិតបសុឱសថ ព្រមទាំងការកែច្នៃសម្រាប់ការនាំចេញ | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ៣.៧ | ជំរុញលើកទឹកចិត្តការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារតាមទីជនបទ ដែលជាប្រភពចំណូលបន្ថែមរបស់កសិករខ្នាតតូច រួមទាំងផ្តល់ធាតុចូលកសិកម្មដែលមានផលវិជ្ជមានដល់ការធ្វើស្រែចម្ការ។ | √ | √ | √ | |
| ៤ | **លើកកម្ពស់ការអភិវឌ្ឍកសិឧស្សាហកម្ម និងកសិទេសចរណ៍**<br>**<u>សូចនាករ</u>**<br>អត្រា(%) នៃការនាំចេញផលិតផលកសិកម្មកែច្នៃធៀបនឹងការនាំចេញសរុប<br>ចំណុចដៅ : ១០%នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ និង១៥%នៅឆ្នាំ២០៣០។ | | | | |
| ៤.១ | ធ្វើឱ្យប្រសើរឡើងនិងទំនើបកម្មផ្នែកកសិឧស្សាហកម្ម ដោយត្រូវពង្រឹងសមត្ថភាពផលិតដល់សហគ្រាសធុនតូចនិងមធ្យម ឆ្លើយតបតាមស្តង់ដាគុណភាព និងសុវត្ថិភាពចំណីអាហារ | √ | √ | √ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងទេសចរណ៍<br>- សភាពាណិជ្ជកម្មកម្ពុជា |
| ៤.២ | សិក្សានិងបង្កើតសួនកសិឧស្សាហកម្មនៅកម្ពុជាសម្រាប់ប្រមូលផ្តុំសហគ្រាសកែច្នៃផលិតផលកសិកម្មដើម្បីផលិតបម្រើឱ្យការនាំចេញ | √ | √ | | |
| ៤.៣ | លើកកម្ពស់កសិទេសចរណ៍ក្នុងខ្សែច្រវាក់ផលិតកម្មនៃវិស័យកសិកម្ម | √ | √ | √ | |
| ៤.៤ | ពង្រឹងនិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាព សុវត្ថិភាពសម្រាប់ផល ផលិតផលកសិកម្មដោយអនុលោមតាមស្តង់ដាអន្តរជាតិ | √ | √ | √ | |
| ៤.៥ | ពង្រឹងនិងអភិវឌ្ឍប្រព័ន្ធទីផ្សារប្រកបដោយនិរន្តរភាពនិងបរិយាបន្នសម្រាប់ផល ផលិតផលកសិកម្មតាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា | √ | √ | √ | |
| ៥ | **បង្កើនផលិតភាពតាមការអនុវត្តបច្ចេកវិទ្យាទំនើបក្នុងខ្សែច្រវាក់តម្លៃកសិកម្ម**<br>**<u>សូចនាករ</u>**<br>- អត្រា (%) របស់ផលិតករកសិកម្ម/ សហគមន៍កសិកម្មដែលមានវិញ្ញាបនបត្រ GAP កើនឡើង<br>ចំណុចដៅ : កសិដ្ឋាននៃសហគមន៍កសិកម្មយ៉ាងតិច៤០% មានវិញ្ញាបនបត្រ GAP នៅឆ្នាំ២០៣០<br>- អត្រា (%) នៃការប្រើប្រាស់ថាមពលកកើតឡើងវិញក្នុងផលិតកម្មកសិកម្មកើនឡើង។ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.១ | ជំរុញការអនុវត្តបច្ចេកទេសកសិកម្មទំនើប (ប្រព័ន្ធដំណក់ទឹក ការគ្រប់គ្រងសត្វល្អិតចង្រៃ កសិដ្ឋានមានដំបូល/ សំណាញ់) | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងរ៉ែ និងថាមពល (អគ្គិសនីកម្ពុជា)<br>- ធនាគារសហគ្រាសធុនតូច និងមធ្យម<br>- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម<br>- សមាគម និងវិស័យឯកជនពាក់ព័ន្ធ |
| ៥.២ | លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ សូឡាបូមទឹក ជំរុញសហគ្រាសកសិកម្មឱ្យប្រើបច្ចេកវិទ្យាកសិកម្មវៃឆ្លាត និងការកសាងនិងប្រើប្រាស់ឡជីវឧស្ម័ន | √ | √ | √ | |
| ៥.៣ | លើកកម្ពស់និងអនុវត្តផលិតកម្មកសិកម្មសរីរាង្គ (CamOrganic) អនុវត្តកសិកម្មល្អ (CamGAP) និងកសិកម្មដែលវៃឆ្លាតនឹងអាកាសធាតុ ជាមួយនឹងការអនុវត្តនូវបច្ចេកវិទ្យាវៃឆ្លាតនិងទំនើប | √ | √ | √ | |
| ៥.៤ | ពង្រឹងការផ្សព្វផ្សាយកសិកម្មដោយប្រើបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ទំនើប ដើម្បីផ្សព្វផ្សាយដល់កសិករទាំងអស់ ដោយប្រើប្រព័ន្ធដែលផ្អែកលើតម្រូវការ និងការគាំទ្រចំគោលដៅប្រកបដោយគុណភាពខ្ពស់ | √ | √ | √ | |
| ៥.៥ | ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតនៅគ្រប់ដំណាក់កាលនៃផលិតកម្មកសិកម្ម ពិសេសក្រោយពេលប្រមូលផលដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ | √ | √ | √ | |
| **៦** | **បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃវារីវប្បកម្ម**<br>**<u>សូចនាករ</u>**<br>តម្លៃផលវារីវប្បកម្មកើនឡើងពី ៦១៥លានដុល្លារនៅឆ្នាំ២០១៩ ដល់ ១ ២០០លានដុល្លារនៅឆ្នាំ២០៣០។ | | | | |
| ៦.១ | ពង្រឹងការងារស្រាវជ្រាវពូជ ពង្រីកផលិតកម្មពូជ បច្ចេកទេសចិញ្ចឹមទំនើប រួមទាំងស្រាវជ្រាវកែលម្អពូជត្រីធម្មជាតិនិងអភិរក្សពូជត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដើម្បីបង្កាត់ពូជឱ្យបានកាន់តែច្រើន សម្រាប់ចែកចាយលែងក្នុងទន្លេ បឹង ស្រះធម្មជាតិ និងចែកជូនប្រជាពលរដ្ឋ ដើម្បីចិញ្ចឹមតាមបែបធម្មជាតិតាមវាលស្រែ | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងធនធានទឹកនិងឧតុនិយម |
| ៦.២ | សិក្សាអំពីសក្តានុពលនៃទីតាំង ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវគាំទ្រ និងបរិស្ថានដែលអំណោយផលដើម្បីបង្កើតតំបន់វារីវប្បកម្ម | √ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៦.៣ | ចងក្រងបណ្តុំវារីវប្បករទៅតាមតំបន់នីមួយៗ ដើម្បីបង្កើនសមត្ថភាពផលិតកម្ម ងាយស្រួលក្នុងការផ្តល់បច្ចេកទេស ឥណទាន និងទីផ្សារ | √ | √ | √ | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៦.៤ | រៀបចំផែនការផលិតកម្មនិងសកម្មភាពវារីវប្បកម្មជាក់លាក់ទៅតាមប្រភេទវារីសត្វ ព្រមទាំងរៀបចំបង្កើតបណ្តុំអាជីវករ/អ្នកប្រមូលទិញនិងភ្ជាប់ទៅកាន់ទីផ្សារតាមរយៈការអនុវត្តនូវយន្តការ "ផលិតកម្មវារីវប្បកម្មតាមកិច្ចសន្យា" រវាងបណ្តុំវារីវប្បករ និងបណ្តុំអាជីវករ | √ | √ | | - ក្រសួងរ៉ែ និងថាមពល (អាជ្ញាធរអគ្គិសនីកម្ពុជា)<br>- ក្រសួងបរិស្ថាន<br>- សមាគមវារីវប្បកម្មកម្ពុជា<br>- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ៦.៥ | សម្របសម្រួលដល់វារីវប្បករក្នុងការទទួលបាននូវតម្លៃអគ្គិសនីសមស្រប ដើម្បីជំរុញការធ្វើវារីវប្បកម្មនិងការបង្កើតរោងចក្រកែច្នៃផលវារីវប្បកម្មសម្រាប់នាំចេញ | √ | √ | | |
| ៦.៦ | សម្របសម្រួលដល់វារីវប្បករក្នុងការទទួលបាននូវឥណទាន ដែលមានអត្រាការប្រាក់ទាបសមរម្យ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម | √ | √ | | |
| ៦.៧ | ពិនិត្យលទ្ធភាពលើការលើកលែងឬព្យួរអាករលើតម្លៃបន្ថែមនិងពន្ធនាំចូលគ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខារ ឧបករណ៍ដែលបម្រើដល់ការជំរុញនិងអភិវឌ្ឍន៍វារីវប្បកម្ម | √ | | | |
| ៦.៨ | សិក្សាលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់ការធ្វើវារីវប្បកម្មទឹកសាបនៅតាមតំបន់ដីសណ្តទន្លេមេគង្គកម្ពុជានិងសិក្សាលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់ការធ្វើវារីវប្បកម្មសមុទ្រសម្រាប់ការនាំចេញ | √ | | | |
| ៦.៩ | រៀបចំផែនការនៃការបង្កើតទីផ្សារផលវារីវប្បកម្មនិងមានការគាំទ្រនូវមធ្យោបាយដឹកជញ្ជូនផលវារីវប្បកម្មទៅដល់កន្លែងចែកចាយនៅតាមរាជធានី/ខេត្តដល់បណ្តុំវារីវប្បករ | √ | √ | | |
| ៧ | **បង្កើនផលិតភាពនិងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់តម្លៃព្រៃឈើនិងសត្វព្រៃ**<br>**<u>សូចនាករ</u>**<br>- តម្លៃជាទឹកប្រាក់នៃផលិតកម្មឈើដាំកើនឡើង១៥%ក្នុងមួយឆ្នាំៗ។ | | | | |
| ៧.១ | ពង្រឹងនិងកែលម្អខ្សែច្រវាក់តម្លៃផលិតកម្មព្រៃឈើនិងសត្វព្រៃ តាមរយៈការពង្រឹងបច្ចេកវិទ្យាផលិតកម្មនិងកែច្នៃប្រកបដោយនិរន្តរភាពនិងពង្រឹងសមត្ថភាព | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | |
|---|---|---|---|---|---|
| | សហគមន៍ព្រៃឈើ | | | | និងអង្គភាពជំនាញក្រោមឱវាទ |
| ៧.២ | ពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ ដោយបង្កើនបណ្តាញផ្ទេរបច្ចេកវិទ្យាដល់អ្នកអ្នកពាក់ព័ន្ធដើម្បីបង្កើនគុណភាពនិងផលិតភាពព្រៃឈើនិងសត្វព្រៃ ពិសេសបង្កើនសមត្ថភាពបច្ចេកទេសក្នុងការសិក្សា ពិសោធន៍ស្រាវជ្រាវប្រភេទពូជឈើឆាប់ផ្តល់ផលនិងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ | √ | √ | √ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងបរិស្ថាន<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- វិស័យឯកជនពាក់ព័ន្ធ |
| ៧.៣ | លើកកម្ពស់ការវិនិយោគផ្ទាល់ពីបរទេសលើការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ និងធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ ដើម្បីគាំទ្រផលិតកម្មនិងការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាព | √ | | | |
| ៧.៤ | បង្កើនផលិតកម្មព្រៃឈើដែលមានភាពប្រកួតប្រជែងនិងបរិយាបន្ន តាមរយៈការជំរុញការអនុវត្តគម្រោងសហការដាំព្រៃឈើឡើងវិញជាមួយវិស័យឯកជន | √ | | | |
| ៧.៥ | លើកកម្ពស់ការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាព ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយការអនុវត្តបច្ចេកទេស ព្រមទាំងពង្រឹងការអនុវត្តច្បាប់និងគោលនយោបាយ | √ | √ | √ | |
| ៧.៦ | លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងអនុវិស័យព្រៃឈើនិងសត្វព្រៃ | √ | √ | √ | |
| ៧.៧ | ពង្រឹងការគ្រប់គ្រងនិងបច្ចេកទេសកែច្នៃឈើដាំឱ្យស្របតាមស្តង់ដាសម្រាប់បម្រើដល់ការនាំចេញនូវផលិតផលឈើដាំ | √ | √ | √ | |
| **៨** | **ពង្រឹងប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព** | | | | |
| ៨.១ | អនុវត្តវិធានការបច្ចេកទេសសំដៅធ្វើឱ្យមាននូវអាហារដែលមានសុវត្ថិភាពនិងមានអាហារូបត្ថម្ភគ្រប់គ្រាន់ដើម្បីកាត់បន្ថយបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ ដោយរួមបញ្ចូលការលើកកម្ពស់យេនឌ័រ | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ |

| | | | | | |
|---|---|---|---|---|---|
| ៨.២ | ជំរុញឱ្យមានប្រពន្ធ័ស្បៀងអាហារកាន់តែមានប្រសិទ្ធភាព បរិយាបន្ននិងធន់ជាងមុន ដែលអាចបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ដោយត្រូវជំរុញការធ្វើទំនើបកម្មនៃផលិតកម្មស្បៀងអាហារ | √ | √ | √ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ<br>- ក្រសួងផែនការ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងសុខាភិបាល |
| ៨.៣ | អនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ | √ | √ | √ | |
| ៨.៤ | អនុវត្តនូវវិធានការកាត់បន្ថយការបាត់បង់ស្បៀងអាហារតាមបណ្តោយខ្សែច្រវាក់តម្លៃកសិកម្ម | √ | √ | √ | |
| **៩** | **ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្ម** | | | | |
| ៩.១ | បង្កើតប្រព័ន្ធគាំទ្រកសិកម្មតាមបែបឌីជីថលដើម្បីជំរុញផលិតកម្មកសិកម្ម រួមទាំងការចែករំលែកព័ត៌មានកសិកម្មទាន់ពេលវេលា | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងព័ត៌មាន<br>- ក្រសួងអប់រំ យុវជន និងកីឡា |
| ៩.២ | បង្កើតនិងអនុវត្តឧបករណ៍សម្រាប់ឌីជីថលនីយកម្មក្នុងការអប់រំ ការបណ្តុះបណ្តាល និងការងារផ្សព្វផ្សាយកសិកម្ម ព្រមទាំងលើកទឹកចិត្តដល់ការប្រើប្រាស់ឧបករណ៍ឌីជីថលនិងឧបករណ៍ឆ្លាតវៃដោយកសិករទាំងបុរសនិងស្ត្រី | √ | √ | | |
| ៩.៣ | បង្កើតនិងសម្របសម្រួលដល់ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់កសិពាណិជ្ជកម្ម | √ | √ | | |
| ៩.៤ | ផ្តល់សេវាកម្មដោយប្រើបច្ចេកវិទ្យាឌីជីថល ជាពិសេសគាំទ្រដល់ប្រព័ន្ធផ្តល់វិញ្ញាបនបត្រ ការចេញលិខិតអនុញ្ញាត ការផ្លាស់ប្តូរព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ សមស្របតាមស្តង់ដាតម្រូវការជាតិនិងអន្តរជាតិ | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ៩.៥ | គាំទ្រដល់ការអភិវឌ្ឍនិងការគ្របដណ្តប់ទូលំទូលាយនៃបណ្តាញឌីជីថលនៅទូទាំងប្រទេសកម្ពុជា រួមទាំងតំបន់ជនបទនិងតំបន់កសិកម្ម ដើម្បីសម្រួលដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ | √ | √ | √ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- វិស័យឯកជនពាក់ព័ន្ធ |
| ៩.៦ | អនុវត្តសាកល្បងសេវាផ្សព្វផ្សាយកសិកម្មដែលប្រើបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងទំនើប លើបច្ចេកវិទ្យាកសិកម្មជាក់លាក់និងវិស័យអាទិភាព (ផលិតកម្មស្រូវ កៅស៊ូ សត្វ វារីវប្បកម្ម) | √ | √ | √ | |
| ៩.៧ | អនុវត្តសាកល្បងគំនិតនៃការដាក់បញ្ចូលកសិករវ័យក្មេង ជាអ្នកសម្របសម្រួលបន្ថែមលើភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលទទួលការបណ្តុះបណ្តាលលើបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ដែលគាំទ្រដោយអ្នកអភិវឌ្ឍបច្ចេកវិទ្យាវៃឆ្លាត | √ | √ | | |
| ៩.៨ | ពង្រឹងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) | √ | √ | √ | |
| ៩.៩ | សម្របសម្រួលការស្រាវជ្រាវនិងអនុវត្តសាកល្បងវេទិកាឌីជីថលសម្រាប់កៀរគរការវិនិយោគសាធារណៈលើការដាំឈើវិបុលកម្មនិងចិញ្ចឹមសត្វព្រៃ | √ | √ | √ | |
| **១០** | **ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារសម្រាប់កសិករខ្នាតតូចនិងមធ្យម** | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១០.១ | បង្កើតនិងពង្រឹងសហគមន៍កសិកម្មដើម្បីកែលម្អលទ្ធភាពចូលទៅកាន់ទីផ្សារតាមរយៈកិច្ចព្រមព្រៀងអាជីវកម្មឬយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា | √ | √ | √ | |
| ១០.២ | ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារសម្រាប់កសិករខ្នាតតូចនិងមធ្យមតាមរយៈការរៀបចំផ្សព្វផ្សាយតាំងលក់ផលិតផលកសិកម្មនៅតាមបណ្តារាជធានីខេត្ត | √ | √ | √ | |
| ១០.៣ | ជំរុញការអនុវត្តបច្ចេកទេសសមស្របនិងធាតុចូល ដើម្បីធានាការចំណាយទាបនៃផលិតកម្ម សំដៅបង្កើនការប្រកួតប្រជែងរបស់កសិករខ្នាតតូចនិងមធ្យម | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ១០.៤ | បង្កើតលទ្ធភាពចូលទៅកាន់ទីផ្សារ ជាមួយនឹងតម្លៃថេរក្នុងរដូវប្រមូលផល (ចង ក្រងបណ្ដុំអាជីវកម្មដោយភ្ជាប់ទីផ្សារតាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា) | √ | √ | √ | |
| ១០.៥ | ធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់ខ្សែច្រវាក់តម្លៃក្នុងចំណោមតួអង្គនានា ដោយត្រូវផ្សព្វផ្សាយដល់កសិករក្នុងការរៀបចំការផលិតនូវផលិតផលកសិកម្មស្របគ្នាជាមួយតម្រូវការផ្គត់ផ្គង់លើទីផ្សារ | √ | √ | √ | |
| ១០.៦ | ពង្រីកសេវាកម្មព័ត៌មានទីផ្សារកសិកម្មដល់កសិករខ្នាតតូចនិងមធ្យម សំដៅភ្ជាប់ទីផ្សារកសិកម្មនិងកសាងទំនុកចិត្តក្នុងចំណោមតួអង្គនៃខ្សែច្រវាក់តម្លៃលើតម្លៃកសិផល | √ | √ | √ | |
| ១០.៧ | បង្កើតសមាគមកសិករនិងអ្នកកែច្នៃកសិផលសម្រាប់បង្កភាពងាយស្រួលក្នុងការចែកចាយនិងគ្រប់គ្រងតម្លៃទីផ្សារ | √ | √ | | |
| ១០.៨ | ជំរុញការបញ្ចូលសកម្មភាពទេសចរណ៍និងអេកូទេសចរណ៍ទៅក្នុងសហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍ដែលមានសក្ដានុពលដទៃទៀត | √ | √ | √ | |
| **ខ- ការវិនិយោគសាធារណៈនិងឯកជនក្នុងវិស័យកសិកម្ម** | | | | | |
| ១ | **បង្កើនប្រសិទ្ធភាពនៃការស្រោចស្រពកសិកម្ម**<br>**<u>សូចនាករ</u>**<br>អត្រា (%) ផ្ទៃដីដំណាំស្រូវដែលអាចទទួលការស្រោចស្រព (វស្សានិងប្រាំង) កើនឡើង<br>ចំណុចដៅ : កើនឡើងពី៦១,១៨%នាឆ្នាំ២០១៩ ដល់ប្រមាណ៧០%នៅឆ្នាំ២០៣០។ | | | | - ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- វិស័យឯកជនពាក់ព័ន្ធ |
| ១.១ | ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកធារាសាស្ត្រកសិកម្ម | √ | √ | √ | |
| ១.២ | គ្រប់គ្រងនិងអភិវឌ្ឍធនធានទឹកនិងអនុវត្តការពង្រីកប្រព័ន្ធធារាសាស្ត្រ | √ | √ | √ | |
| ១.៣ | គ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ១.៤ | គ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម | √ | √ | √ | |
| ១.៥ | បង្កើនការការពារនិងអភិរក្សធនធានទឹក | √ | √ | √ | |
| ១.៦ | ធ្វើផែនទីនិងកំណត់តំបន់ស្រោចស្រពកសិកម្មដើម្បីធ្វើផែនការផលិតកម្មកសិកម្មសមស្រប | √ | √ | | |
| ១.៧ | ការកំណត់និងធ្វើអាទិភាពដល់តំបន់សក្តានុពលសម្រាប់ប្រព័ន្ធធារាសាស្ត្រ | √ | √ | | |
| ១.៨ | សាងសង់និងស្តារស្ថានីយបូមទឹកសម្រាប់បម្រើឱ្យការងារកសិកម្ម | √ | √ | √ | |
| ១.៩ | បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកក្នុងតំបន់កសិកម្មដែលទទួលបានការស្រោចស្រព | √ | √ | √ | |
| ១.១០ | ជំរុញលើកទឹកចិត្តស្តារព្រែក បឹង អូរ ស្រះ ត្រពាំងធម្មជាតិ សម្រាប់ស្តុកទឹកអន្តរាគមន៍ពេលមានគ្រោះរាំងស្ងួតជាអន្តរកាលនិងជួយពន្លឿនការរំដោះទឹកជំនន់ | √ | √ | √ | |
| ២ | **ពង្រីកការភ្ជាប់ផ្លូវចូលទៅកសិដ្ឋានបណ្តាញអគ្គិសនីនិងការដឹកជញ្ជូនផលិតផលកសិកម្ម**<br>**សូចនាករ**<br>- ប្រវែង(គីឡូម៉ែត្រ) ផ្លូវជនបទតភ្ជាប់ទៅកសិដ្ឋានត្រូវបានសាងសង់<br>- ៣០% នៃសហគមន៍កសិកម្មទទួលបានអគ្គិសនីមានតម្លៃអនុគ្រោះ | | | | |
| ២.១ | បន្តបង្កើនថវិកាវិនិយោគដើម្បីកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រកសិកម្មដោយត្រូវពង្រីកការតភ្ជាប់ផ្លូវចូលកសិដ្ឋាន ទីផ្សារ និងសហគ្រាសកសិកម្មឱ្យបានល្អប្រសើរ | √ | √ | √ | |
| ២.២ | ពង្រីកការគ្របដណ្តប់និងបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ ដោយសាងសង់ស្ថានីយបន្ថែមនៅតំបន់សក្តានុពលកសិកម្ម ពិសេសពង្រីកបណ្តាញអគ្គិសនីសម្រាប់ផលិតកម្មកសិកម្មក្នុងសហគមន៍កសិកម្មនិងសហគ្រាសកែច្នៃផលិតផលកសិកម្ម | √ | √ | √ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| | | | | | |
|---|---|---|---|---|---|
| ២.៣ | ពិនិត្យលទ្ធភាពបង្កើនថវិកានិងគ្រប់គ្រងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការងារផលិតកម្មកសិកម្ម | √ | √ | | - ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងរ៉ែ និងថាមពល (អគ្គិសនីកម្ពុជា)<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ |
| ២.៤ | ពង្រីកប្រព័ន្ធឡូជីស្ទិកសម្រាប់ផលិតផលកសិកម្ម ដើម្បីផ្តល់នូវការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការដឹកជញ្ជូនកសិផល រួមទាំងការរៀបចំបង្កើតផ្សារបោះដុំកសិផលនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រោយពេលប្រមូលផលចាំបាច់ផ្សេងទៀត | √ | √ | √ | |
| ៣ | **លើកកម្ពស់ការវិនិយោគកសិកម្មនិងកិច្ចសម្រួលកសិពាណិជ្ជកម្ម**<br>**<u>សូចនាករ</u>**<br>-ទុនវិនិយោគផ្ទាល់ពីបរទេសនិងវិនិយោគក្នុងស្រុកសម្រាប់វិស័យកសិកម្ម និងកសិឧស្សាហកម្មកើនឡើង១០%ក្នុងមួយឆ្នាំ។ | | | | |
| ៣.១ | ជំរុញវិស័យឯកជនឱ្យបង្កើនការវិនិយោគក្នុងវិស័យកសិកម្ម ពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍកសិកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនិងវិនិយោគ | √ | √ | √ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងពាណិជ្ជកម្ម<br>- សភាពាណិជ្ជកម្មកម្ពុជា |
| ៣.២ | លើកទឹកចិត្តនិងផ្តល់ការថែទាំការវិនិយោគក្នុងស្រុកនិងបរទេសក្នុងវិស័យកសិកម្ម តាមរយៈការបង្កើតគោលនយោបាយ បទប្បញ្ញត្តិពាក់ព័ន្ធ និងជំរុញការអនុវត្តច្បាប់ស្តីពីវិនិយោគ | √ | √ | √ | |
| ៣.៣ | សម្របសម្រួលវិនិយោគលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេសសម្រាប់កែច្នៃផលិតផលកសិកម្មនាំចេញ | √ | √ | | |
| ៣.៤ | ពង្រីកភាពជាដៃគូរវាងវិស័យសាធារណៈនិងផ្នែកឯកជន តាមរយៈការបង្កើតសហព័ន្ធកសិឧស្សាហកម្មកម្ពុជា | √ | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.៥ | បន្តកែទម្រង់និងការពង្រឹងសមត្ថភាពស្ថាប័នក្នុងការផ្តល់សេវា កាត់បន្ថយចំណាយលើការធ្វើធុរកិច្ច ដោយពិនិត្យជាចាំបាច់លើបញ្ហាបទប្បញ្ញត្តិ នីតិវិធីនៃការអនុវត្ត សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | √ | √ | | |
| ៣.៦ | លើកទឹកចិត្តបង្កើតនិងពង្រីកភាពជាដៃគូរវាងរដ្ឋនិងឯកជន លើការបង្កើតរោងចក្រផលិតជីកសិកម្ម និងចំណីសត្វក្នុងស្រុកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាការផ្គត់ផ្គង់ជីនិងចំណីសត្វមានគុណភាពខ្ពស់ ថ្លៃសមស្របដែលធានាបាននូវផលិតផលកសិកម្មមានទិន្នផល និងសុវត្ថិភាពខ្ពស់ សម្រាប់ប្រជែងបានទាំងក្នុងស្រុក តំបន់ និងទីផ្សារអន្តរជាតិ | √ | √ | √ | |
| ៣.៧ | លើកកម្ពស់ការវិនិយោគទៅលើវិបុលកម្មសត្វព្រៃដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ដោយបង្កលក្ខណៈអំណោយផលដែលផ្តល់ការលើកទឹកចិត្តវិស័យឯកជននៅក្នុងការធ្វើវិបុលកម្មសត្វព្រៃ | √ | √ | √ | |
| ៣.៨ | ជំរុញការវិនិយោគលើគម្រោងបង្កើតមូលដ្ឋានឧស្សាហកម្មកែច្នៃឈើដាំ | √ | √ | √ | |
| ៤ | **បង្កើនធនធានហិរញ្ញវត្ថុនិងឥណទានក្នុងវិស័យកសិកម្ម**<br>**សូចនាករ**<br>ប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្មសម្រាប់វិស័យកសិកម្មកើនឡើង<br>ចំណុចដៅ : អត្រា(%) នៃប្រាក់កម្ចីក្រៅពីស្រូវកើនពី២៣% នាឆ្នាំ២០១៩ ដល់៤៧%នៅឆ្នាំ២០៣០។ | | | | - ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា |
| ៤.១ | បង្កើនការប្រើប្រាស់ថវិកាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដែលឆ្លើយតបនឹងភាពចាំបាច់និងតម្រូវការរបស់អ្នកផលិត អ្នកកែច្នៃ និងអ្នកនាំចេញ | √ | √ | | |
| ៤.២ | សម្របសម្រួលនិងអភិវឌ្ឍសេវាកម្មហិរញ្ញវត្ថុនិងផលិតផលហិរញ្ញវត្ថុ ស្របតាមតម្រូវការសម្រាប់កសិដ្ឋានខ្នាតតូចនិងមធ្យម និងកសិធុរកិច្ច | √ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៤.៣ | បង្កើនឥណទានសម្រាប់វិស័យកសិកម្ម ដោយត្រូវបង្កើនទំហំទឹកប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា ដើម្បីបម្រើសេចក្តីត្រូវការហិរញ្ញវត្ថុរបស់អ្នកពាក់ព័ន្ធកសិកម្ម និងកសិឧស្សាហកម្ម | √ | √ | √ | |
| ៤.៤ | ជំរុញឱ្យមានការចូលរួមនិងបង្កើនលទ្ធភាពប្រើប្រាស់សេវាធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម កាន់តែច្រើនបន្ថែមទៀត ដើម្បីបម្រើសេចក្តីត្រូវការហិរញ្ញវត្ថុរបស់តួអង្គនានានៅក្នុងខ្សែច្រវាក់តម្លៃ ពិសេសពង្រីកបន្ថែមនូវឥណទានក្រៅពីស្រូវអង្ករ ដោយបង្កើនឥណទានដល់ការចិញ្ចឹមសត្វ វារីវប្បកម្ម កែច្នៃផលផលិតផលផលជលផល សហគមន៍ ការដាំឈើ ការធ្វើវិបុលកម្ម និងចិញ្ចឹមសត្វព្រៃ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រកសិកម្មផ្សេងទៀត | √ | √ | √ | |
| **គ- កំណើនប្រកបដោយចីរភាពនិងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | |
| ១ | **លើកកម្ពស់ការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃ**<br>**<u>សូចនាករ</u>**<br>- តម្លៃតម្លៃបន្ថែមសរុបនៃផលិតផលព្រៃឈើកើនឡើងពី១ ៤៩០ពាន់លានរៀល ក្នុងឆ្នាំ២០១៩ ដល់១ ៦៩៩ពាន់លានរៀលនៅឆ្នាំ២០៣០<br>- ប្រាក់ចំណូលព្រៃឈើសហគមន៍កើនឡើង២៥%ក្នុងមួយឆ្នាំ។ | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន |
| ១.១ | ជំរុញការគ្រប់គ្រងនិងអភិវឌ្ឍព្រៃឈើ មានភាពធននឹងការប្រែប្រួលអាកាសធាតុ ដោយត្រូវរៀបចំផែនការអភិវឌ្ឍន៍វិស័យព្រៃឈើសម្រាប់អនុវត្តរយៈពេល១០ឆ្នាំទៅមុខ និងរៀបចំយន្តការអនុវត្តផែនការនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ | √ | √ | √ | |
| ១.២ | បង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍព្រៃឈើសហគមន៍ ជំរុញការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ រៀបចំគោលការណ៍ណែនាំស្តីពីការចងក្រងផែនការគ្រប់គ្រងព្រៃសហគមន៍ និងលើកកម្ពស់ជីវភាពសហគមន៍តាមរយៈ | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ២.៤ | ពង្រីកការផ្សព្វផ្សាយជំរុញការចិញ្ចឹមត្រីតាមបែបធម្មជាតិនៅតាមវាលស្រែ តាមទីតាំងណាដែលអាចធ្វើបាន ដើម្បីស្តារត្រីធម្មជាតិឡើងវិញ កែលម្អប្រភពផ្គត់ផ្គង់ត្រីតាមបែបធម្មជាតិ កាត់បន្ថយការប្រើប្រាស់ជី និងថ្នាំគីមីកសិកម្មដែលបំផ្លាញត្រី និងជីវៈចម្រុះ | √ | √ | √ | |
| ២.៥ | ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍ធនធានជលផលដោយផ្ដោតលើការវិភាគខ្សែច្រវាក់តម្លៃ រួមទាំងការគ្រប់គ្រងក្រោយប្រមូលផល | √ | √ | √ | |
| ២.៦ | ជំរុញការអភិវឌ្ឍសមត្ថភាពនិងបច្ចេកវិទ្យាដើម្បីកែលម្អគុណភាពនៃផលរបស់អ្នកនេសាទខ្នាតតូចសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ | √ | √ | √ | |
| ២.៧ | បង្កើនការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផលនិងលើកកម្ពស់ការនាំចេញផលផលិតផលជលផល | √ | √ | √ | |
| ២.៨ | ជំរុញការអនុវត្តគោលនយោបាយគ្រប់គ្រងជលផលសមុទ្រ | √ | √ | √ | |
| ២.៩ | ពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលនិងបទប្បញ្ញត្តិដែលមានសម្រាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ | √ | √ | √ | |
| ២.១០ | ពង្រឹងសមភាពយេនឌ័រនិងលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល | √ | √ | √ | |
| ៣ | **លើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម** | | | | |
| ៣.១ | អនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី | √ | √ | √ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងបរិស្ថាន |
| ៣.២ | ទប់ស្កាត់ការរេចរឹលដីនិងបង្កើនផលិតភាពដី តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ ឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងពង្រីកការអនុវត្តបច្ចេកទេសគ្រប់គ្រងដីកសិកម្ម | √ | √ | √ | |
| ៣.៣ | រៀបចំផែនការសកម្មភាពជាក់លាក់និងអនុវត្តឱ្យបានសកម្ម ដើម្បីទប់ស្កាត់ការខ្សោះជីវជាតិដី គុណភាពទឹក និងការពារធនធានធម្មជាតិ | √ | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.៤ | ធ្វើឱ្យប្រសើរឡើងនូវការអភិរក្សដីកសិកម្មរបស់ប្រទេសកម្ពុជា ដោយត្រូវស្តារទីជម្រាលនិងសេវាកម្មអេកូឡូស៊ី រួមទាំងការជំរុញអនុវត្តបង្ហាញអំពីការអនុវត្តល្អក្នុងការគ្រប់គ្រងដីកសិកម្មនិងការរៀបចំបង្ហាញអំពីប្រសិទ្ធភាពនៃការបញ្ចូលក្បាលដីរួមគ្នាក្នុងការធ្វើផលិតកម្មកសិកម្មបែបយន្តូបនីយកម្ម | √ | √ | √ | |
| ៣.៥ | ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងដីនិងទីជម្រាលដោយចីរភាព | √ | √ | √ | |
| ៣.៦ | លើកកម្ពស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងអេកូឡូស៊ី | √ | √ | √ | |
| ៣.៧ | បង្កើនយុទ្ធសាស្ត្រឬវិធីសាស្ត្រគាំទ្រវិស័យកសិកម្ម មិនមានការប្រើប្រាស់ជីគីមីដែលមិនស្របតាមស្តង់ដា ព្រមទាំងជំរុញកសិកម្មដែលប្រើប្រាស់ជីធម្មជាតិឱ្យមាននិរន្តរភាព | √ | √ | √ | |
| **៤** | **ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ** | | | | - ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងរ៉ែ និងថាមពល (អគ្គិសនីកម្ពុជា) |
| ៤.១ | ជំរុញការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពតាមរយៈការបង្កើតនិងអនុវត្តនូវយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឆ្នាំ២០៣០ | √ | √ | √ | |
| ៤.២ | ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញប្រកបដោយប្រសិទ្ធភាពនិងចីរភាពតាមរយៈការបង្កើតនិងអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ | √ | √ | √ | |
| ៤.៣ | ជំរុញផលិតកម្មនូវផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថាន តាមរយៈការអនុវត្តបច្ចេកទេសកសិកម្មអភិរក្ស | √ | √ | √ | |
| ៤.៤ | សម្របសម្រួលការអភិវឌ្ឍវិស័យកសិកម្មរបស់ប្រទេសកម្ពុជា ឆ្ពោះទៅរកអព្យាក្រឹតកាបូន (Carbon Neutral) | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ៤.៥ | អនុវត្តយុទ្ធសាស្ត្រពាក់ព័ន្ធដើម្បីទប់ទល់នឹងភាពរាំងស្ងួតដែលប៉ះពាល់ដល់ធនធានផលផល រួមទាំងវារីវប្បកម្ម | √ | √ | √ | |
| ៤.៦ | សម្របសម្រួលគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី១២ ដែលជាការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាពឱ្យស្របនឹងគោលនយោបាយនៃការប្រើប្រាស់ដីគីមី | √ | √ | √ | |
| **ឃ- ការកែទម្រង់ស្ថាប័ននិងបញ្ហាអន្តរវិស័យ** | | | | | |
| **១** | **ពង្រឹងអភិបាលកិច្ចនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម** | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១.១ | ធ្វើការកែទម្រង់ការគ្រប់គ្រងស្ថាប័នទៅជារចនាសម្ព័ន្ធដែលមានប្រសិទ្ធភាពជាងមុន រួមទាំងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សប្រកបដោយការគាំទ្រ និងមានប្រសិទ្ធភាពខ្ពស់ | √ | √ | | |
| ១.២ | ពង្រឹងការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងវិស័យកសិកម្ម | √ | √ | √ | |
| ១.៣ | ពង្រឹងគុណភាពនៃការអប់រំកសិកម្ម តាមរយៈការអនុវត្តផែនការមេឆ្នាំ២០៣០ របស់គ្រឹះស្ថានអប់រំកសិកម្មនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យកសិកម្មសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់នូវលទ្ធភាពបង្កើតមុខរបរវិជ្ជាជីវៈដែលទាក់ទាញផ្អែកលើគុណផលនិងមានចំណូលខ្ពស់ | √ | √ | √ | |
| ១.៤ | បង្កើនសមត្ថភាពស្រាវជ្រាវសម្រាប់ការអភិវឌ្ឍកសិកម្ម ធ្វើការស្រាវជ្រាវមូលដ្ឋាន និងការស្រាវជ្រាវបែបអនុវត្តដែលផ្សារភ្ជាប់ទៅនឹងតម្រូវការទីផ្សារ ព្រមទាំងត្រូវរៀបចំនិងអនុវត្តគោលនយោបាយស្រាវជ្រាវកសិកម្មកម្ពុជា | √ | √ | √ | |
| ១.៥ | ពង្រឹងសមត្ថភាពសេវាផ្សព្វផ្សាយបច្ចេកទេសលើជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទាក់ទាញ ប្រមូលផ្តុំ និងបណ្តុះបណ្តាលកសិករវ័យក្មេងជាមួយនឹងបច្ចេកវិទ្យាកសិកម្មថ្មីៗ និងឌីជីថល | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| ១.៦ | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងចុះបញ្ជីកសិកម្ម (ដំណាំ ការចិញ្ចឹមសត្វ ព្រៃឈើ ជលផល ជាដើម) ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងព្យាករណ៍ការផ្គត់ផ្គង់ និងតម្រូវការសម្រាប់ដាក់ចេញនូវវិធានការនានាក្នុងការអភិវឌ្ឍវិស័យកសិកម្មទាំងមូល | √ | √ | √ | |
| ២ | **ការគាំទ្រកែលម្អច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យកសិកម្ម** | | | | - ក្រសួងយុត្តិធម៌<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ |
| ២.១ | រៀបចំកសាងច្បាប់ថ្មីៗបន្ថែមទៀតនិងធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធនឹងវិស័យកសិកម្មឱ្យស្របតាមសភាពការណ៍ជាក់ស្តែង (ធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល) | √ | √ | | |
| ២.២ | ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញឱ្យអនុវត្ត ដើម្បីពង្រឹងវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ | √ | √ | √ | |
| ២.៣ | រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ (អនុក្រឹត្យ ប្រកាសនានា) និងពិនិត្យលើតម្រូវការកែសម្រួលបទប្បញ្ញត្តិ ដែលគ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍កសិកម្ម ដើម្បីផ្តល់បរិយាកាសគាំទ្រដល់អ្នកផលិតផលិតផលកសិកម្ម អ្នកកែច្នៃ និងអ្នកនាំចេញ | √ | √ | √ | |
| ២.៤ | ពង្រីកការផ្សព្វផ្សាយនិងការយល់ដឹងជាសាធារណៈអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងកសិកម្ម | √ | √ | √ | |
| ៣ | **បង្កើនភាពជាអ្នកដឹកនាំក្នុងវិស័យកសិកម្ម** | | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញក្រោមឱវាទ |
| ៣.១ | ជំរុញការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងសមត្ថភាពការងារនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីគ្រប់គ្រង ដឹកនាំ និងគាំទ្រដល់កិច្ចអភិវឌ្ឍវិស័យកសិកម្មនិងអ្នកពាក់ព័ន្ធក្នុងវិស័យនេះ | √ | √ | √ | |
| ៣.២ | ពង្រឹងសមត្ថភាពដើម្បីទាក់ទាញការគាំទ្រនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ | √ | √ | √ | |

| | | | | | |
|---|---|---|---|---|---|
| | វិស័យកសិកម្ម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | |
| ៣.៣ | លើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅគ្រប់ដំណាក់កាលនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម និងអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត ដែលគិតគូរពីយេនឌ័រ | √ | √ | √ | |
| ៣.៤ | ផ្តល់ចំណេះដឹងបច្ចេកទេសនិងចំណេះធ្វើ ការងារប្រតិបត្តិការ ព្រមទាំងព័ត៌មានចាំបាច់សម្រាប់ការអនុវត្តនិងវាយតម្លៃគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មនៅថ្នាក់ក្រោមជាតិ | √ | √ | √ | |
| ៣.៥ | ពង្រឹងយន្តការនៃការអនុវត្តរបស់អង្គភាពគ្រប់គ្រងគម្រោងអភិវឌ្ឍន៍កសិកម្ម ដើម្បីបង្កើនការសម្របសម្រួល ការធ្វើសុខដុមនីយកម្មនៃគម្រោងទាំងអស់ឱ្យមានសង្គតិភាព និងជំរុញការអនុវត្តឆ្លើយតបទៅនឹងវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម | √ | √ | √ | |

## រូបភាពទី១ : ភាពជាដៃគូរវាងវិស័យសាធារណៈ ផ្នែកឯកជន អ្នកផលិត/សហគមន៍កសិកម្ម ( ៤Ps )

